TRUTH CENTERED TRANSFORMATION

MODULE ONE



# សេចក្តីផ្តើមអំពីព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ

# មគ្គុទ្ទេសក៍សម្រាប់គ្រូបង្រៀន

reconciledworld

This is a training tool designed by Reconciled World. visit TCTprogram.org for more information

កម្មវិធីផ្លាស់ប្រែសហគមន៍ដោយផ្តោតលើសេចក្តីពិត (Truth Centered Transformation) ជំពូកទី១៖ សេចក្តីផ្តើមអំពីព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ ត្រូវបានរក្សាសិទ្ធិ © 2012 ដោយអង្គការ រីខុនសាល់ វើលដ៍ (Reconciled World) ទីក្រុង ហ្វូអ៊ិននិក (Phoenix) រដ្ឋអារីសូណា (Arizona) សហរដ្ឋអាមេរិក។ គេហទំព័រ www.reconciledworld.org

ស្នាដៃនេះត្រូវបានដាក់ឲ្យប្រើប្រាស់នៅក្នុងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ Creative Commons Attribution-ShareAlike 3.0។ អ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តដើម្បីសម្របសម្រួលការងារ ថតចម្លង ចែកចាយ និងផ្ទេរស្នាដៃនេះនៅក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- **ការទទួលស្គាល់៖** អ្នកត្រូវតែទទួលស្គាល់ស្នាដៃនេះដោយរួមបញ្ចូលសេចក្តីដូចខាងក្រោម រក្សាសិទ្ធគ្រប់យ៉ាង © 2012។ ត្រូវបានចេញផ្សាយដោយអង្គការ រីខុនសាល់ វើលដ៍ (Reconciled World) (www.reconciledworld.org) ក្រោមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ Creative Commons Attribution-ShareAlike 3.0។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ www.creativecommon.org

- **មិនសម្រាប់ធ្វើពាណិជ្ជកម្ម៖** អ្នកមិនអាចប្រើប្រាស់ស្នាដៃនេះ ក្នុងគោលបំណងពាណិជ្ជកម្មឡើយ។

CC BY NC

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ក្នុងការបកប្រែសម្ភារៈនេះ សូមទាក់ទងមកកាន់ info@tctprogram.org ។

សម្រាប់អត្ថបទដើមជាភាសាអង់គ្លេស៖ ប្រសិនបើគ្មានការបញ្ជាក់ពីច្បាប់នៃការបកប្រែព្រះគម្ពីរ គ្រប់អត្ថបទគម្ពីរទាំងអស់ត្រូវបានដកស្រង់ចេញពីព្រះគម្ពីរច្បាប់ New International Version ®, NIV ®។ រក្សាសិទ្ធគ្រប់យ៉ាង © ឆ្នាំ១៩៧៣ ១៩៧៨ ១៩៨៤ ដោយ Biblica, Inc.™ ទទួលបានសិទ្ធអនុញ្ញាតពី Zondervan។ រក្សាសិទ្ធគ្រប់យ៉ាងទូទាំងពិភពលោកដោយ www.zondervan.com។ ព្រះគម្ពីររបស់ "NIV" និង "New International Version" ត្រូវបានចុះបញ្ជីពាណិជ្ជសញ្ញានៅក្នុងប៉ាតង់សហរដ្ឋអាមេរិក និង ការិយាល័យពាណិជ្ជសញ្ញា តាមរយៈ Biblica, Inc™

សម្រាប់អត្ថបទជាភាសាខ្មែរ៖ អត្ថបទគម្ពីរត្រូវបានដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរបច្ចុប្បន្ន © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល ២០០៥ - ដកស្រង់ដោយមានការអនុញ្ញាត។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណទៅមនុស្សគ្រប់គ្នាដែលបានផ្ដល់ជានិមិត្ត ការលើកទឹកចិត្ត និងការគាំទ្រដល់កម្មវិធីនេះ។ ការបំផុសគំនិតភាគច្រើនបានមកពីការបង្រៀនរបស់លោក ដារ៉ូ មីលឡើរ (Darrow Miller) នៃអង្គការ Disciple Nations Alliance និងលោក បប់ ម៉ូហ្វិត (Bob Moffitt) នៃមូលនិធិហាវ៉េសត៍ (Harvest Foundation)។ ខ្ញុំសូមថ្លែងអំណរគុណដល់លោកទាំងពីរជាខ្លាំង។

កម្មវិធីនេះត្រូវបានបង្កើត និងអនុវត្តនៅក្នុងពេលដែលខ្ញុំជាបុគ្គលិកនៅក្នុងអង្គការអាហារសម្រាប់ជនស្រេកឃ្លាន (Food for the Hungry)។ ដោយសារការប្រណីសន្ដោស និងការផ្ដល់ជំនួយខាងផ្នែកថវិកាពីបុគ្គលិក បានឲ្យខ្ញុំអាចសាកល្បងនូវគំនិតផ្សេងៗ ប្រមូលទិន្នន័យ និងបង្កើតកម្មវិធីដ៏រឹងមាំ និងប្រកបដោយនិរន្តរភាពនេះ។ សូមអរគុណចំពោះការជឿទុកចិត្តលើខ្ញុំ និងគាំទ្រកិច្ចការមួយនេះ។

នៅក្នុងជំពូកទី១នេះ ខ្ញុំបានយកសម្ភារៈជាច្រើនពីលោក បប់ និង ដារ៉ូ មកប្រើ ជាពិសេស សៀវភៅ «សីលធម៌នៃការអភិវឌ្ឍ» (Development Ethic និពន្ធដោយលោក ដារ៉ូ មីលលើរ និង «កម្មវិធីបណ្ដុះបណ្ដាលលើការអភិវឌ្ឍអ្នកដឹកនាំ» (Leadership Development Training Program) និពន្ធដោយលោក បប់ ម៉ូហ្វិត។ លើសពីនេះទៅទៀតនោះ គំនិតមួយចំនួនក្នុងការធ្វើបទបង្ហាញនូវសម្ភារៈដែលមានប្រភពដើមពីលោក ម៉ាក វៀលសុល (Mark Wilson)។ រឿងការដើរឆ្លងកាត់ទន្លេដែលអ្នកនឹងឃើញនៅក្នុងមេរៀនទី៨ ក៏ត្រូវបានដកស្រង់ចេញប្រភពផ្សេងៗទៀតដែរ ជាអកុសលខ្ញុំអាចមិនដាក់ឈ្មោះអ្នកនិពន្ធដើម ដើម្បីថ្លែងអំណរគុណដ៏សមរម្យបានទេ។

ខ្ញុំសូមអរគុណចំពោះអស់អ្នកដែលបានធ្វើការជាមួយខ្ញុំអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដូចដែលពួកគេបានសិក្សា និងអនុវត្តគំនិតទាំងនេះ។ ពួកគាត់សុទ្ធតែជាវីរបុរស វីរនារីដ៏ពិតប្រាកដរបស់ខ្ញុំ។ ការអនុវត្ត និងមតិអ្នកប្រើប្រាស់ទាំងនេះបានធ្វើឲ្យកិច្ចការនេះដំណើរការបាន ព្រមទាំងការលើកទឹកចិត្តរបស់ពួកគេធ្វើឲ្យខ្ញុំនៅតែបន្តទៅមុខទៀត ទោះបីជាពេលខ្លះខ្ញុំចង់បោះបង់ចោលក៏ដោយ។ ខ្ញុំនៅតែស្រលាញ់រាប់អានដល់ក្រុមអ្នកបង្ហាត់បង្រៀនដំបូង ពួកគេបានយល់ច្រឡំនៅពេលដែលខ្ញុំរៀនពីរបៀប និងអ្វីដែលត្រូវបង្រៀន។ ពួកគេបានអត់ធ្មត់ ព្យាយាមស្វែងយល់ និងថែមទាំងបង្រៀននូវគំនិតនានា ដែលក្រោយមកទើបបានយល់ថា គំនិតទាំងនោះមានភាពស្មុគស្មាញខាងផ្នែកបរិបទក្ដី។ ក៏ប៉ុន្តែព្រះជាម្ចាស់បានផ្លាស់ប្ដូរសហគមន៍ទាំងនោះឲ្យចេញពីភាពក្រីក្រ មិនថាយើងមានការបរាជ័យយ៉ាងណាក៏ដោយ ដែលនេះជាការរំឭកដល់លោកអ្នកទាំងអស់គ្នាថា កម្មវិធីនេះមិនមែនអំពីខ្ញុំ ឬអ្វីដែលខ្ញុំធ្វើទេ ប៉ុន្តែអំពីព្រះជាម្ចាស់ និងអ្វីដែលទ្រង់ធ្វើ។ ខ្ញុំពិតជារំភើបចិត្តជាខ្លាំង ដែលព្រះជាម្ចាស់បានអនុញ្ញាឲ្យខ្ញុំធ្វើជាផ្នែកនៃកិច្ចការនេះ និងប្រើប្រាស់ខ្ញុំ លើភាពខ្សោយរបស់ខ្ញុំ។ ខ្ញុំសូមថ្វាយសិរីរុងរឿងដាច់ដល់ទ្រង់តែមួយ។

ជាចុងក្រោយនេះ ខ្ញុំចង់ថ្លែងអំណរគុណដល់ស្វាមីជាទីស្រលាញ់របស់ខ្ញុំ ដែលបានលះបង់ព័ន្ធកិច្ចរបស់គាត់ដើម្បីធ្វើការងារនេះជាមួយខ្ញុំនៅក្នុងកម្មវិធីនេះផងដែរ។ ប្រសិនបើគ្មានគាត់ និងការលះបង់ជាច្រើនដែលគាត់បានធ្វើអស់ជាច្រើនឆ្នាំមកនេះ នឹងមិនអាចឲ្យកិច្ចការនេះដំណើរការបានទេ។ បងគឺជាអ្នកដែលតែងតែនៅក្បែរ និងគាំទ្រអូន។ អូនស្រលាញ់បងខ្លាំងណាស់!

# មាតិកា


**មេរៀនទី១៖ ដំណើររឿងទាំងមូល ............ ៦**

ហេតុអ្វីបានជាព្រះយេស៊ូសុគត? ............ ៦

កាលពីដើមដំបូង ............ ៦

ការធ្លាក់ចុះក្នុងអំពើបាប ............ ៧

បេសកកម្ម ............ ៨

ឈើឆ្កាង ............ ១០

ចុងបញ្ចប់នៃសាច់រឿង ............ ១១

**មេរៀនទី២៖ មនុស្សពិតជាសំខាន់ខ្លាំងណាស់សម្រាប់ព្រះជាម្ចាស់ ............ ១២**

សេចក្ដីផ្ដើម ............ ១២

ត្រូវបានបង្កើតឲ្យមានលក្ខណៈដូចព្រះជាម្ចាស់ ............ ១៣

ករណីសិក្សា៖ ក្រុមជំនុំសម័យដំបូង ............ ១៤

ការឆ្លុះបញ្ចាំង ............ ១៥

**មេរៀនទី៣៖ ស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់អ្នកជិតខាង ............ ១៦**

សេចក្ដីផ្ដើម៖ ការដើរតួសម្ដែងពីការផ្សព្វផ្សាយដំណឹងល្អ ............ ១៦

ក្រឹត្យវិន័យដ៏សំខាន់ ............ ១៨

ត្រូវស្រលាញ់អ្នកជិតខាងរបស់អ្នក ............ ១៨

ឈើឆ្កាង ............ ១៩

តើអ្នកជិតខាងយើងជានរណា? ............ ១៩

អនុវត្តន៍ ............ ២០

**មេរៀនទី៤៖ លូកា ២៖៥២ ............ ២១**

សេចក្ដីផ្ដើម ............ ២១

ការរីកចម្រើនរបស់ព្រះយេស៊ូ ............ ២២

អនុវត្តន៍លើជីវិតរបស់យើងផ្ទាល់ ............ ២៣

**មេរៀនទី៥៖ ព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំជួយដល់សហគមន៍ ............ ២៥**

សេចក្ដីផ្ដើម ............ ២៥

ចូរអាន អេសាយ ៥៨ ............ ២៦

អំបិល និងពន្លឺ ............ ២៦

ប្រស្នាអំពីសត្វចៀម និងសត្វពពែ នៅក្នុងម៉ាថាយ ២៥៖៣១-៤៦ ........................ ២៨
ការអនុវត្តន៍ ........................ ២៩
**មេរៀនទី៦៖ តើមានតម្រូវការអ្វីខ្លះ ដែលយើងអាចជួយបាន? ........................ ៣១**
និមិត្តរបស់គ្រូគង្វាលវ៉ង់ ........................ ៣១
ករណីសិក្សា៖ លោកយ៉ូសេ និងនាងម៉ារា ........................ ៣១
សហគមន៍របស់យើង ........................ ៣៣
**មេរៀនទី៧៖ គណិតវិទ្យាតាមបែបព្រះរាជ្យព្រះជាម្ចាស់ ........................ ៣៤**
សេចក្ដីផ្ដើម៖ អេសាយ ៤០៖២៩ ........................ ៣៤
ទី១៖ «ក្មេងប្រុស និងអាហារថ្ងៃត្រង់របស់គេ» (យ៉ូហាន ៦៖១-៤) ........................ ៣៥
ទី២៖ «ស្ត្រីមេម៉ាយ និងអាហារចុងក្រោយរបស់នាង»
(១ពង្សាវតាក្សត្រ ១៧៖៧) ........................ ៣៧
ទី៣៖ «ស្ត្រីមេម៉ាយ និងកាក់ពីរសេន» (ម៉ាកុស ១២៖៤១) ........................ ៣៨
ទី៤៖ «ប្រស្នាអំពីប្រាក់ណែន» (ម៉ាថាយ ២៥៖១៤) ........................ ៤០
សេចក្ដីសន្និដ្ឋាន ........................ ៤១
**មេរៀនទី៨៖ ការស្វែងយល់ពីរបៀបជួយ ........................ ៤២**
ការដើរឆ្លងទឹកទន្លេ ........................ ៤២
ដំណើររឿងពិតនៃការផ្លាស់ប្ដូររបស់អ្នកស្រី លី ........................ ៤៣
ករណីសិក្សា ........................ ៤៦
អនុវត្តន៍ ........................ ៤៨
**មេរៀនទី៩៖ សកម្មភាពនៃសេចក្ដីស្រលាញ់ ........................ ៤៩**
សេចក្ដីផ្ដើម ........................ ៤៩
សកម្មភាពនៃសេចក្ដីស្រលាញ់ ........................ ៤៩
លក្ខណៈរបស់សកម្មភាពនៃសេចក្ដីស្រលាញ់ ........................ ៥០
**មេរៀនទី១០៖ ការរៀបចំផែនការសកម្មភាពនៃសេចក្ដីស្រលាញ់ ........................ ៥៧**

មេរៀនទី១

# ដំណើររឿងទាំងមូល

**គោលបំណង**

១. យល់ពីគម្រោងការរបស់ព្រះជាម្ចាស់ គឺព្រះអង្គមិនគ្រាន់តែចង់ឃើញជីវិតមនុស្សត្រូវបានសង្គ្រោះប៉ុណ្ណោះទេ តែព្រះអង្គចង់ទតឃើញការស្ដារឡើងវិញនូវទំនាក់ទំនងទាំងបីដែលបានបាក់បែកដោយសារតែអំពើបាប។

**សម្ភារៈដែលត្រូវការ**

- រូបភាពនៃទំនាក់ទំនងទាំងបី

## ហេតុអ្វីបានជាព្រះយេស៊ូសុគត?

ចូរពិភាក្សាជាក្រុមធំថា ហេតុអ្វីបានជាព្រះយេស៊ូសុគត?

យើងតែងតែនិយាយថាព្រះយេស៊ូគ្រាន់តែមកសង្គ្រោះយើងពីអំពើបាបប៉ុណ្ណោះ។ វាជាការពិត ប៉ុន្តែទ្រង់បានយាងមកធ្វើការកិច្ចការជាច្រើនលើសពីនោះទៅទៀត។ ការសុគតរបស់ទ្រង់ គឺគ្រាន់តែជាផ្នែកមួយនៃសាច់រឿងទាំងមូលតែប៉ុណ្ណោះ។ ដើម្បីស្វែងយល់កាន់តែច្បាស់ពីខ្លឹមសារនៅក្នុងព្រះគម្ពីរ យើងចាំបាច់ត្រូវស្វែងយល់ពីដំណើររឿងទាំងមូលតាំងពីដើមដំបូងដល់ទីបញ្ចប់ជាមុនសិន។

## កាលពីដើមដំបូង

**រូបទី១៖ ការបង្កើត**



ដោយយោងទៅតាមអ្វីដែលយើងបានរៀននៅក្នុងលោកុប្បត្តិ១-២ តើអ្នកនឹងឆ្លើយសំណួរទាំងនេះយ៉ាងដូចម្ដេច? (ប្រសិនបើអ្នកចង់ធ្វើវានៅក្នុងក្រុមតូចក៏បានដែរ។ សូមរៀបចំក្រដាស ហើយសរសេរសំណួរនៅលើនោះ)

- តើពិភពលោកមានលក្ខណៈដូចម្ដេចកាលពីដើមដំបូងបង្អស់ នៅក្នុងសួនអេដែន?
- តើទំនាក់ទំនងរវាងព្រះជាម្ចាស់ និងលោកអដាំ មានលក្ខណៈដូចម្ដេច?
- តើទំនាក់ទំនងរវាងអដាំ និងអេវ៉ាមានលក្ខណៈដូចម្ដេច? តើអ្នកគិតថាពួកគេឈ្លោះគ្នាច្រើនដែរឬទេ?

- តើទំនាក់ទំនងរវាងអដាំ និងស្នាព្រះហស្តរបស់ព្រះជាម្ចាស់មានលក្ខណៈដូចម្តេច? តើអដាំមានអ្វីគ្រប់យ៉ាងដែលគាត់ត្រូវការដែរឬទេ? តើគាត់មានអាហារគ្រប់គ្រាន់ដែរឬទេ?

*ចូរបង្ហាញរូបភាពទី១ ហើយជួយឲ្យសិស្សយល់ថា កាលពីដំបូងឡើយមុនពេលមានអំពើបាប ទំនាក់ទំនងនីមួយៗនៃទំនាក់ទំនងទាំងបីគឺល្អឥតខ្ចោះ*

## ការធ្លាក់ចុះក្នុងអំពើបាប

ចូរអាននៅក្នុងលោកុប្បត្តិ ៣៖១-២០

ឲ្យមនុស្សពីរនាក់ដើរតួសម្តែងដូចខាងក្រោម៖

*«កិច្ចសន្ទនារវាងលោកអដាំ និងនាងអេវ៉ា»*

<u>អដាំ៖</u> (កំពុងថែសួន) អេវ៉ាអើយ! យើងធ្វើការក្នុងសួនពិតជាពិបាកណាស់ ក្រោយពីបេះផ្លែឈើបរិភោគ ធ្វើឲ្យព្រះជាម្ចាស់ខកព្រះទ័យមក។

<u>អេវ៉ា៖</u> ពិតមែនហើយ! កូនរបស់យើងក៏មិនចេះចុះសម្រុងនឹងគ្នាដែរ។ ពួកវាគិតតែពីឈ្លោះគ្នា និងវាយគ្នារហូត។ ខ្ញុំសង្ឃឹមថាវានឹងមិនកាន់តែពិបាកជាងនេះទេ។ ស្លឹកឈើដែលខ្ញុំពាក់បិទបាំងកាយនេះក៏មើលទៅអាក្រក់ណាស់!

<u>អដាំ៖</u> (ឈ្លោះតបមកវិញ) នែ! កុំត្អូញត្អែរពេក យើងគ្មានលទ្ធភាពណាទៅទិញខោអាវថ្មីនោះទេ! (ផ្អាក) ខ្ញុំនឹកដល់គ្រាដំបូងណាស់ នឹកពេលដែលព្រះជាម្ចាស់ធ្លាប់យាង និងមានព្រះបន្ទូលជាមួយយើង។ តែឥឡូវ ទ្រង់ខកព្រះទ័យណាស់ដែលយើងទៅជាអញ្ចឹង។ ហើយខ្ញុំចាំបានថាពីមុនសូម្បីតែសត្វក៏ស្តាប់បង្គាប់យើងដែរ? តែឥឡូវពួកវាខ្លាចយើងអស់ហើយ!

<u>អេវ៉ា៖</u> ពិតហើយ! ពួកវាថែមទាំងចង់ខាំយើងទៀត! អឺ...ខ្ញុំស្អប់ពស់ណាស់! ខ្ញុំមិនគួរស្តាប់តាមវាសោះ! កំហុសទាំងអស់នេះគឺមកពីពស់ទាំងអស់!

<u>អដាំ៖</u> ទេ គឺមកពីនាងហ្នឹង! នាងមិនដែលធ្វើអ្វីត្រូវទាល់តែសោះ! ហេតុអ្វីបានជាខ្ញុំស្តាប់តាមមនុស្សដែលស្តាប់បង្គាប់សត្វពស់អញ្ចឹង?

<u>អេវ៉ា៖</u> នែ កុំមកបន្ទោសខ្ញុំឲ្យសោះ! វាជាកំហុសរបស់លោកឯង! (ឈប់ដោយមុខក្រៀមក្រំ) សូមទោស ទោះបីស្រែកក៏គ្មានបានការអ្វីដែរ។ អដាំ តើអ្វីៗគ្រប់យ៉ាងនឹងវិលទៅរកដូចដើមទេ?

<u>អដាំ៖</u> ខ្ញុំមិនដឹងទេ មានតែព្រះជាម្ចាស់ទេ ទើបអាចធ្វើឲ្យវាដូចដើមវិញ!

<u>អេវ៉ា៖</u> អូ ទេ! (ស្រែកជំទាល ហើយរត់ចេញបាត់) ឈប់វាយគ្នាទៅ! ឈប់ភ្លាម! តើឯងស្តាប់ឮយើងនិយាយទេ? ម៉ែនឹងប្រាប់ឪពុកឯង ហើយគាត់នឹងមិនពេញចិត្តទេ!

<u>អដាំ៖</u> (ត្រឡប់ទៅសួនច្បារវិញ ទាំងដកដង្ហើមធំ) ថ្ងៃណាក៏ធ្វើ ធ្វើការ ធ្វើការ ធ្វើការ ធ្វើការ ធ្វើការ...

**ការពិភាក្សាជាក្រុមធំ៖**

តាមរយៈការសម្តែង និងពីអ្វីដែលអ្នកបានអាននៅក្នុងព្រះគម្ពីរ តើអ្វីជាបញ្ហាដែលមនុស្សកំពុងតែជួបប្រទះ បណ្តាលមកពីលទ្ធផលនៃអំពើបាប?




- ចូរអានលោកុប្បត្តិ ៣៖៨-១០ តើមានអ្វីកើតឡើងចំពោះទំនាក់ទំនងរវាងព្រះជាម្ចាស់ និងមនុស្សអំឡុងពេលនៃអំពើបាប?
- ចូរអានលោកុប្បត្តិ ៣៖១២ តើមានអ្វីកើតឡើងចំពោះទំនាក់ទំនងរបស់មនុស្សជាមួយគ្នាទៅវិញទៅមកក្នុងអំឡុងពេលនៃអំពើបាប?
- ចូរអានលោកុប្បត្តិ ៣៖១៥ តើមានអ្វីកើតឡើងចំពោះទំនាក់ទំនងរវាងមនុស្សនឹងស្នាព្រះហស្តរបស់ព្រះជាម្ចាស់?

ចូរពន្យល់៖ នៅគ្រាដែលមនុស្សបានធ្លាក់ចុះក្នុងអំពើបាប ពួកអារក្សបានឈានជើងចូលក្នុងពិភពលោក ទាំងអារក្សមានតែវិញ្ញាណ និងអារក្សមានរូបកាយ។ មុនគ្រាដែលមនុស្សបានធ្លាក់ចុះ ពួកគេមានអាហារគ្រប់គ្រាន់ និងពុំដែលមានរញ្ជួយដី ទឹកជំនន់ និងគ្រោះរាំងស្ងួតឡើយ។ ដោយសារតែការធ្លាក់ចុះនេះឯងដែលបណ្តាលឲ្យយើងទទួលរងនូវគ្រោះទាំងអស់នេះ។

ការធ្លាក់ចុះបានបំផ្លិចបំផ្លាញទំនាក់ទំនងទាំងបីឲ្យខ្ទេចខ្ទាំ។

## បេសកកម្ម

ដំណាក់កាលបន្ទាប់នៃដំណើររឿងរវាងព្រះជាម្ចាស់ និងស្នាព្រះហស្តរបស់ព្រះអង្គ គឺឃើញមាននៅចន្លោះរវាងការធ្លាក់ចុះរបស់មនុស្ស និងចុងបញ្ចប់នៃព្រះគម្ពីរសម្ពន្ធមេត្រីចាស់។ (ចូរ បើករកចំណុចក្នុងព្រះគម្ពីរដែលអ្នកចង់បង្ហាញដល់សិស្ស)

នេះជាដំណាក់កាលដែលព្រះជាម្ចាស់កំពុងស្វែងរកប្រជារាស្ត្ររបស់ទ្រង់។ ដ្បិតព្រះអង្គមានបំណងចង់ទតឃើញនូវការស្តារឡើងវិញនៃទំនាក់ទំនងដែលបានបាក់បែក៖

- **លោកអប្រាហាំ៖** ចូរអានលោកុប្បត្តិ ១២៖១-៣។ នៅក្នុងផ្នែកនេះ ព្រះជាម្ចាស់ជ្រើសតាំង លោកអប្រាហាំឡើងហើយប្រទានពរឲ្យលោក។ ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានពរដល់លោកអប្រាហាំ? (ព្រះជាម្ចាស់សព្វព្រះទ័យប្រទានពរដល់ជាតិសាសន៍ទាំងឡាយ)។ នៅក្នុងខគម្ពីរមួយនេះ យើងឃើញពីគម្រោងការរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះពិភពលោកទាំងមូល។ ព្រះអង្គសព្វព្រះហឫទ័យប្រទានពរដល់ជាតិសាសន៍ទាំងឡាយតាមរយៈក្រុមជំនុំ។

- **លោកម៉ូសេ៖** ព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យទាំង១០ ដល់មនុស្ស ដើម្បីឲ្យយើងដឹងពីរបៀបស្តារនូវទំនាក់ទំនងដែលបែកបាក់ឡើងវិញ។

    - តើក្រឹត្យវិន័យគ្រាន់តែចែងពីកិច្ចការខាងវិញ្ញាណ ឬក៏ចែងពីទំនាក់ទំនងរបស់យើងជាមួយគ្នាម្នាក់ៗ និងជាមួយធម្មជាតិដែរ?

        - ត្រូវពន្យល់ឲ្យសិស្សដឹងថា វិន័យគឺចែងអំពីទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់ (និក្ខមនំ ២១៖៣) ទំនាក់ទំនងរបស់យើងជាមួយគ្នាទៅវិញទៅមក (ឧ. និក្ខមនំ ២១៖១២) និងទំនាក់ទំនងរបស់យើងជាមួយស្នាព្រះហស្តរបស់ព្រះជាម្ចាស់ (និក្ខមនំ ២៣៖១០)។ មានក្រឹត្យវិន័យខ្លះជួយបង្ហាញមនុស្សឲ្យចេះរស់នៅដោយមានសុខភាពល្អ (លេវីវិន័យ ១៣) ឲ្យចេះប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក (ឧ. និក្ខមនំ ២៣៖១-៩)។ ព្រះជាម្ចាស់មិនត្រឹមតែមានព្រះទ័យទុកដាក់លើកិច្ចការខាងវិញ្ញាណប៉ុណ្ណោះទេ តែព្រះអង្គមានព្រះទ័យទុកដាក់លើគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង។ នេះជាមូលហេតុដែលទ្រង់បង្កើតក្រឹត្យវិន័យឡើងសម្រាប់គ្រប់ផ្នែកទាំងអស់ដែលបានបាក់បែកដោយសារអំពើបាប។

    - ចូរអាន ទុតិយកថា ២៨៖១-១៤ តើព្រះជាម្ចាស់មានព្រះបន្ទូលថា ប្រសិនបើយើងគោរពតាមក្រឹត្យវិន័យទាំងអស់នេះ តើនឹងមានលទ្ធផលអ្វីកើតឡើង? តើការប្រទានពរដែលព្រះជាម្ចាស់សន្យា គឺសម្រាប់តែខាងវិញ្ញាណ ឬជាការប្រទានពរសម្រាប់ខាងរូបកាយដែរ?

- ព្រះជាម្ចាស់បានជ្រើសតាំងស្តេច និងព្យាការីនានាឡើងសម្រាប់ជនជាតិអ៊ីស្រាអែល ប៉ុន្តែម្តងហើយម្តងទៀត ពួកគេនៅតែរងទុក្ខវេទនាដោយសារភាពក្រីក្រ និងសង្គ្រាមដ្បិតពួកគេបានបែរខ្នងដាក់ព្រះជាម្ចាស់។

- ២របាក្សត្រ ៧៖១៤

    - តើព្រះជាម្ចាស់ត្រាស់ហៅនរណាឲ្យបន្ទាបខ្លួន ហើយអធិស្ឋាន? (មិនមែនមនុស្សទាំងអស់ទេ គឺសំដៅលើតែប្រជារាស្ត្ររបស់ទ្រង់ប៉ុណ្ណោះ សព្វថ្ងៃគឺសំដៅលើគ្រិស្តបរិស័ទនេះឯង)។

- តើព្រះជាម្ចាស់មានព្រះបន្ទូលថានឹងមានរឿងអ្វីកើតឡើង ប្រសិនបើពួកគេស្តាប់បង្គាប់? (ព្រះជាម្ចាស់នឹងប្រោសស្រុកយើងឲ្យជា)។ សេចក្តីនេះនៅតែពិតមកដល់សព្វថ្ងៃនេះ។ កិច្ចការនេះ គឺលើសពីការដែលជីវិតមនុស្សត្រូវបានសង្គ្រោះទៅទៀត។ សេចក្តីនេះចែងអំពីសេចក្តីពិតដែលថា ព្រះជាម្ចាស់នឹងប្រោសទំនាក់ទំនាងទាំងបីនេះឲ្យបានជា។

## ឈើឆ្កាង

នេះមិនគ្រាន់តែជាផ្នែកដែលប្រសើរបំផុតនៅក្នុងរឿងនោះទេ តែក៏ជាផ្នែកដែលសំខាន់ជាងគេដែរ។ នៅក្នុងសាសនាភាគច្រើន គេតម្រូវឲ្យអ្នកជឿធ្វើសក្ការៈបូជាដើម្បីគាប់ចិត្តព្រះរបស់គេ។ តែនៅក្នុងជំនឿគ្រិស្តបរិស័ទវិញ គឺព្រះជាម្ចាស់ស្រលាញ់មនុស្សខ្លាំងណាស់ ដែលព្រះអង្គសុខចិត្តចាត់ឲ្យបុត្រាតែមួយរបស់ព្រះអង្គឲ្យមកសុគតសម្រាប់ពួកគេ។

ចូរអាន កូឡុស ១៖១៩-២០ ហេតុអ្វីបានជាព្រះយេស៊ូសុគត?

- ដើម្បីសម្រុះសម្រួលទំនាក់ទំនងទាំងអស់

រូបទី៣៖ ការស្តារឡើងវិញ



បង្ហាញរូបទី៣ រួចពន្យល់ឲ្យសិស្សដឹងថាព្រះជាម្ចាស់បានយាងមកដើម្បីសម្រុះសម្រួលអ្វីៗគ្រប់យ៉ាងដែលបានខូចខ្ទាំកាលពីគ្រាធ្លាក់ចុះរបស់មនុស្ស។ តែទោះជាយ៉ាងនេះក្តី ក៏អ្វីៗទាំងអស់ពុំទាន់ឈានទៅដល់ភាពល្អឥតខ្ចោះដែរ លុះត្រាដល់ចុងបញ្ចប់នៃសាច់រឿង។

ព្រះយេស៊ូបានប្រទានឲ្យយើងនូវបេសកកម្មដ៏អស្ចារ្យ។ ទំនួលខុសត្រូវរបស់យើង គឺមិនត្រឹមជួយឲ្យមនុស្សក្លាយជាគ្រិស្តបរិស័ទប៉ុណ្ណោះទេ តែព្រះអង្គចង់ឲ្យយើងបង្កើតសិស្សនៅក្នុងជាតិសាសន៍នានា។ ការជួយឲ្យជាតិសាសន៍ដទៃក្លាយជាសិស្ស (ឬសាវ័ក) មានន័យថា ជួយឲ្យជាតិសាសន៍នោះដើរតាមបំណងរបស់ព្រះជាម្ចាស់នូវគ្រប់ផ្នែកទាំងអស់ ដែលទ្រង់បានយាងមកដើម្បីសម្រុះសម្រួល។

# ចុងបញ្ចប់នៃសាច់រឿង

រូបទី១៖ ការត្រឡប់មកវិញ



ចូរអាន វិវរណៈ ២១៖១-៧

- តើចុងបញ្ចប់ ទំនាក់ទំនងរបស់មនុស្សជាមួយព្រះជាម្ចាស់នឹងមានលក្ខណៈដូចម្ដេច?
- តើទំនាក់ទំនងរបស់មនុស្សជាមួយគ្នាទៅវិញទៅមក នឹងមានលក្ខណៈដូចម្ដេច?
- តើទំនាក់ទំនងរបស់មនុស្ស ជាមួយនឹងធម្មជាតិនឹងមានលក្ខណៈដូចម្ដេចដែរ? តើយើងនឹងមានអាហារបរិភោគគ្រប់គ្រាន់ដែរឬទេ? តើយើងនឹងមានជម្ងឺដែរឬទេ?

## សេចក្ដីសន្និដ្ឋាន

នេះជាដំណើររឿងទាំងមូល ជាដំណើររឿងដ៏ល្អប្រពៃ ដែលតំណាលតាំងពីដើមដំបូងរហូតដល់ចប់ អំពីរបៀបដែលព្រះជាម្ចាស់ បង្កើតពិភពលោកនេះមកដោយល្អឥតខ្ចោះ។ ដោយសារតែអំពើបាបឈានចូលមក ធ្វើឲ្យអ្វីៗគ្រប់យ៉ាងត្រូវវិនាស និងការដែលព្រះជាម្ចាស់បានស្រលាញ់មនុស្សលោកខ្លាំងប៉ុណ្ណា ទើបទ្រង់បានបញ្ជូនព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យយាងមក ដើម្បីស្ដារទំនាក់ទំនងទាំងប៉ុន្មាន ដែលបានបែកបាក់ដោយសារតែអំពើបាប ហើយនិងការដែលឲ្យយើងដឹងថា ថ្ងៃណាមួយ ព្រះជាម្ចាស់និងយាងត្រឡប់មកវិញ ហើយព្រះអង្គនិងធ្វើឲ្យអ្វីៗទាំងអស់ទៅជាថ្មីឡើងវិញ។

ព្រះជាម្ចាស់ស្រលាញ់អ្នកខ្លាំងណាស់។ ដ្បិតព្រះអង្គបានបញ្ជូនព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យមកសុគត ដើម្បីឲ្យអ្នកមានទំនាក់ទំនងជាមួយទ្រង់ និងដើម្បីឲ្យអ្នកមានទំនាក់ទំនងល្អទៅវិញទៅមកជាមួយគ្នា និងជាមួយស្នាព្រះហស្ថរបស់ព្រះអង្គ។

# មេរៀនទី២

# មនុស្សពិតជាសំខាន់ខ្លាំងណាស់សម្រាប់ព្រះជាម្ចាស់

**គោលបំណង៖**

១. យល់ថាយើងត្រូវបានបង្កើតមកឲ្យមានលក្ខណៈដូចព្រះជាម្ចាស់។

២. យល់ថាមនុស្សគ្រប់រូបសុទ្ធតែមានតម្លៃ ព្រោះគេត្រូវបានបង្កើតមកដោយលក្ខណៈដូចព្រះជាម្ចាស់ ហើយព្រះយេស៊ូសុគតសម្រាប់ពួកគេ។

៣. យល់ថាព្រះជាម្ចាស់ស្រលាញ់យើងខ្លាំង រហូតដល់ចាត់បុត្រារបស់ព្រះអង្គឲ្យយាងមកសុគតដើម្បីយើង ដូច្នេះយើងជាមនុស្សជាតិដូចគ្នា គួរចេះស្រលាញ់គ្នា។

## សេចក្តីផ្តើម



**ការពិភាក្សាជាក្រុមធំ៖**

- តើនៅក្នុងវប្បធម៌របស់អ្នក ជឿថាថាតើមនុស្សកើតចេញមកពីណា?
- តើជំនឿទាំងនោះ នាំឲ្យមានលទ្ធផលអ្វី? ប្រសិនបើនរណាម្នាក់ជឿលើរឿងទាំងអស់នោះ តើពួកគេនឹងគិតថាមនុស្សពិតជាសំខាន់ដែរឬទេ?

នៅក្នុងប្រទេសឥណ្ឌា មានស្ត្រីម្នាក់ដែលគេហៅគាត់ថា អ្នកម្តាយថេរីសា (Teresa) ជាអ្នកដែលបានបង្កើតផ្ទះដើម្បីជួយមើលថែអ្នកជិតស្លាប់នៅតាមដងផ្លូវ ដើម្បីឲ្យគេអាចស្លាប់ដោយមានសេចក្តីថ្លៃថ្នូរ។ មានមនុស្សជាច្រើននៅក្នុងប្រទេសឥណ្ឌាបានរិះគន់គាត់យ៉ាងខ្លាំង ដោយគេនិយាយថា នៅប្រទេសឥណ្ឌាមានមនុស្សច្រើនណាស់ ហេតុអ្វីបានជាគាត់ជួយមនុស្សដែលជិតនឹងស្លាប់ទៅហើយ។ តើអ្នកគិតយ៉ាងដូចម្តេចដែរ? តើព័ន្ធកិច្ចនេះមានតម្លៃស័ក្តិសមដែរឬទេ?

# ត្រូវបានបង្កើតឲ្យមានលក្ខណៈដូចព្រះជាម្ចាស់

**ការពិភាក្សានៅក្នុងក្រុមធំ៖** មើលតាមផ្នែកនីមួយៗនៃខគម្ពីរ ម្ដងមួយៗ។

ចូរអាន លោកុប្បត្តិ ១៖២៦-២៧

- តើមនុស្សមានលក្ខណៈខុសប្លែកពីស្នាព្រះហស្តផ្សេងៗទៀតរបស់ព្រះជាម្ចាស់យ៉ាងណាខ្លះ? តើព្រះជាម្ចាស់បានប្រើអ្វី ជាគំរូរបស់ទ្រង់ទៅដល់មនុស្ស?
- តើបុគ្គលិកលក្ខណៈណាខ្លះរបស់ព្រះជាម្ចាស់ ដែលយើងអាចរកឃើញនៅក្នុងមនុស្ស? ចូររៀបរាប់ឲ្យបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាន។

ចូរអាន ទំនុកតម្កើង ១៣៩៖១៣-១៦

- តើនៅក្នុងខគម្ពីរនេះបានប្រាប់យើងពីសារៈសំខាន់របស់មនុស្សយ៉ាងដូចម្ដេច?
- តើអ្នកយល់ថា ខគម្ពីរនេះ គឺសម្រាប់តែមនុស្សមួយចំនួន ឬសម្រាប់មនុស្សទាំងអស់?

<u>ពន្យល់</u>៖ ព្រះជាម្ចាស់បានរចនាយើង និងបង្កើតយើងមកដោយយកចិត្តទុកដាក់ជាខ្លាំង ហើយទ្រង់បានកត់ត្រាទុកនូវថ្ងៃនៃអាយុជីវិតរបស់យើងនៅក្នុងក្រាំង។ យើងមិនគ្រាន់តែកើតឡើងដោយឯកឯងនោះទេ ប៉ុន្តែព្រះជាម្ចាស់បានបង្កើតយើងម្នាក់ៗ។

**ការពិភាក្សានៅក្នុងក្រុមធំ**

យ៉ូហាន ៣៖១៦

- តើព្រះជាម្ចាស់បានធ្វើអ្វី ដើម្បីស្ដារពិភពលោកឡើងវិញ?
- តើព្រះជាម្ចាស់បានសុគតសម្រាប់យើងដោយសារតែយើងជាមនុស្សល្អឬ? (ប្រសិនបើពួកគេមិនប្រាកដ សូមមើល រ៉ូម៥៖៨)
- ចុះបើព្រះជាម្ចាស់សុខចិត្តចាត់ឲ្យព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យមកសុគតសម្រាប់មនុស្ស ដូច្នេះតើទ្រង់គិតថាមនុស្សសំខាន់កម្រិតណា?
- តើវាមានអត្ថន័យបែបណា ចំពោះរបៀបដែលយើងត្រូវប្រព្រឹត្តចំពោះមនុស្សដទៃទៀត?

**សង្ខេប៖**

នៅក្នុងខគម្ពីរទាំងនេះ យើងឃើញយ៉ាងច្បាស់ថា មនុស្សគឺមានសារៈសំខាន់ចំពោះព្រះជាម្ចាស់។ ព្រះអង្គបានបង្កើតយើងមកឲ្យមានលក្ខណៈដូចទ្រង់។ ព្រះជាម្ចាស់បានបង្កើតយើងម្នាក់ៗ និងដាក់យើងនៅ

ក្នុងផ្ទៃម្ដាយដោយយកព្រះទ័យទុកដាក់។ ទ្រង់យកព្រះទ័យទុកដាក់ដល់មនុស្សលោកយ៉ាងខ្លាំង រហូតដល់ទ្រង់សុខចិត្តចាត់ព្រះបុត្រារបស់ព្រះអង្គ ឲ្យមកសុគតសម្រាប់ពួកគេ។

ចូរគិតម្ដងទៀតអំពីកិច្ចការរបស់អ្នកម្ដាយ ថេរីសា នៅប្រទេសឥណ្ឌា។ តើគំនិតទាំងនេះ អាចជួយឲ្យយើងយល់ពីកិច្ចការរបស់គាត់ប្រសើរជាងមុនដែរឬទេ? ហេតុអ្វីបានជាអ្នកគិតថាគាត់ បែរជាយកចិត្តទុកដាក់នឹងមនុស្សជិតស្លាប់ទៅវិញ?

មានគ្រាមួយ ដែលអ្នកយកព័ត៌មានដ៏ល្បីម្នាក់ បានសាកសួរពីមូលហេតុដែលជំរុញឲ្យគាត់ធ្វើដូច្នេះ។ គាត់បានដកស្រង់ខគម្ពីរចេញពីម៉ាថាយ ២៥៖៣១-៤៦ ដែលជាខគម្ពីរនិយាយអំពីសត្វចៀម និងសត្វពពែ។ នៅក្នុងខគម្ពីរនេះព្រះយេស៊ូបានដាក់ទោសអ្នកដែលនៅខាងឆ្វេងដោយមានព្រះបន្ទូលថា «កាលយើងឃ្លានអ្នករាល់គ្នាពុំបានឲ្យម្ហូបអាហារ **យើង**បរិភោគទេ កាល**យើង**ស្រេក អ្នករាល់គ្នាក៏ពុំបានឲ្យទឹក**យើង**ពិសារដែរ»។ នៅពេលពួកគេតបថា ទាំងមិនដែលឃើញព្រះយេស៊ូឃ្លាន ឬស្រេកទឹក ព្រះអង្គក៏មានព្រះបន្ទូលតបវិញថា «គ្រប់ពេលអ្នករាល់គ្នាមិនបានប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេបំផុតដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏មិនបានប្រព្រឹត្តចំពោះយើងដែរ» ។ អ្នកម្ដាយថេរីសាបានពន្យល់ថា ការបម្រើដល់មនុស្សដែលជិតស្លាប់នៅតាមផ្លូវក្នុងប្រទេសឥណ្ឌាក៏ដូចជាបម្រើដល់ព្រះយេស៊ូដែរ។

**ចូរគិតពីសេចក្ដីនេះ៖** យើងម្នាក់ៗមានតម្លៃយ៉ាងខ្លាំងចំពោះព្រះជាម្ចាស់។ ហេតុដូច្នេះហើយមនុស្សគ្រប់គ្នានៅក្នុងសហគមន៍របស់អ្នកក៏មានតម្លៃដូចគ្នាដែរ។ ចូរចំណាយពេលគិតដោយស្ងៀមស្ងាត់ ថាអ្វីក៏ដោយដែលអ្នកប្រព្រឹត្តចំពោះមនុស្សនៅក្នុងសហគមន៍ គឺត្រូវប្រព្រឹត្តដោយតម្លៃ ដ្បិតពួកគេសុទ្ធតែមានតម្លៃចំពោះព្រះជាម្ចាស់។

## ករណីសិក្សា៖ ក្រុមជំនុំសម័យដំបូង

ចូរអានករណីសិក្សាដូចខាងក្រោម៖

គ្រិស្តបរិស័ទនៅក្នុងក្រុមជំនុំសម័យដំបូង យល់ថាមនុស្សគ្រប់គ្នាសុទ្ធតែមានសារៈសំខាន់។ នាសម័យនោះ មនុស្សជឿថាព្រះជាច្រើនគិតតែប្រយុទ្ធប្រឆាំងគ្នាដណ្ដើមយកតំណែងធំ ហើយតម្រូវឲ្យមនុស្សថ្វាយយញ្ញបូជាដើម្បីចៀសវាងការដាក់ទណ្ឌកម្មផ្សេងៗពីព្រះទាំងនោះ។ ប៉ុន្តែ ចំពោះគ្រិស្តបរិស័ទវិញ ពួកគេដឹងច្បាស់ថាព្រះជាម្ចាស់ខុសប្លែកពីព្រះក្លែងក្លាយដទៃទៀត។ ទ្រង់បានប្រទានយញ្ញបូជាដើម្បីមនុស្ស ដ្បិតព្រះអង្គបានចាត់ព្រះបុត្រាតែមួយរបស់ព្រះអង្គឲ្យមកសុគតសម្រាប់គេ (យ៉ូហាន ៣៖១៦)។ ជំនឿនេះមានន័យថា មនុស្សគ្រប់ៗរូបសុទ្ធតែមានតម្លៃ និងមានសារៈសំខាន់យ៉ាងធំធេង។ ដោយសារការយល់ដឹងច្បាស់អំពីសេចក្ដីស្រលាញ់ដែលមិនគួរឲ្យជឿរបស់ព្រះជាម្ចាស់សម្រាប់ពិភពលោក និងមនុស្សជាតិនេះហើយ នាំឲ្យក្រុមជំនុំសម័យដំបូងនាំគ្នាប្រឆាំងនឹងការប្រព្រឹត្តខុសឆ្គងនានា ដូចជាការ

ពន្លូតកូន និងការសម្លាប់ទារកជាដើម។ នៅសម័យនោះ ប្រសិនបើទារកកើតមកជាក្មេងស្រី គេនិងបោះបង់វាចោលនៅតាមផ្លូវ។ ទោះបីជាយ៉ាងណាក៏ដោយ សម្រាប់គ្រិស្តបរិស័ទយល់យ៉ាងច្បាស់ថាគ្រប់ជីវិតមនុស្ស មិនថាជនពិការ ទារកមិនទាន់កើត មនុស្សប្រុសឬស្រី ជាទាសករ ឬជាអ្នកមានក្តី គឺសុទ្ធតែមានតម្លៃដ៏ធំធេងចំពោះព្រះជាម្ចាស់។ ដោយការយល់ឃើញបែបនេះហើយ ទើបបានពួកគេជួយសង្គ្រោះទារកដែលគេបោះបង់នៅតាមផ្លូវ ហើយចិញ្ចឹមពួកគេទុកដូចជាកូនរបស់ខ្លួន។

ក្រុមជំនុំសម័យដំបូងក៏ជឿថា ដ្បិតព្រះជាម្ចាស់បានបង្ហាញក្តីស្រលាញ់របស់ព្រះអង្គ ដោយការលះបង់ព្រះជន្មាយុរបស់ទ្រង់ជំនួសយើង យើងក៏ត្រូវមានភារៈកិច្ចលះបង់បម្រើដល់អ្នកដទៃវិញដែរ។ អ្នកដើរតាមព្រះយេស៊ូសុទ្ធតែយល់ថាព្រះជាម្ចាស់ មានការអាណិតអាសូរ និងក្តីមេត្តាចំពោះគេយ៉ាងណា គេក៏ត្រូវមានការអាណិតអាសូរ និងក្តីមេត្តាចំពោះអ្នកដទៃយ៉ាងនោះដែរ។

ក្នុងអំឡុងពេលនោះ ស្រាប់តែមានការផ្ទុះឡើងការរាតត្បាតនៃជម្ងឺអាសន្នរោគ។ ពេលនោះ ប្រសិនបើអ្នកផ្តល់ទឹកឲ្យអ្នកដែលមានជម្ងឺអាសន្នរោគ នោះគេអាចមានសង្ឃឹមរស់ខ្ពស់។ តែបើគ្មានទឹក ពួកគេនឹងត្រូវស្លាប់ជាមិនខាន។ ទោះបីជាយ៉ាងណាក៏ដោយ ជម្ងឺអាសន្នរោគជាជម្ងឺដ៏កាចសាហាវបំផុត។ ពួកជនជាតិរ៉ូម៉ាំងខ្លាចឆ្លងជម្ងឺនោះណាស់ កាលណាពួកគេឃើញមនុស្សដែលមានជម្ងឺនោះ ពួកគេនឹងបោះបង់ចោលអ្នកនោះឲ្យដេកស្លាប់តាមផ្លូវ ជាជាងឲ្យទឹកពួកគេបរិភោគ។ ជីវិតមនុស្សមិនសំខាន់ចំពោះពួកគេទេ។ ប៉ុន្តែ គ្រិស្តបរិស័ទខុសប្លែកពីពួកគេ។ តាមពិតទៅ ពួកគេនឹងចូលទៅកាន់អ្នកណាដែលមានជម្ងឺនោះ ហើយឲ្យទឹក និងមើលថែរក្សាពួកគេ។ ពួកគេបម្រើប្រកបដោយការលះបង់ និងក្តីមេត្តា។ ថ្វីត្បិតតែមានមនុស្សជាច្រើនស្លាប់ដោយសារតែជម្ងឺនេះ ប៉ុន្តែតាមរយៈសេចក្តីស្រលាញ់របស់ពួកគេ ធ្វើឲ្យចំនួនគ្រិស្តបរិស័ទមានការកើនឡើងយ៉ាងឆាប់រហ័ស។

## ការឆ្លុះបញ្ចាំង

ចូរយកពេលគិតអំពីរឿងនេះដោយស្ងាត់ៗសម្រាប់ខ្លួនអ្នក។

ចូរសុំព្រះជាម្ចាស់ឲ្យជួយអ្នកពីរបៀបប្រព្រឹត្តចំពោះអ្នកដទៃ។ តើអ្នកប្រព្រឹត្តចំពោះពួកគេ ដូចដែលព្រះជាម្ចាស់គិតថាពួកគេពិតជាសំខាន់ ដែលទ្រង់សុខចិត្តសុគតសម្រាប់ពួកគេដែរឬទេ? តើអ្នកធ្វើល្អ តែជាមួយមនុស្សមួយចំនួន ហើយមិនល្អជាមួយអ្នកផ្សេងទៀតឬ? ចូរទូលសុំឲ្យព្រះជាម្ចាស់អត់ទោសឲ្យរូបអ្នក ចំពោះទង្វើណាដែលអ្នកបានប្រព្រឹត្តខុសនឹងព្រះហឫទ័យរបស់ព្រះអង្គទៅលើអ្នកដទៃ។ ចូរទូលសុំឲ្យទ្រង់បង្ហាញអ្នក ពីរបៀបដែលទ្រង់ឃើញមនុស្ស។

**ពិភាក្សានៅក្នុងក្រុមតូចៈ**

- តើមនុស្សប្រភេទណាខ្លះដែលមិនត្រូវបានគេឲ្យតម្លៃ?
- តើមានវិធីសាស្រ្តណាខ្លះ ដែលយើងអាចបង្ហាញទៅកាន់មនុស្សថា ពួកគេពិតជាសំខាន់ខ្លាំងណាស់សម្រាប់ព្រះជាម្ចាស់?

## មេរៀនទី៣

# ស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់អ្នកជិតខាង

**គោលបំណង៖**

១. ស្វែងយល់ពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងការឲ្យយើងស្រលាញ់អ្នកជិតខាង

២. ស្គាល់ថាអ្នកជិតខាងរបស់យើងជានរណា

៣. គិតពីរបៀបដែលយើងអាចស្រលាញ់អ្នកជិតខាងរបស់យើង។

## សេចក្ដីផ្ដើម ៖ ការដើរតួសម្ដែងពីការផ្សព្វផ្សាយដំណឹងល្អ

ចូរជ្រើសរើសយកសមាជិក៣នាក់ពីក្នុងក្រុមឲ្យចូលរួមសម្ដែងដូចខាងក្រោម៖



អ្នកពោលពីសេចក្ដីផ្ដើម៖ ពេលខ្លះគ្រិស្តបរិស័ទមានអ្វីម្យ៉ាងដែលយើងហៅថា «គំនិតចង្អៀតចង្អល់ពីការផ្សព្វផ្សាយដំណឹងល្អ»។ ពួកគេយល់ឃើញថា ការទទួលយកព្រះយេស៊ូគ្រិស្ត គឺជាការសម្រេចចិត្តស្លាប់រស់ ហើយក្រៅពីនេះពួកគេមិនយល់អ្វីទៀតសោះឡើយ។ បើគេមិនដែលបើកភ្នែកមើលពីតម្រូវការរបស់អ្នកដទៃផង នោះការផ្សព្វផ្សាយដំណឹងល្អរបស់គេក៏ឥតប្រយោជន៍ដែរ... នៅថ្ងៃនេះ យើងនឹងទៅសួរសុខទុក្ខផ្ទះជនក្រីក្រមួយកន្លែង។ ម្ចាស់ផ្ទះ (អក្សរកាត់ ម.ផ) នោះ ឈឺជាទម្ងន់ដេកលើគ្រែ (គាត់ជាជនទីទាល់ក្រ ហើយមានជម្ងឺ)។ ពេលនោះ មានអ្នកមកសួរសុខទុក្ខម្នាក់ដែលជាអ្នកផ្សាយដំណឹងល្អ (អក្សរកាត់ អ.ផ.ល) តាមផ្ទះបានមកដល់។

**អ.ផ.ល៖** ជម្រាបសួរ! មាននរណានៅផ្ទះទេ? ខ្ញុំសុំចូលបានអត់? (ដើរចូល)

**ម.ផ៖** (ខ្សោយនិយាយខ្សែវៗ) នៅហ្នឹងតើ ចូលមក. . .

**អ.ផ.ល៖** ជម្រាបសួរ ខ្ញុំឈ្មោះ____________មកពីក្រុមជំនុំ____________។ ថ្ងៃនេះខ្ញុំមកទីនេះដើម្បីអញ្ជើញបងប្អូនគ្រប់គ្នាឲ្យចូលរួមក្រុមជំនុំយើងខ្ញុំ។ ព្រះអម្ចាស់បានប្រទានពរយើងឲ្យមានកម្លាំងឡើងវិញ ដូច្នេះអ្នកគួរតែទៅកុំខកខានឲ្យសោះណា។

**ម.ផ ៖** (ថ្ងូរឈឺ និយាយទាក់ៗ) ខ្ញុំទៅអត់រួចទេ... គ្រាន់តែងើបពីគ្រែក៏អត់រួចផងហ្នឹង... យ៉ាប់ណាស់ កម្រើកក៏អត់រួចដែរ... អស់ហើយខ្ញុំ ការងារក៏បាត់បង់ដែរ... លុយមួយរៀលទិញថ្នាំក៏អត់មានដែរ... ម្ហូបហូបក៏អត់... លុយជួលផ្ទះក៏អត់មានដែរ...

**អ.ផ.ល ៖** ទាំងអស់នេះជាបញ្ហាធំណាស់ ប៉ុន្តែខ្ញុំស្គាល់មនុស្សម្នាក់ដែលមានចម្លើយសម្រាប់បញ្ហាគ្រប់យ៉ាងក្នុងជីវិត។ តើបងធ្លាប់ទទួលព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់បងដែរឬទេ?

**ម.ផ៖** (និយាយខ្សោយៗ) ក្រុមគ្រួសារ និងមិត្តភក្តិសុទ្ធតែបោះបង់ខ្ញុំចោលទាំងអស់ ហើយពេលខ្ញុំឈឺហើយក៏បានបាត់បង់ការងារ... តើមាននរណាពីក្រុមជំនុំអ្នកអាចជួយខ្ញុំបានទេ? សូមអង្វរ?...

**អ.ផ.ណ៖** អ្វីដែលអាចជួយអ្នកបានគឺមាននៅក្នុងខិតប័ណ្ណតូចនេះ។ នៅក្នុងនេះពន្យល់បងអំពីគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់បង។ បងដឹងទេថា ព្រះជាម្ចាស់ពុំមានបំណងឲ្យបងដេកឈឺអញ្ចឹងទេ។ សូមយកខិតប័ណ្ណនេះទៅអាន រួចអធិស្ឋានក្នុងនាមជាអ្នកមានបាប ហើយទទួលជឿលើព្រះអង្គទៅ។

**ម.ផ៖** (កាន់តែខ្សោយទៅៗ) ធ្វើអត់កើតទេ... អត់កម្លាំងទេ ខ្សោយណាស់... ( ស្រាប់ តែស្ងាត់មាត់ឈឹង ប្រាស់ដេកស្ងៀមឥតកម្រើកសោះ)

**អ.ផ.ណ៖** (ពិនិត្យមើលជីពចរ) អូហ៎ នៅរស់តើ! អរគុណព្រះជាម្ចាស់ ដែលខ្ញុំមកធ្វើជាទីបន្ទាល់ទាន់ពេល! អញ្ចឹងខ្ញុំទុកខិតប័ណ្ណនៅហ្នឹងណ៎ា ព្រោះខ្ញុំត្រូវបន្តទៅធ្វើកិច្ចការ ខាងមុខទៀតជាមួយអ្នកមិនទាន់ជឿ។ (និយាយឲ្យខ្លាំងៗដាក់ត្រចៀកអ្នកជម្ងឺ) យើងនឹងអធិស្ឋានឲ្យបង។ ចូរចងចាំថាមានតែព្រះយេស៊ូទេជាចម្លើយចំពោះបញ្ហានេះ (ដើរចេញ)

**ម.ផ៖** (តាមមើលគាត់ដើរចេញទាំងថ្ងូរ) អូយ....... (មិនបាច់ធ្វើអ្វីទៀតនោះទេ ឬធ្វើក៏បានឲ្យតែសមរម្យ)

**ចូរពិភាក្សាក្នុងក្រុមធំ នូវសំណួរដូចខាងក្រោម៖**

- តើមានរឿងអ្វីកើតឡើងនៅក្នុងការសម្ដែងនេះ?
- តើអ្នកធ្លាប់បានជួប ឬស្គាល់អ្នកដើរចែកចាយដំណឹងល្អប្រភេទនេះដែរឬទេ?
- តើការចែកចាយបែបនេះទទួលបានជោគជ័យបែបណាក្នុងរយៈពេលវែង?
- បើប្រៀបធៀបទៅនឹងរបៀបផ្សាយដំណឹងល្អរបស់ព្រះយេស៊ូ តើវិធីសាស្ត្រចែកចាយបែបនេះមានលក្ខណៈយ៉ាងណាដែរ?

ព្រះគម្ពីរបានចែងយ៉ាងច្បាស់ណាស់ថា ព្រះជាម្ចាស់មិនចង់ឲ្យមនុស្សណាម្នាក់រងការឈឺចាប់នោះទេ ហើយយើងក៏ត្រូវធ្វើដូចព្រះអង្គដែរ។ «គន្លឹះ» ល្អបំផុតដើម្បីជួយឲ្យយើងយល់កាន់តែ យល់ច្បាស់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់មនុស្ស គឺមានចែងនៅក្នុងក្រឹត្យវិន័យរបស់ព្រះយេស៊ូ។ នៅក្នុងក្រឹត្យវិន័យទាំងនេះ យើងឃើញពី «ការបង្រួមអត្ថន័យ» នៃដំណឹងល្អ។ ចំណុចចម្បងមិនសូវច្បាស់នោះទេ ប៉ុន្តែវាគួរឲ្យភ្ញាក់ផ្អើល។

## ក្រឹត្យវិន័យដ៏សំខាន់

**នៅក្នុងក្រុមតូចៈ**

ចូរអានខគម្ពីរដូចខាងក្រោមៈ

- *ម៉ាថាយ ២២ៈ៣៦-៤០*
- *ម៉ាកុស ១២ៈ២៨-៣១, ៣៣*
- *លូកា១០ៈ២៧*
- *ម៉ាថាយ ៧ៈ១២*
- *រ៉ូម ១៣ៈ៩*
- *កាឡាទី ៥ៈ១៤*

តើមានអ្វីខ្លះដូចគ្នា និងខុសគ្នានៅក្នុងអត្ថបទគម្ពីរទាំង៦នេះ?

- អត្ថបទគម្ពីរទាំងនេះសុទ្ធតែចែងថា «ត្រូវស្រលាញ់អ្នកជិតខាងរបស់អ្នក»
- ត្រឹមតែពាក់កណ្ដាលប៉ុណ្ណោះ ដែលនិយាយអំពីការស្រលាញ់ព្រះជាម្ចាស់

ក្នុងចំណោមក្រឹត្យវិន័យទាំងពីរ តើព្រះយេស៊ូមានព្រះបន្ទូលថា វិន័យមួយណាធំជាង?

- ត្រូវស្រលាញ់ព្រះជាម្ចាស់

នៅពេលក្រឹត្យវិន័យ និងពាក្យដែលថ្លែងដោយព្យាការីត្រូវបានបង្រួមទៅជាក្រឹត្យវិន័យមួយដ៏សំខាន់ តើមួយណាជាក្រឹត្យវិន័យដែលសំខាន់ជាងគេ?

- ត្រូវស្រលាញ់អ្នកជិតខាងរបស់អ្នក

តើអ្នកគិតថា ហេតុអ្វីបានជាព្រះយេស៊ូបង្រួមក្រឹត្យវិន័យ និងពាក្យរបស់ព្យាការីដោយប្រើក្រឹត្យវិន័យមួយនេះ?

- *(ទុកឲ្យសិស្សគិតរកចម្លើយដោយខ្លួនឯង។ ប្រសិនបើសិស្សមិនអាចធ្វើការសន្និដ្ឋានបានទេ ចម្លើយគឺព្រះយេស៊ូធ្វើដូច្នេះ ដើម្បីឲ្យយើងអាចសម្ដែងក្ដីស្រលាញ់របស់យើងដល់ព្រះជាម្ចាស់តាមរយៈសកម្មភាពរបស់យើង រួចបកទៅសំណួរនេះវិញ នៅចុងបញ្ចប់នៃមេរៀននេះ។)*

## ត្រូវស្រលាញ់អ្នកជិតខាងរបស់អ្នក

**នៅក្នុងក្រុមធំ**

ចូរអាន ១យ៉ូហាន ៣ៈ១៧, ១ យ៉ូហាន ៥ៈ៣, យ៉ាកុប ១ៈ២៧)

យើងអាចយកក្ដីស្រលាញ់របស់ព្រះជាម្ចាស់ទៅឆ្លើយតបនឹងតម្រូវការរបស់អ្នកដទៃដោយរបៀបណា?

- ប្រសិនបើយើងស្រលាញ់ព្រះជាម្ចាស់មែននោះ វាស្ដែងឲ្យឃើញតាមរយៈការស្រលាញ់អ្នកដទៃ។ ប្រសិនបើយើងពោលថា យើងស្រលាញ់ព្រះជាម្ចាស់ តែយើងមិនស្រលាញ់អ្នកជិតខាងសោះ នោះបញ្ជាក់ឲ្យឃើញថាយើងមិនបានស្រលាញ់ព្រះជាម្ចាស់ពិតប្រាកដទេ។

បើយើងមិនជួយអ្នកដទៃ តើយើងអាចចែកចាយក្ដីស្រលាញ់ព្រះជាម្ចាស់បានដែរឬទេ?

- ទេ គឺមិនអាចនោះទេ។

តើយើងជាសាវ័ករបស់ព្រះយេស៊ូដែរឬទេ បើយើងមិនបម្រើដល់តម្រូវការរបស់មនុស្សខាងផ្នែកសង្គម រូបកាយ និងវិញ្ញាណ?

- ទេ។ ប្រសិនបើយើងក្រឡេកមើលប្រស្នាអំពីសត្វចៀម និងសត្វពពែ នោះយើងឃើញថា យើងត្រូវបានញែកចេញពីគ្នាតាមរយៈទង្វើរបស់យើង។ នៅក្នុងប្រស្នានេះ ព្រះយេស៊ូមិនបង្គាប់ឲ្យសាវ័កទ្រង់អធិប្បាយដល់អស់អ្នកដែលស្រេកឃ្លានទេ។ ប៉ុន្តែ ព្រះអង្គឲ្យគេផ្ដល់អាហារវិញ។ នៅក្នុងប្រស្នានេះ ព្រះយេស៊ូបានបង្ហាញយ៉ាងច្បាស់ថា ព្រះអង្គរំពឹងឲ្យយើងយកចិត្តទុកដាក់ពីតម្រូវការអស់អ្នកដែលនៅជុំវិញខ្លួនយើង បើយើងពិតជាអ្នកដើរតាមព្រះអង្គដ៏ពិតប្រាកដមែននោះ។

## ឈើឆ្កាង




ចូរគូររូបឈើឆ្កាងលើក្ដាខៀនដើម្បីទុកបង្ហាញ។

រួចពន្យល់ដល់ក្រុម៖

រូបនេះរចនាឡើងដើម្បីជួយឲ្យយើងចាំនូវគោលការណ៍នេះ។ បន្ទាត់ត្រង់បញ្ឈរ តំណាងឲ្យទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់។ វាជាបន្ទាត់ធំជាងគេ។ រីឯបន្ទាត់ដេកតំណាងឲ្យទំនាក់ទំនងយើងជាមួយអ្នកដទៃ។ ហើយបន្ទាត់នេះទ្រ ដោយបន្ទាត់ឈរ។ បើគ្មានបន្ទាត់ឈរនេះទ្រជាទម្រទេ នោះបន្ទាត់ដេកនឹងត្រូវធ្លាក់មកដី។ នេះជាការពិត មិនសម្រាប់តែរូបភាពនេះទេ តែវាជាការពិតសម្រាប់ជីវិតយើងដែរ។ យើងត្រូវការព្រះជាម្ចាស់ជួយយើងឲ្យមានទំនាក់ទំនងល្អជាមួយអ្នកដទៃ។

## តើអ្នកជិតខាងយើងជានរណា?

សេចក្ដីផ្ដើម៖ នេះជារឿងមួយដែលព្រះយេស៊ូប្រាប់មនុស្សម្នាក់ដែលចង់បានជីវិតអស់កល្បជានិច្ច ដែលជីវិតនេះទទួលបានគឺទាល់តែក្លាយជាគ្រិស្តបរិស័ទ។ ទ្រង់មានព្រះបន្ទូលពីពីរចំណុចដែលគេត្រូវការនោះគឺត្រូវស្រលាញ់ព្រះជាម្ចាស់ និងត្រូវស្រលាញ់អ្នកជិតខាងរបស់អ្នក។ ក្រោយមកបុរសនោះសួរព្រះ

យេស៊ូថា  តើនរណាជាអ្នកជិតខាងរបស់គាត់ ហើយព្រះអង្គមានបន្ទូលតបវិញតាមរយៈរឿងដូចខាងក្រោម។

ចូរអានរឿងអំពីអ្នកស្រុកសាម៉ារីម្នាក់ដែលមានចិត្តសប្បុរស (លូកា ១០៖៣០-៣៧) នៅខណៈដែលសិស្សក្នុងថ្នាក់ឡើងសម្តែង។ ចូរឲ្យសិស្សដើរសម្តែងធ្វើតួអង្គម្នាក់ៗនៅក្នុងរឿង។
*(យើងត្រូវការមនុស្សប្រាំពីរនាក់ដើម្បីជួយសម្តែងនៅក្នុងសាច់រឿងនេះ៖ បុរសម្នាក់, ចោរប្លន់ពីរនាក់, បូជាចារ្យម្នាក់, អ្នកលេវីម្នាក់, សាសន៍សាម៉ារីម្នាក់ និងម្ចាស់ផ្ទះសំណាក់ម្នាក់)*

**ពិភាក្សានៅក្នុងក្រុមធំ**

- តើអ្នកស្រុកសាម៉ារីដែលមានចិត្តសប្បុរស ស្គាល់អ្នកដែលដេកដួលលើដីនោះដែរឬទេ?
- តើអ្នកស្រុកសាម៉ារីនោះមានប្រតិកម្មយ៉ាងដូចម្តេចចំពោះបុរសនោះ? តើទង្វើនោះ ខុសប្លែកពីអ្នកផ្សេងៗទៀតយ៉ាងណាខ្លះ?
- តើអ្នកស្រុកសាម៉ារីដែលមានចិត្តសប្បុរសនោះ បានបង្ហាញក្តីស្រលាញ់យ៉ាងដូចម្តេចចំពោះអ្នកជិតខាងរបស់គាត់? តើវាគ្រាន់តែសមល្មម ឬលើសពីអ្វីដែលចាំបាច់?
- តើរឿងនេះបានបង្រៀនយើងដូចម្តេចខ្លះ ថានរណាជាអ្នកជិតខាងយើង?
- តើរឿងនេះបានបង្រៀនយើងឲ្យចេះបង្ហាញក្តីស្រលាញ់ដល់អ្នកជិតខាងយើងដោយរបៀបណា?

## អនុវត្តន៍

ចូរគិតពីមនុស្សដែលអ្នកជួបជារឿយៗ។ តើមានរឿងណាមួយដែលអ្នកអាចធ្វើដើម្បីគេដែរឬទេ?

# មេរៀនទី៤
# លូកា ២៖៥២

**គោលបំណង**

១. យល់ពីផ្នែកទាំងបួនដែលយើងត្រូវរីកចម្រើនដូចជា រូបកាយ វិញ្ញាណ សង្គម និងសតិបញ្ញា

២. ឲ្យសិស្សដឹងថា មិនមែនទាល់តែមានលុយទើបអាចសម្រេចនូវអ្វីដែលព្រះមានសម្រាប់យើងនោះទេ

៣. គិតពីរបៀបជួយអ្នកដទៃឲ្យរីកចម្រើនលើផ្នែកទាំងបួនដែរ

៤. អនុវត្តន៍៖ ចេះបង្កើតគម្រោងជួយខ្លួនឯង និងសហគមន៍របស់គេ ព្រមទាំងមនុស្សនៅក្នុងក្រុមជំនុំជាមួយគ្នាឲ្យបានរីកចម្រើនលើផ្នែកទាំងបួន



## សេចក្តីផ្តើម

**ចូរពិភាក្សាគ្នាជាក្រុមធំ**

- តើក្មេងមានអាយុចន្លោះពី០ទៅ១៨ឆ្នាំ ត្រូវការរីកចម្រើនលើផ្នែកអ្វីខ្លះ?

ចូរសរសេរ ឬគូររូបភាពជាចម្លើយនៅលើក្រដាស។ ប្រសិនបើសិស្សឆ្លើយមិនបានគ្រប់ចំណុច (មើលតាមសំណួរខាងក្រោម) ចូរជំរុញឲ្យពួកគេគិតបន្ថែមទៀត។ ឧទាហរណ៍ តើអ្នកគិតថាមនុស្សស្ថិតនៅក្នុងវ័យនេះត្រូវការឲ្យគ្រួសារ ឬនរណាម្នាក់ស្រលាញ់គេដែរឬទេ?

## លូកា ២៖៥២

លូកា ២៖៥២ ៖ «ព្រះយេស៊ូមានវ័យចម្រើនឡើង ហើយមានប្រាជ្ញាកាន់តែវាងវៃជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាទីគាប់ចិត្តមនុស្សទាំងពួង»។

១. តើព្រះយេស៊ូបានចម្រើនឡើងលើផ្នែកទាំងបួនរួមមានអ្វីខ្លះ? តើពាក្យអ្វីខ្លះដែលប្រើសម្រាប់បរិយាយពីការរីកចម្រើននៃផ្នែកទាំងបួននេះ?

- មានប្រាជ្ញា <u>ផ្នែកប្រាជ្ញា</u>
- មានវ័យចម្រើនឡើង <u>ផ្នែករូបកាយ</u>
- ជាទីគាប់ព្រះទ័យរបស់ព្រះជាម្ចាស់ <u>ផ្នែកវិញ្ញាណ</u>

- ជាទីគាប់ចិត្តរបស់មនុស្សទាំងពួង  ផ្នែកសង្គម

ចូរយកកាតពីសេចក្តីផ្តើមមកប្រើ ហើយបង្ហាញសិស្សឲ្យឃើញថា ចម្លើយរបស់គេស៊ីគ្នាឬអត់ បើធៀបទៅនឹងចំណុចដែលបានរៀបរាប់ខាងលើ។ ចូរពន្យល់ថា ព្រះយេស៊ូត្រូវការរីកចម្រើនធំធាត់លើផ្នែកទាំងបួននេះយ៉ាងណា យើងក៏ត្រូវការរីកចម្រើនយ៉ាងនោះដែរ។ យើងអាចប្រើលំនាំនេះជាគំរូដើម្បីយល់ពីការរីកលូតលាស់របស់មនុស្ស។

## ការរីកចម្រើនរបស់ព្រះយេស៊ូ

ចូរឆ្លើយសំណួរខាងក្រោមនៅក្នុងក្រុមតូចៈ

១. តើការរីកចម្រើនរបស់ព្រះយេស៊ូកើតឡើងភ្លាមៗ ឬត្រូវការពេលវេលា?

- ការរីកចម្រើនរបស់ព្រះយេស៊ូត្រូវការពេលវេលា

២. តើព្រះយេស៊ូចម្រើនវ័យឡើងក្នុងលក្ខខណ្ឌជីវភាពរស់នៅបែបណា? (តើព្រះអង្គបានទៅរៀននៅសាកលវិទ្យាល័យដែរឬទេ?  តើនៅផ្ទះរបស់ព្រះអង្គមានអគ្គិសនីប្រើដែរឬទេ? តើព្រះអង្គមានអាហារបរិភោគគ្រប់គ្រាន់ដែរឬទេ? តើព្រះអង្គចេះអាន និងចេះសរសេរអក្សរដែរឬទេ? តើទ្រង់មានឳពុកម្តាយដែលផ្តល់នូវក្តីស្រលាញ់ដែរឬទេ?)

- ព្រះយេស៊ូធំធាត់ឡើងក្នុងគ្រួសារក្រីក្រមួយ។ គ្រួសាររបស់ព្រះអង្គគ្មានអ្វីសម្រាប់ថ្វាយជាតង្វាយទេ គឺមានតែព្រាបពីរក្បាលប៉ុណ្ណោះ (សូមមើល លូកា ២៖២៤ និងលេវីវិន័យ ១២៖៨)
- ទោះជាយ៉ាងនេះក្តី ក៏ព្រះអង្គនៅមានអាហារហូបគ្រប់គ្រាន់។ ឳពុករបស់ទ្រង់ មានការងារធ្វើ ហើយព្រះអង្គមានគ្រួសារដែលផ្តល់នូវក្តីស្រលាញ់ ។

៣. តើព្រះយេស៊ូមានធនធានគ្រប់គ្រាន់ចាំបាច់ ដើម្បីបំពេញគោលបំណងរបស់ព្រះជាម្ចាស់ដែរឬទេ? បើមាន តើហេតុអ្វី? ចុះបើមិនមានវិញ តើហេតុអ្វីដែរ?

- យ៉ូហាន ១៧៖៤ ប្រាប់យើងគ្រប់យ៉ាងពីកិច្ចការដែលព្រះជាម្ចាស់បានប្រទានមកឲ្យទ្រង់ធ្វើដែលព្រះយេស៊ូបានសម្រេច។ ទ្រង់អាចសម្រេចបាននូវគោលបំណងរបស់ព្រះជាម្ចាស់។

៤. តើព្រះយេស៊ូត្រូវមានទ្រព្យសម្បត្តិប៉ុន្មាន ដើម្បីអាចសម្រេចតាមបំណងរបស់ព្រះជាម្ចាស់?

- ព្រះយេស៊ូក្រីក្រ តែព្រះអង្គអាចសម្រេចគ្រប់កិច្ចការស្របតាមព្រះទ័យព្រះជាម្ចាស់សម្រាប់ជីវិតរបស់ទ្រង់។

៥. ព្រះយេស៊ូបានរីកចម្រើនឡើងលើផ្នែកទាំងបួន។ តើយើងអាចជួយអ្នកដទៃឲ្យរីកចម្រើនលើផ្នែកទាំងបួននោះបានដែរឬទេ? តើជួយដោយរបៀបណា?

- អាចជួយបាន ដ្បិតផ្នែកទាំងបួននេះផ្តល់ជាគំរូដល់យើងក្នុងការជួយដល់អ្នកដទៃ។

៦. សូម្បីតែព្រះយេស៊ូក៏ត្រូវការពេលវេលាជាច្រើនឆ្នាំដើម្បីរីកចម្រើនដែរ ចុះទម្រាំតែអ្នកដទៃវិញ តើគេត្រូវការពេលប៉ុន្មានដើម្បីរីកចម្រើន?

- យើងត្រូវការពេលវេលាដើម្បីឲ្យមនុស្សមានការរីកចម្រើន។ ប្រសិនបើយើងចង់ជួយពួកគេនោះ យើងត្រូវតែសុខចិត្តលះបង់ពេលវេលាជាច្រើនឆ្នាំ។

## អនុវត្តន៍លើជីវិតរបស់យើងផ្ទាល់

យើងមិនគ្រាន់តែត្រូវរីកចម្រើនលើផ្នែកទាំងបួនដូចព្រះយេស៊ូទេ ប៉ុន្តែយើងក៏ត្រូវជួយអ្នកដទៃឲ្យរីកចម្រើនលើផ្នែកទាំងនោះដែរ។ តារាងបំពេញខាងក្រោមនេះ ឲ្យជាឧទាហរណ៍ពីរបៀបដែលអ្នកអាចរីកចម្រើននៅក្នុងផ្នែកទាំងនេះ និងលើកទឹកចិត្តដល់ក្រុមគ្រួសារ ក្រុមជំនុំ និងសហគមន៍ឲ្យរីកចម្រើនលើផ្នែកទាំងនេះដែរ។

***ចំណាំក្នុងការបង្រៀន៖*** *ប្រសិនបើអ្នកមិនបានថតចម្លងតារាងនោះទេ អ្នកអាចគូសតារាងនៅលើក្ដារខៀន ហើយសិស្សអាចគូរវាដាក់នៅលើក្រដាសរបស់ពួកគេ។*

**ចំណាំ**

- ជ្រើសរើសអ្វីដែលយើងអាចធ្វើបាននៅក្នុងមួយសប្ដាហ៍។ ប្រសិនបើយើងជ្រើសអ្វីមួយដែលធំពេក វានឹងពិបាកដើម្បីទទួលបានលទ្ធផល ហើយងាយនឹងបាក់ទឹកចិត្ត។ ចូរជ្រើសរើសអ្វីដែលតូច ដើម្បីឲ្យអ្នកអាចទទួលបានជោគជ័យ ហើយជ្រើសរើសអ្វីមួយធ្វើបន្ទាប់ទៀត។
- ជ្រើសរើសអ្វីដែលអ្នកមិនទាន់បានធ្វើ។

**ក្រុមដែលមិនសូវចេះអក្សរ៖* ប្រសិនបើវាពិបាកនៅក្នុងក្រុមដើម្បីបំពេញតារាងនោះ គឺគ្រាន់តែពិភាក្សា៖

- ចូរគិតអំពីគ្រួសាររបស់អ្នកផ្ទាល់។ តើពួកគេកំពុងរីកចម្រើនលើផ្នែកទាំងបួននេះដែរឬទេ? តើមានកិច្ចការណាមួយដែលអ្នកអាចធ្វើ ដើម្បីឲ្យក្រុមគ្រួសារ ឬសមាជិកណាម្នាក់រីកចម្រើនលើផ្នែកណាមួយនៃផ្នែកទាំងបួននោះ?
- ចូរគិតអំពីក្រុមជំនុំរបស់អ្នក។ តើមាននរណាម្នាក់នៅក្នុងក្រុមជំនុំដែលអ្នកអាចជួយឲ្យគេរីកចម្រើនលើផ្នែកណាមួយក្នុងចំណោមផ្នែកទាំងបួននេះដែរឬទេ? តើអ្នកអាចធ្វើអ្វីបានខ្លះ?
- ចូរគិតពីសហគមន៍របស់អ្នក។ តើមាននរណាម្នាក់នៅក្នុងសហគមន៍របស់អ្នក ដែលអ្នកអាចជួយឲ្យគេរីកចម្រើនលើផ្នែកណាមួយនៃផ្នែកទាំងបួននេះដែរឬទេ? តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីជួយគេ?

| បរិបទ | ផ្នែកនៃការរីកចម្រើនរបស់ព្រះយេស៊ូ | | | |
|---|---|---|---|---|
| សម្រាប់ការរីកចម្រើន | ប្រាជ្ញា | រូបកាយ | ព្រលឹងវិញ្ញាណ | សង្គម |

| | | | | |
|---|---|---|---|---|
|  ផ្ទាល់ខ្លួន | អានសៀវភៅ ឬ អត្ថបទទាក់ទងនឹងចំណុចដែលខ្ញុំចង់រីកចម្រើន | ដើរហាត់ប្រាណ | ឈប់សម្រាកពេលកន្លះថ្ងៃ ដើម្បីយកពេលអធិស្ឋាន | ផ្ញើពាក្យលើកទឹកចិត្តដល់មិត្តភក្តិ |
|  គ្រួសារ | ពិភាក្សាពីការអនុវត្តខគម្ពីរពីរខជាមួយគ្រួសារ | លាងចានបន្ទាប់ពីញ៉ាំអាហាររួច | ដឹកនាំគ្រួសារចំណាយពេលជាមួយព្រះជាម្ចាស់ប្រចាំថ្ងៃ | នាំប្ដី ឬប្រពន្ធដើរលេង (ដោយមិនយកកូនទៅជាមួយ) |
|  ក្រុមជំនុំ | ចំណាយពេលជាមួយព្រះជាម្ចាស់រាល់ថ្ងៃច័ន្ទ ដោយអនុវត្តពីការអធិប្បាយថ្ងៃអាទិត្យ | ជួសជុលផ្លូវដើរចូលមុខក្រុមជំនុំ | អធិស្ឋានជាប្រចាំឲ្យគ្រូគង្វាល និងចាស់ទុំក្នុងក្រុមជំនុំ | អញ្ជើញសមាជិកផ្សេងៗគ្នាពីក្រុមជំនុំឲ្យមកពិសាអាហារតែនៅផ្ទះ |
|  សហគមន៍ | ពិភាក្សាពីបញ្ហានៅក្នុងសហគមន៍ជាមួយមេដឹកនាំ (មេភូមិ) សហគមន៍ | រើសសំរាមនៅជុំវិញផ្ទះរបស់អ្នកជិតខាង | អញ្ជើញញាតិជិតខាងឲ្យចូលរួមពិធីបុណ្យណូអែលនៅផ្ទះរបស់អ្នក | លេងបាល់ទាត់ជាមួយកូនៗអ្នកជិតខាងរបស់អ្នក |

*ចូរទុកពេលឲ្យសិស្សគិតឲ្យបានគ្រប់គ្រាន់។ វាសំខាន់ណាស់ដែលពួកគេមានពេលប្រមូលយកគំនិតល្អៗ ជាជាងឲ្យគេប្រញាប់ប្រញាល់ធ្វើ ហើយយកតែគំនិតដំបូងៗដែលពួកគេមាន។*

ពេលគេគិតរួចចប់សព្វគ្រប់ហើយ ចូររកអ្នកស្ម័គ្រចិត្តឲ្យចែកចាយគំនិតរបស់គេជាមួយសិស្សរួមថ្នាក់។ (ប្រសិនបើមិនមានពេលគ្រប់គ្រាន់សម្រាប់សិស្សគ្រប់គ្នា សូមលើកទឹកចិត្តសិស្សឲ្យយកវាទៅផ្ទះ ហើយបន្តធ្វើការលើវា)

នៅក្នុងក្រុមដែលមានគ្នា ២ឬ៣នាក់ (មិនឲ្យលើសពី៣) សូមចែកចាយពីអ្វីមួយដែលអ្នកប្ដេជ្ញានឹងធ្វើ។ ចូរអធិស្ឋានឲ្យគ្នាទៅវិញទៅមកថា ព្រះជាម្ចាស់នឹងប្រទានឲ្យអ្នកនូវសមត្ថភាព ដើម្បីបំពេញការប្ដេជ្ញារបស់អ្នក។

## មេរៀនទី៥

# ព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំជួយដល់សហគមន៍

**គោលបំណង៖**

១. យល់ថា ទ្រង់ត្រាស់ហៅឲ្យយើងបម្រើជាមួយសកម្មភាព ក៏ដូចជាពាក្យសំដីដែរ។

២. យល់ថា នៅពេលដែលពួកគេបង្ហាញសេចក្ដីស្រលាញ់ជាមួយសកម្មភាព មនុស្សនៅក្នុងសហគមន៍នឹងត្រូវបានទាក់ទាញមកក្រុមជំនុំ

៣. សម្គាល់ពីរបៀបដែលក្រុមជំនុំរបស់គេអាចចាប់ផ្ដើមបង្ហាញសេចក្ដីស្រលាញ់របស់ព្រះ

## សេចក្ដីផ្ដើម

**ចូរធ្វើការជាក្រុមដែលមានគ្នា៤នាក់**

សូមធ្វើតារាងរៀបរាប់ពីសកម្មភាពទាំងអស់ដែលក្រុមជំនុំរបស់អ្នកធ្វើ (បើចាំបាច់ ចូរគូររូបតំណាងសកម្មភាពនីមួយៗ)។

នៅពេលដែលរួចរាល់ ចូរឲ្យក្រុមនីមួយៗពិនិត្យមើលតារាង រួចឲ្យពួកគេកត់ចំណាំថា តើសកម្មភាពណាសម្រាប់អ្នកចូលរួមនៅក្នុងក្រុមជំនុំ និងសកម្មភាពណា សម្រាប់អ្នកដែលមិនចូលរួមនៅក្នុងក្រុមជំនុំ។ តើសកម្មភាពណាខ្លះដែលផ្ដោតទៅលើអ្នកក្រីក្រ និងអ្នកដែលមានជីវភាពខ្វះខាត?

**ចូរពិភាក្សាគ្នាដោយសង្ខេបៗនៅក្នុងក្រុមធំ៖**

១. តើមនុស្សនៅក្នុងសហគមន៍គិតយ៉ាងដូចម្ដេចចំពោះក្រុមជំនុំ?

២. តើមនុស្សនៅក្នុងសហគមន៍គិតយ៉ាងដូចម្ដេចចំពោះសកម្មភាពក្រុមជំនុំរបស់អ្នក?

៣. តើមនុស្សនៅក្នុងសហគមន៍គិតយ៉ាងដូចម្ដេចចំពោះគ្រិស្តបរិស័ទ?

៤. តើមនុស្សនៅក្នុងសហគមន៍ចង់មកក្រុមជំនុំដោយខ្លួនឯង ឬទាល់តែអ្នកទៅអញ្ជើញគេ?

៥. តើអ្នកគិតថាមនុស្សនៅក្នុងសហគមន៍នឹងមានអារម្មណ៍ដូចម្ដេច ប្រសិនបើក្រុមជំនុំលែងនៅទីនោះ?

៦. បើដូច្នេះមែន តើអ្នកគិតថាធ្វើឲ្យព្រះជាម្ចាស់សប្បាយព្រះទ័យដែរឬទេ?

## ចូរអាន អេសាយ ៥៨

ចូរពន្យល់ថា ព្យាការីអេសាយបានសរសេរសេចក្តីនេះទៅកាន់ជនជាតិអ៊ីស្រាអែល ជាជាតិសាសន៍ដែលព្រះជាម្ចាស់បានជ្រើសរើស។ ពួកគេគឺជាគំរូសម្រាប់ក្រុមជំនុំសព្វថ្ងៃនេះ។

ចូរអាន អេសាយ ៥៨៖១-១០ រួចពិភាក្សា៖

ក. តើមនុស្សទាំងនោះកំពុងតែធ្វើអ្វី?

ខ. តើព្រះជាម្ចាស់មានប្រតិកម្មយ៉ាងដូចម្តេចចំពោះមនុស្សទាំងអស់នោះ?

គ. ហេតុអ្វីបានជាព្រះជាម្ចាស់មានប្រតិកម្មបែបនេះ?

*ចូរបែងចែកជាក្រុមមានគ្នា៤ ឬ៥ នាក់ ។* ចូរឲ្យក្រុមនីមួយៗធ្វើការសង្ខេបអត្ថបទនេះដោយឲ្យគេគូរជារូបភាពក៏បាន ឬសរសេរជាប្រយោគក៏បាន។

បន្ទាប់ពីក្រុមនីមួយៗបកស្រាយប្រយោគ ឬរូបភាពរបស់គេហើយ សួរពួកគេថា តើគំនិតទាំងអស់នេះមានអត្ថន័យយ៉ាងណាចំពោះក្រុមជំនុំសព្វថ្ងៃនេះ។

## អំបិល និងពន្លឺ

**ធ្វើជាក្រុមតូចក៏បាន ក្រុមធំក៏បាន**

ចូរអាន ម៉ាថាយ ៥៖១៣

- ហេតុអ្វីបានជាព្រះយេស៊ូមានព្រះបន្ទូលថាគ្រិស្តបរិស័ទប្រៀបដូចជា «អំបិលនៃផែនដី»?
- តើយើងអាចមានលក្ខណៈដូចជា «អំបិល» ដោយរបៀបណា?
- តើយើងអាចបាត់បង់ «ភាពប្រៃ» របស់យើងដោយរបៀបណាខ្លះ?

ចូរអាន ម៉ាថាយ ៥៖១៤-១៦

- តើមានពេលខ្លះយើងព្យាយាមបិទបាំង «ពន្លឺ» ដែរឬទេ?
- តើយើងអាចមានពន្លឺកាន់តែចែងចាំងដោយរបៀបណា?

**ដំណើររឿងអំពីការធ្វើជាអំបិល និងពន្លឺ**

**រឿងទី១៖ ការចែកសារី (រ៉ូបរបស់ជនជាតិឥណ្ឌា) ជូនស្ត្រីក្រីក្រ**

សមាជិកនៅក្នុងក្រុមជំនុំនេះ ចាត់ទុកខ្លួនគេថាជាប្រជាជនមួយចំនួនតូចដែលជឿលើសាសនាដែលគេបៀតបៀន។ ពួកគេមានការភ័យខ្លាចក្នុងការធ្វើព័ន្ធកិច្ចក្រៅពីសហគមន៍គ្រិស្តបរិស័ទ។ ក្រោយពេល

ស្តាប់ការបង្រៀនពីការសម្តែងក្តីស្រលាញ់របស់ព្រះគ្រិស្តដល់សហគមន៍ទាំងមូល លោកគ្រូគង្វាលបាន លើកទឹកចិត្តឲ្យនារីនៅក្នុងក្រុមជំនុំធ្វើការស៊ើបអង្កេតពីតម្រូវការរបស់សហគមន៍នៅសប្តាហ៍ក្រោយ។

ពេលប្រជុំគ្នាអាទិត្យក្រោយ ពួកនារីៗឡើងរាយការណ៍ថាមានស្ត្រីខាងសាសនាហិណ្ឌូចំនួន១២នាក់ពុំ មានសារី (រ៉ូបរបស់ជនជាតិឥណ្ឌា) ស្លៀកគ្រប់គ្រាន់ទេ គឺម្នាក់មានតែមួយប៉ុណ្ណោះ។ ពេលរដូវក្តៅម្តងៗ គេត្រូវបោកសារីនោះជាប្រចាំថ្ងៃ ។ សម្រាប់ស្ត្រីដែលមានសារីតែមួយ ពួកនាងត្រូវរង់ចាំនៅខាងក្នុងផ្ទះ រហូតទាល់តែសារីដែលត្រូវបានបោកសម្អាតនោះស្ងួត ទើបចេញក្រៅបាន។ គ្រូគង្វាលបានសួរស្ត្រីនៅ ក្នុងក្រុមជំនុំថា តើនរណាមានសារីបី ហើយស្ម័គ្រចិត្តបរិច្ចាគសារីមួយឲ្យស្ត្រីសាសនាហិណ្ឌូទាំងនោះ។ មានស្ត្រីជាច្រើនបានស្ម័គ្រចិត្តឆ្លើយតបទៅនឹងសេចក្តីត្រូវការនេះ។ នៅសប្តាហ៍បន្ទាប់ នារីៗទាំងនោះ បាននាំគ្នាទៅលេងផ្ទះស្ត្រីខាងសាសនាហិណ្ឌូដែលមានសារីតែមួយនោះ ហើយបានជូនសារីមួយទៀត ដល់ពួកគេ។ នារីៗខាងសាសនាហិណ្ឌូ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះទង្វើនេះ ហើយពួកគេបានសុំ ឲ្យនារីៗខាងគ្រិស្តសាសនា អធិស្ឋានឲ្យពួកគេថែមទៀតផង។ លើសពីនេះទៅទៀតនារីៗខាងសាសនា ហិណ្ឌូដែលមានផ្ទៃពោះក៏សុំឲ្យគេអធិស្ឋានឲ្យកូននៅក្នុងផ្ទៃរបស់គេផងដែរ។

**ដំណើររឿងទី២៖ ទឹកស្អាតសម្រាប់សហគមន៍**



មានប្រជាជននៅក្នុងតំបន់មួយកន្លែងកំពុងជួបប្រទះ បញ្ហាកង្វះទឹកប្រើប្រាស់។ បន្ទាប់ពីរៀនអំពីបំណងព្រះ ហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការឈោងចាប់ដល់ សហគមន៍ អ្នកដឹកនាំក្រុមជំនុំបានសម្រេចចិត្តរិះរកវិធី ដើម្បីជួយដោះស្រាយលើតម្រូវការទឹកនេះ។ ជាលទ្ធ ផល ពួកគេបានរកឃើញកន្លែងមួយដែល អាចជួល ឧបករណ៍ដើម្បីបុកអណ្តូងដោយដៃ។ ជាដំបូងអ្នកស្រុកមិនយល់ស្របនឹងគំនិតនេះទេ ព្រោះគេគិតថាទឹក វានៅជ្រៅពេក។ ម្យ៉ាងទៀតពួកគេក៏និយាយផងដែរថា បើពិតជាអាចបុកអណ្តូងដោយដៃកើតមែននោះ ហេតុអ្វីក៏មិនបុកតាំងពីមុនមក?

តែទោះជាយ៉ាងនេះក្តី អ្នកដឹកនាំក្រុមជំនុំនៅតែសម្រេចចិត្តសាកល្បង។ ពួកគេបានជួលដែកបំពង់ខ្វង ដែលគិតជាម៉ែត និងម៉ាស៊ីនខា។ ពួកគេបានដឹកសម្ភារៈទាំងនោះមកកាន់សហគមន៍ រួចចាប់ផ្តើមជីក អណ្តូងនៅលើដី បរិវេណខាងក្រោយក្រុមជំនុំ។ នៅពេលគេជីកដល់ជម្រៅ ១៤ ម៉ែត្រស្រាប់តែមានទឹក ចេញមក ហើយធ្វើឲ្យគ្រប់ៗគ្នារីករាយសាទរយ៉ាងខ្លាំង។

ប៉ុន្តែ អ្នកដែលមិនមែនជាសមាជិកក្រុមជំនុំពុំសូវសប្បាយចិត្តទេ។ ពួកគេគិតថាទឹកអណ្តូងនោះគឺទុកប្រើ ប្រាស់សម្រាប់តែសមាជិកក្រុមជំនុំតែប៉ុណ្ណោះ។ តែក្រុមជំនុំមិនបានធ្វើដូច្នេះនោះទេ គឺគេបានអញ្ជើញ សហគមន៍ទាំងមូលដើម្បីទទួលបានព្រះពរពីព្រះជាម្ចាស់ និងជោគជ័យរបស់ពួកគេទាំងអស់គ្នា។ មិន

យូរប៉ុន្មាន អ្នកតំណាងពីសហគមន៍ដាច់ស្រយាលនៅក្បែរនោះបានស្នើសុំឲ្យមេដឹកនាំក្រុមជំនុំជួយជីកអណ្ដូងនៅតំបន់មួយទៀតនៃសហគមន៍របស់គេ។ ក្រុមជំនុំបានទទួលយកសំណើរបស់គេ ហើយរយៈពេលត្រឹមតែជាងមួយឆ្នាំប៉ុណ្ណោះ គេបានជីកអណ្ដូងដោយដៃចំនួន ១៥កន្លែង ហើយនៅក្នុងនោះមានអណ្ដូងមួយកន្លែងមានជម្រៅជាង ២៤ ម៉ែត្រ។

ដោយសារតែក្រុមជំនុំបានបង្ហាញក្ដីស្រលាញ់របស់ព្រះជាម្ចាស់ដល់សហគមន៍តាមរបៀបនេះ ធ្វើឲ្យអ្នកភូមិមានចំណាប់អារម្មណ៍មកលើក្រុមជំនុំយ៉ាងខ្លាំង ហើយនៅពេលក្រុមជំនុំអញ្ជើញពួកគេឲ្យចូលរួមស្ដាប់ដំណឹងល្អពីក្ដីស្រលាញ់របស់ព្រះជាម្ចាស់ម្ដងៗ អ្នកភូមិក៏ចូលរួមយ៉ាងកុះករ។ អ្នកភូមិចាប់ផ្ដើមចង់ដឹងចង់ឮបន្ថែមអំពីព្រះជាម្ចាស់ និងអ្នកដែលបានផ្ដល់ទឹកឲ្យពួកគេ។

**ពិភាក្សា**

- តើពួកជំនុំទាំងនេះបានធ្វើអ្វីខ្លះ?
- តើពួកជំនុំទាំងនោះ ជាអ្នកមានឬ?
- តើពួកគេបានធនធានមកពីណា?
- ហេតុអ្វីបានជាគេធ្វើរឿងរ៉ាវទាំងអស់នេះ?
- តើសកម្មភាពរបស់គេបានជះឥទ្ធិពលអ្វីខ្លះដល់សហគមន៍?

## ប្រស្នាអំពីសត្វចៀម និងសត្វពពែ នៅក្នុងម៉ាថាយ ២៥៖៣១-៤៦

**នៅក្នុងក្រុមធំ**

ចូរអាន ម៉ាថាយ ២៥៖៣១-៤៦

១. តើសត្វចៀម និងសត្វពពែខុសដូចគ្នាដូចម្ដេច?

២. តើសត្វចៀមបានធ្វើសកម្មភាពអ្វីខ្លះ? តើវាជាសកម្មភាពខាងវិញ្ញាណ ឬខាងរូបកាយ?

- *(ត្រូវជួយឲ្យសិស្សឃើញថា ការសង្កត់ន័យសំខាន់នៃអត្ថបទនេះគឺនៅលើផ្នែកខាងរូបកាយ។ ព្រះយេស៊ូមិនបានមានព្រះបន្ទូលថា «ពេលព្រះអង្គឃ្លានអ្នកយកខិតប័ណ្ណផ្សាយ ឬកូនសៀវភៅដំណឹងល្អឲ្យខ្ញុំ» រឺង «ពេលខ្ញុំឈឺ អ្នកផ្ញើរខ្សែអាត់សម្លេងនៃមេរៀនអធិប្បាយមកឲ្យខ្ញុំស្ដាប់» នោះទេ ដ្បិតអ្វី ដែលព្រះអង្គមានព្រះបន្ទូលគឺសំដៅលើដំណោះស្រាយនៃតម្រូវការផ្នែករូបកាយ)*

៣. តើក្រុមជំនុំរបស់អ្នកធ្វើនូវកិច្ចការដូចព្រះបន្ទូលរបស់ព្រះយេស៊ូខាងលើនេះ ញឹកញាប់ប៉ុណ្ណាដែរ?

៤. ប្រសិនបើសមាជិកទាំងអស់ក្នុងក្រុមជំនុំរបស់អ្នកធ្វើនូវរឿងទាំងអស់នេះ តើវានឹងមានឥទ្ធិពលយ៉ាងណាដល់សហគមន៍?

*(ចម្លើយខ្លះដែលអ្នកអាចកើតឡើង)*

- អ្នកភូមិនឹងមានចំណាប់អារម្មណ៍ជាវិជ្ជមានចំពោះក្រុមជំនុំ
- ជីវិតរបស់គេនឹងមានការរីកចម្រើន
- ពួកគេនឹងបើកចិត្តកាន់តែទូលាយដើម្បីរៀនអំពីព្រះជាម្ចាស់។

## អនុវត្តន៍

ចូរចែកសិស្សជាក្រុម រួចឲ្យគេបំពេញតារាងខាងក្រោម។ ចូរពិភាក្សាគំនិតពីរបៀបដែលក្រុមជំនុំអាចជួយដល់ចំណុចដែលបានលើកឡើងនេះ។

| តម្រូវការ | របៀបដែលក្រុមជំនុំអាចជួយបាន |
|---|---|
|  ឃ្លាន | |
|  ស្រេកទឹក | |
|  ខ្វះខាត | |

| | |
|---|---|
| <br>ខ្ទះជំរក | |
| <br>ឈឺ | |
| <br>ជាប់ឃុំឃាំង | |

## មេរៀនទី៦

# តើមានតម្រូវការអ្វីខ្លះ ដែលយើងអាចជួយបាន?

**គោលបំណង**

១. ស្គាល់ពីធនធានមួយចំនួន ដែលមានស្រាប់នៅក្នុងសហគមន៍។

២. គិតពីរបៀបជាក់ស្តែងមួយចំនួនដែលពួកគេអាចជួយបាន ដោយប្រើប្រាស់នូវអ្វីដែលពួកគេមានស្រាប់។

៣. បើកភ្នែកសិស្សឲ្យឃើញពីបញ្ហាផ្សេងៗនៅក្នុងសង្គម។

## និមិត្តរបស់គ្រូគង្វាលវ៉ង់ (Wong)

ចូរអានដំណើររឿងរបស់លោកគ្រូគង្វាល វ៉ង់ នៅក្នុងឧបសម្ព័ន្ធទី១

**ពិភាក្សាគ្នាជាក្រុមតូច**

- តើនៅក្នុងសហគមន៍ លោកគ្រូគង្វាលវ៉ង់ ជួបប្រទះបញ្ហាអ្វីខ្លះ? ចូរបែងចែកបញ្ហាទាំងនេះជាបួនផ្នែកគឺ បញ្ហាទាក់ទងខាងវិញ្ញាណ សង្គម រូបកាយ និងសតិបញ្ញា។
- តើព្រះជាម្ចាស់មានព្រះបំណងដូចម្តេចចំពោះសហគមន៍នេះ? ចូរពិនិត្យមើលបញ្ហានីមួយៗ ហើយក្រឡេកមើលពីដំណោះស្រាយដែលព្រះយេស៊ូបានបង្ហាញ។
- តើព្រះយេស៊ូបានប្រាប់លោកគ្រូគង្វាលវ៉ង់ ឲ្យធ្វើអ្វីខ្លះ?

## ករណីសិក្សា៖ លោកយ៉ូសេ (Jose) និងនាងម៉ារា (Maria)

ចែកសិស្សជាក្រុមតូចៗហើយអានករណីសិក្សាដូចខាងក្រោម។ (សំណួរខ្លះមានចម្លើយជាគំរូស្រាប់)

ផ្ទះរបស់លោកយ៉ូសេ និងនាងម៉ារា ទើបតែត្រូវភ្លើងឆាបឆេះអស់គ្មានសល់អ្វីឡើយ។ កាលពីម្សិលមិញ ពួកគាត់ និងកូនប្រាំនាក់ទៀតបានទៅជ្រកកោននៅក្រោមផ្ទះរបស់សាច់ញាតិ។ ប៉ុន្តែ ផ្ទះនោះតូចចង្អៀតស្រាប់ទៅហើយសម្រាប់គ្រួសារសាច់ញាតិរបស់ពួកគេដែលមានគ្នាដល់ទៅ ១០នាក់  ដូច្នេះគឺគ្មាន

កន្លែងណាសម្រាប់សមាជិក៧នាក់បន្ថែមទៀតនោះទេ។ លោកយ៉ូសេ ជាកសិករ ហើយគាត់បានដកស្ទូងរួចហើយ ប៉ុន្តែគាត់ត្រូវរង់ចាំ៣ខែទៀតទម្រាំដល់ពេលច្រូតកាត់។ គាត់បានចំណាយលុយទាំងអស់លើគ្រាប់ពូជ ហើយអ្វីដែលនៅសេសសល់គឺត្រូវរលាយអស់នៅក្នុងភ្លើង។



តើគ្រួសារនេះមានតម្រូវការអ្វីខ្លះ?

- អាហារ
- ទីជម្រក
- សំលៀកបំពាក់
- ប្រដាប់ប្រដាចម្អិនអាហារ
- កន្លែងស្នាក់នៅបណ្តោះអាសន្នពេលផ្ទះកំពុងសាងសង់

តើមានអ្វីខ្លះដែលសហគមន៍អាចជួយបាន?

- មនុស្ស
    - ក. កម្លាំងជួយសាងសង់ផ្ទះថ្មី
    - ខ. មនុស្សជួយចម្អិនម្ហូបសម្រាប់អ្នកដែលស្ម័គ្រចិត្តជួយសង់ផ្ទះ
    - គ. អ្នកជួយមើលកូន
    - ង. អ្នកដែលផ្តល់សេចក្តីថ្នាក់ថ្នម និងការជ្រោមជ្រែងដល់គ្រួសារនេះ
    - ច. មនុស្សដើម្បីជួយសម្អាតកម្ទេចកម្ទីផ្ទះដែលឆេះ
    - ឈ. អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ជួយអន្តរាគមន៍ករណីចាំបាច់
- សម្ភារៈប្រើប្រាស់
    - ក. ឆ្នាំង និងខ្ទះទំនេរ
    - ខ. អាហារ
    - គ. សំលៀកបំពាក់
    - ឃ. ភួយដណ្តប់
- ការជួយសម្រួល
    - ក. កន្លែងស្នាក់នៅ



ចូរចែកសិស្សជាក្រុមតូចៗ រួចឆ្លើយសំណួរដូចខាងក្រោម។ ប្រសិនបើអាច ចូរលើកទឹកចិត្តឲ្យសិស្សគ្រប់ក្រុមចំណាយពេល ១០-២០ នាទីដើរជុំវិញសហគមន៍របស់គេ ដើម្បីជាការក្រើនរំឭកពីបញ្ហាដែលសហគមន៍កំពុងជួបប្រទះ។

១. តើក្នុងសហគមន៍របស់អ្នកមានបញ្ហាអ្វីខ្លះ?

២. តើអ្នកគិតថា ព្រះជាម្ចាស់មានព្រះបំណងដូចម្ដេចចំពោះបញ្ហាទាំងនោះ?

ចូរជ្រើសយកបញ្ហាធំៗ ៣យ៉ាងដោយចាប់ឆ្នោតតាមចំនួនគ្រាប់ (មើលកំណត់ចំណាំរបស់គ្រូ)។

តើព្រះជាម្ចាស់កំពុងត្រាស់ហៅឲ្យក្រុមជំនុំរបស់អ្នកធ្វើអ្វីខ្លះ? ចូរយកបញ្ហាទាំង៣ដែលអ្នកស្គាល់ ហើយចំពោះបញ្ហានីមួយៗត្រូវចោទសួរខ្លួនឯងថា តើសហគមន៍របស់យើងមានអ្វីខ្លះស្រាប់ហើយ ដើម្បីដោះស្រាយបញ្ហានេះ? សូមគិតអំពីមនុស្ស សម្ភារៈ ថវិការ និងគ្រឿងបរិក្ខារនានា ដែលអាចយកមកប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

**កំណត់ចំណាំរបស់គ្រូ**

មានរបៀបពីរយ៉ាងដែលអ្នកអាចបោះឆ្នោតរាប់ចំនួនគ្រាប់

១) ឲ្យវត្ថុចំនួន ១០ ដល់សិស្សម្នាក់ៗ (ដូចជាឈើចាក់ធ្មេញ ស្លឹកឈើ ដុំក្រួស ជាដើម) រួចឲ្យគេដាក់ចំនួនគ្រាប់តាមលំដាប់ដូចខាងក្រោម៖ ចំពោះគម្រោងដែលគេគិតថា សំខាន់ជាងគេបំផុតដាក់៤គ្រាប់ ចំពោះគម្រោងសំខាន់បន្ទាប់ដាក់ ៣គ្រាប់ ចំពោះគម្រោងសំខាន់ទី៣ ដាក់២គ្រាប់ និងគម្រោងសំខាន់ទី៤ ដាក់១គ្រាប់។

២) ឲ្យវត្ថុចំនួន១០ដល់សិស្សម្នាក់ៗ រួចឲ្យពួកគេដាក់ចំនួនគ្រាប់ក្នុងចំណោមគម្រោងទាំងនោះ ដាក់គ្រាប់ច្រើនជាងគេនៅក្នុងគម្រោងណាដែលសំខាន់បំផុត។

(វិធីទាំងពីរយ៉ាងនេះនឹងបង្ហាញឲ្យឃើញថាគម្រោងណាមួយទទួលបានចំនួនគ្រាប់ ឬសម្លេងឆ្នោតច្រើនជាងគេ)

## មេរៀនទី៧

# គណិតវិទ្យាតាមបែបព្រះរាជ្យព្រះជាម្ចាស់

**គោលបំណង**

១. ស្គាល់ពីការពហុគុណ និងព្រះពររបស់ព្រះជាម្ចាស់ នៅពេលដែលមនុស្សស្តាប់បង្គាប់។

២. ស្គាល់ពីច្បាប់នៃការប្រមូលផលៈ គឺគ្រាប់ពូជដែលសាបព្រោះតាមបង្គាប់នឹងទទួលបានផលផ្លែ ទោះបីជាអ្នកសាបព្រោះមិនមានបទពិសោធន៍ ឬឃើញអត្ថប្រយោជន៍ដោយផ្ទាល់ក្តី។

៣. ឃើញថាសូម្បីតែអ្នកក្រីក្រក៏អាច «ស្រលាញ់អ្នកជិតខាងឲ្យដូចស្រលាញ់ខ្លួនឯង» បានដែរ។

៤. ដឹងថាមនុស្សម្នាក់ៗមាននូវអ្វីៗគ្រប់យ៉ាងហើយ ដើម្បីសម្រេចតាមបញ្ជារបស់ព្រះជាម្ចាស់ក្នុងការស្រលាញ់អ្នកជិតខាងរបស់ខ្លួន។

៥. ស្គាល់ពីលទ្ធផលកើតចេញពីការស្តាប់បង្គាប់/មិនស្តាប់បង្គាប់ក្នុងការស្រលាញ់អ្នកដទៃ។

**មេរៀនសម្រាប់ចែកឲ្យសិស្ស**

៧.១ អេសាយ ៤០៖២៩ ទីសម្គាល់នានា (១ច្បាប់ ៥ទំព័រ)

៧.២ សំបុត្រនៃរឿង នំប៉័ង៥ដុំ និងត្រី២កន្ទុយ (១ក្រុម សំបុត្រ១)

៧.៣ សំបុត្រនៃរឿង លោកអេលីយ៉ា និងស្ត្រីមេម៉ាយ (១ក្រុម សំបុត្រ១)

៧.៤ សំបុត្រនៃរឿង ស្ត្រីមេម៉ាយ និងប្រាក់ពីរសេន (១ក្រុម សំបុត្រ១)

៧.៥ សំបុត្រនៃរឿង ប្រស្នាអំពីប្រាក់ណែន (១ក្រុម សំបុត្រ១)

**ចំណាំ៖** ចំពោះក្រុមដែលមិនសូវចេះគណិតវិទ្យា ត្រូវប្រើតែរូបភាពដែលប្រាប់ពីភាពខុសគ្នាកាលពីមុន និងពេលក្រោយ។ ចូរឲ្យក្រុមនេះចែករូបភាពជាពីរផ្នែក គឺរូបភាពពីពេលមុន និងពេលក្រោយ។ សូមសួរពួកគេថា «តើរូបទាំងពីរនេះមានភាពខុសគ្នាអ្វីខ្លះ? តើមនុស្សពីរូបភាពនៅផ្នែកទី១ ឆ្លងទៅផ្នែកទី២ ដោយរបៀបណា?» គឺដោយសារ ព្រះជាម្ចាស់។ ត្រូវធ្វើឲ្យសិស្សយល់ច្បាស់ថា ព្រះជាម្ចាស់គឺជាអ្នកពហុគុណ (បង្កើនចំនួន)។

## សេចក្តីផ្តើម ៖ អេសាយ ៤០៖២៩

តើអ្នកបានកត់ចំណាំដែរឬទេថា នៅក្នុងព្រះគម្ពីរមានគោលការណ៍តាមបែបគណិតវិទ្យា? នៅក្នុងមេរៀននេះ យើងនឹងមើលលើគោលការណ៍គណិតវិទ្យាខ្លះនៅក្នុងព្រះគម្ពីរ។

ចូរអាន អេសាយ ៤០៖២៩។ សូមពន្យល់ថា នេះជាខគម្ពីរគន្លឹះសម្រាប់មេរៀននេះ ។

**ការពិភាក្សានៅក្នុងក្រុមធំ៖**

- តើនរណាខ្លាំង? នរណាខ្សោយ?
- តើព្រះជាម្ចាស់ធ្វើអ្វីដើម្បីយើង?
- តើយើងអាចបំប្លែងខគម្ពីរនេះ ទៅជារូបមន្តគណិតវិទ្យាបានដែរឬទេ? ចូរសាកល្បង... (ប្រសិនបើអ្នកមានក្រុមធំ ត្រូវឲ្យសមាជិកប្រាំនាក់ឡើងទៅខាងមុខ ហើយឲ្យគេម្នាក់ៗនូវពាក្យ ឬនិមិត្តសញ្ញាគណិតវិទ្យាណាមួយ (កាតគឺនៅក្នុងកញ្ចប់ផ្ទាំងរូបភាព)។ សម្រាប់ក្រុមតូច ចូរដាក់កាតចូលគ្នាទៅលើឥដ្ឋ ហើយធ្វើការជាមួយគ្នាដើម្បីរៀបតាមលំដាប់ត្រឹមត្រូវ។

**រូបមន្ត៖ «ភាពខ្សោយរបស់យើង x ព្រះជាម្ចាស់ = ភាពខ្លាំង»**

តើយើងបានរៀនអ្វីខ្លះតាមរយៈខគម្ពីរ ឬរូបមន្តនេះ?

## រឿងទី១៖ «ក្មេងប្រុស និងអាហារថ្ងៃត្រង់របស់គេ» (**យ៉ូហាន ៦៖១-១៤**)

ចូរនិយាយរឿងនេះប្រាប់សិស្សដោយបញ្ចេញបញ្ចូលខ្លះៗ

កាលពីគ្រាមួយមានក្មេងប្រុសម្នាក់។ វាបានឮដំណឹងថានឹងមានគ្រូដ៏ល្បីម្នាក់ធ្វើដំណើរកាត់ស្រុកកាលីឡេ ហើយវាចង់ទៅស្តាប់ការបង្រៀនរបស់គាត់។ វាបានសុំម្តាយ តែគាត់មិនឲ្យទៅ ព្រោះនៅឆ្ងាយពេក ហើយណាមួយជិតដល់ពេលហូបបាយថ្ងៃត្រង់ផង។ តែក្មេងប្រុសនោះនៅតែអង្វរម្តាយម្តងហើយម្តងទៀតរហូតដល់គាត់យល់ព្រមឲ្យទៅ។

ពេលក្មេងនោះធ្វើដំណើរដល់គោលដៅហើយ ក៏ឃើញថាមានមនុស្សច្រើនកុះករ រួចវាបានប្រជ្រៀតទៅមុខដូចក្មេងៗផ្សេងទៀតដែរ។ ទីបំផុត វាបានឃើញកន្លែងមួយដែលវាអាចឈរស្តាប់ឮការបង្រៀនរបស់លោកគ្រូ និងពួកសិស្សរបស់គាត់។ ក្មេងប្រុសនោះបានស្តាប់ការបង្រៀន និងអ្វីៗដែលលោកគ្រូនោះបានមានប្រសាសន៍ហើយ គឺអស្ចារ្យមិនគួរឲ្យជឿសោះឡើយ។ វាស្តាប់រហូតដល់ភ្លេចហូបបាយថ្ងៃត្រង់។

តែក្រោយមកទៀត វាចាប់ផ្តើមឃ្លានបាយ ហើយក៏នឹកឃើញពីម្ហូបនៅក្នុងកញ្ចប់ដែលម្តាយខ្ចប់ដាក់ឲ្យ។ វាបានលូកយកនំបុ័ងពីក្នុងហោប៉ៅតិចៗដើម្បីកុំឲ្យគេចាប់អារម្មណ៍។

ស្រាប់តែរំពេចនោះ លោកគ្រូឈប់បង្រៀន ហើយបង្គាប់ឲ្យពួកសិស្សយកម្ហូបចែកអ្នកចូលរួមស្តាប់គ្រប់ៗគ្នា។ ពេលក្មេងនោះឮដូច្នេះ វាបានក្រឡេកមើលជុំវិញ ហើយឃើញថាចំនួនមនុស្សកើនឡើងដល់ទៅ ២០,០០០នាក់។ ក្មេងប្រុសនោះ ភ្ញាក់ផ្អើលហើយឆ្ងល់ថា «តើគេអាចធ្វើម្ហូបឲ្យមនុស្សច្រើនបែបនេះដោយរបៀបណា?» នៅពេលវាកំពុងងឿងឆ្ងល់បែបនេះ ពួកសិស្សក៏មានចម្ងល់ដូចគ្នាដែរ ហើយស្រាប់

តែមានម្នាក់សួរទៅលោកគ្រូថា តើយើងមានប្រាក់ឯណាមកទិញម្ហូបឲ្យមនុស្សច្រើនបែបនេះ? យ៉ាងហោចណាស់ក៏ត្រូវចំណាយប្រាក់ខែពេញមួយឆ្នាំដែរ។

លោកគ្រូបានសួរពួកសិស្សវិញថា «តើអ្នកមានអ្វីខ្លះ?» ក្មេងប្រុសនោះចាប់ផ្ដើមលាក់ម្ហូបរបស់វា តែលាក់មិនទាន់។ ស្រាប់តែមានសិស្សម្នាក់ឈ្មោះ អន់ដ្រេ បានឃើញវា រួចប្រាប់លោកគ្រូថា «លោកគ្រូ លោកគ្រូ មានក្មេងប្រុសម្នាក់មាននំប៉័ង ១ ២ ៣ ៤ ៥ ចំណិត និងត្រីពីរកន្ទុយ»។

លោកគ្រូក៏តបវិញថា «ចូរយកវាមកឲ្យខ្ញុំ»

តើអ្នកអាចស្រមៃមើលថា នឹងមានរឿងអ្វីកើតឡើងបន្ទាប់?

លោកអន់ដ្រេក៏និយាយទៅកាន់ក្មេងប្រុសនោះថា «លោកគ្រូចង់បានអាហាររបស់ប្អូន»។ ក្មេងនោះយល់ព្រមឲ្យអាហាររបស់គេទៅអន់ដ្រេ ហើយគាត់ក៏បានយកវាទៅឲ្យលោកគ្រូ។

ព្រះយេស៊ូបានយកអាហាររបស់ក្មេងប្រុសនោះ ហើយអរព្រះគុណដល់ព្រះបិតា រួចចាប់ផ្ដើមចែកអាហារដល់មនុស្សដែលចូលរួម។ ក្មេងប្រុស នោះឈរសម្លឹងស្លឹមិនគួរឲ្យជឿសោះ នៅពេលដែលឃើញពួកសិស្សកំពុងតែចែកអាហារ។ មនុស្សទាំងអស់នាំគ្នាហូបរហូតដល់ឆ្អែតស្កប់ស្កល់។ ក្មេងប្រុសនោះចាប់ផ្ដើមក្រឡេកមើលជុំវិញខ្លួន ហើយឃើញថាមាននំប៉័ងនៅសល់ដល់ទៅ១២ល្អី។

ឥឡូវនេះក្មេងប្រុសនោះចាប់ផ្ដើមអន្ទះអន្ទែងចង់ទៅផ្ទះប្រាប់ម្ដាយ។ វារត់រហូតដល់ផ្ទះ ហើយប្រាប់ម្ដាយដោយរំភើបចិត្តថា អាហារថ្ងៃត្រង់របស់វាបានឲ្យមនុស្សដល់ទៅ ៥,០០០នាក់បរិភោគទាំងប្រុស ទាំងស្រី និងក្មេងៗ។ ម្ដាយរបស់វាបានបែរមុខមក ហើយដកដង្ហើមធំ ទាំងពោលថា «នែកូនប្រុស ម្ដាយបានប្រាប់កូនច្រើនលើកច្រើនសារហើយថាកុំចេះតែប្រឌិត រឿងផ្ដេសផ្ដាស!»

តើយើងអាចបំប្លែងវាទៅជារូបមន្តបានដោយរបៀបណា?

*ចូរចែកសិស្សជាក្រុមមានគ្នា ៣-៤ នាក់ក្នុងមួយក្រុម ហើយឲ្យស្រោមសំបុត្រដែលសរសេរថា «ក្មេងប្រុស និងអាហារថ្ងៃត្រង់របស់គេ» កាត់ចេញពី (ក្នុងក្រដាសមេរៀន ៧.២) ឬ ធ្វើជាសញ្ញាសម្គាល់ធំៗ ហើយឲ្យសិស្សក្នុងក្រុមធ្វើការរួមគ្នា ដើម្បីបង្កើតរូបមន្ត។ ត្រូវផ្ដល់យោបល់ខ្លះៗ ដើម្បីឲ្យគេស្វែងរកចម្លើយបាន។ នៅពេលដែលសិស្សមួយក្រុមបានបញ្ចប់ជាមួយនឹងរូបមន្តរួចជាមួយគ្នាហើយ គេអាចធ្វើអ្វីដែលនៅសល់នៅក្នុងក្រុមតូចៗបាន។*

**ចម្លើយៈ** «ក្មេងប្រុសម្នាក់ + នំប៉័ង ៥ដុំ + ត្រី២កន្ទុយ x ព្រះយេស៊ូ = អាហារសម្រាប់មនុស្ស ៥,០០០ នាក់ + ទាំងស្រីៗ និងក្មេងៗ + <u>នំប៉័ងនៅសល់ ១២ ល្អី</u>»

នេះជារូបមន្តគណិតវិទ្យាតាមបែបព្រះរាជ្យរបស់ព្រះជាម្ចាស់!

**ការពិភាក្សានៅក្នុងក្រុមធំ៖**

- តើព្រះយេស៊ូត្រូវការក្មេងប្រុស និងអាហារថ្ងៃត្រង់របស់វាដែរឬទេ? តើព្រះយេស៊ូអាចផ្តល់អាហារដល់មនុស្សទាំងអស់តាមវិធីណាផ្សេងដែរឬទេ?
- ហេតុអ្វីបានជាព្រះយេស៊ូយកអាហារពីក្មេងប្រុស?

ចូរប្រាប់សិស្សឲ្យដឹងថា ពេលគេកំពុងគិតពីសំណួរទាំងនេះ យើងនឹងបន្តគណនាលេខនៅក្នុងព្រះគម្ពីរទៀត។

## រឿងទី២៖ «ស្ត្រីមេម៉ាយ និងអាហារចុងក្រោយរបស់គាត់» (១ ពង្សាវតារក្សត្រ ១៧៖៧)

នេះជាដំណើររឿងដែលកើតឡើងចំគ្រាលំបាកក្នុងប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែល។ ប្រទេសនេះបានធ្លាក់ក្នុងគ្រោះរាំងស្ងួតអស់រយៈពេល៣ឆ្នាំកន្លះ ហើយធ្វើឲ្យប្រជាជនរងគ្រោះ ជិតស្លាប់ សូម្បីលោកអេលីយ៉ាជាព្យាការីរបស់ព្រះជាម្ចាស់ ក៏រងទុក្ខវេទនាដែរ។

ប៉ុន្តែ ព្រះជាម្ចាស់បានបង្គាប់ឲ្យស្ត្រីមេម៉ាយម្នាក់ផ្គត់ផ្គង់លោកព្យាការីអេលីយ៉ា។ លុះលោកធ្វើដំណើរដល់ទ្វារក្រុង លោកឃើញស្ត្រីមេម៉ាយម្នាក់កំពុងតែរើសអុស ហើយព្រះជាម្ចាស់បានប្រាប់លោកឲ្យទៅសុំ «ទឹកបន្តិច ទទួលទាន»។ ស្ត្រីនោះក៏យល់ព្រមទៅដងទឹកឲ្យលោកអេលីយ៉ាទទួលទានបន្តិច ប៉ុន្តែមុនពេលនាងទៅដងទឹក លោកអេលីយ៉ាក៏សុំនាងឲ្យយកនំបុ័ងឲ្យលោកបរិភោគជាមុនសិន គឺសុំបរិភោគមុននាង ទាំងកូនរបស់នាងបានពុំទាន់បានបរិភោគផង។

នាងតបថា «នាងខ្ញុំសូមជម្រាបលោកក្នុងនាមព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ ខ្ញុំមានគ្រប់តែសម្រាប់ខ្ញុំ ហើយនិងកូនរបស់ខ្ញុំសម្រាប់តែអាហារមួយពេលនោះទេ ហើយយើងប្រាកដជាស្លាប់មិនខាន!» លោកអេលីបានតបទៅនាងថា «កុំខ្លាចអ្វីឡើយ ដ្បិតព្រះជាម្ចាស់នឹងផ្គត់ផ្គង់»។

ស្ត្រីនោះក៏បានចាកចេញទៅ ដើម្បីទៅធ្វើម្ហូបឲ្យលោកអេលីយ៉ា ដោយនាងមានម្សៅ និងប្រេងតែបន្តិចប៉ុណ្ណោះ។ នៅពេលដែលនាងបានប្រើប្រេងអស់ពីក្នុងដប និងម្សៅដើម្បីដុតនំបុ័ងឲ្យលោកអេលី នាងបានភ្ញាក់ផ្អើលដែលនៅក្នុងដបដាក់ប្រេង និងម្សៅរបស់នាងនៅតែពេញដដែល ដូចជាមិនទាន់បានប៉ះពាល់សោះ។ ស្ត្រីនោះបាននិយាយទៅកាន់លោកអេលីយ៉ាថា «ខ្ញុំបានប្រើអ្វីដែលខ្ញុំមានសម្រាប់លោកតែឥឡូវនេះវានៅសល់ដដែល។ សូមសរសើរតម្កើងដល់ព្រះជាម្ចាស់!»

ព្រះគម្ពីរបានប្រាប់យើងថា ព្រះជាម្ចាស់មិនត្រឹមតែប្រទានអាហារគ្រប់គ្រាន់សម្រាប់លោកអេលីយ៉ា ស្ត្រីមេម៉ាយ និងក្រុមគ្រួសាររបស់នាងនៅថ្ងៃនោះប៉ុណ្ណោះទេ តែព្រះអង្គបានប្រទានអាហារឲ្យពួកគេមានគ្រប់គ្រាន់សម្រាប់រយៈពេល៣ឆ្នាំកន្លះខាងមុខទៀត។ នេះជាហេតុការណ៍ដ៏អស្ចារ្យមួយ។

នេះហើយហៅថាគណិតវិទ្យាតាមបែបព្រះរាជ្យរបស់ព្រះជាម្ចាស់!

តើយើងអាចបំប្លែងរឿងនេះទៅជារូបមន្តដោយរបៀបណា?

ចូរចែកសំបុត្រ (ក្រដាសមេរៀន ៧.៣) ឲ្យក្រុមនីមួយៗ ដើម្បីឲ្យគេសាកល្បងបង្កើតរូបមន្ត។

**ចម្លើយៈ** «ស្ត្រីមេម៉ាយ + នំ១ដុំ x ព្រះជាម្ចាស់ = នំ១ដុំ x មនុស្ស៣នាក់ x ៣៦៥ ថ្ងៃ x ៣ឆ្នាំ = ៣២៨៥»

សម្រាប់ក្រុមមិនសូវចេះអក្សរ ចូរដាក់ពាក្យ ឬសញ្ញាតំណាងឱ្យៈ

- ស្ត្រីមេម៉ាយ
- នំ១ដុំ
- អាហារសម្រាប់មនុស្ស៣នាក់ ក្នុងរយៈពេល ៣ឆ្នាំ

**ការពិភាក្សាៈ**

- តើស្ត្រីមេម៉ាយនោះជាអ្នកក្រីក្រឬ?
- តើព្រះជាម្ចាស់អាចប្រទានអាហារដល់ព្យាការីអេលីយ៉ា តាមរបៀបណាផ្សេងបានដែរឬទេ?
- ហេតុអ្វីបានជាព្រះជាម្ចាស់បង្គាប់ឲ្យព្យាការីអេលីយ៉ាទៅជួបស្ត្រីមេម៉ាយក្រីក្រ ដើម្បីសុំអាហារពីគាត់ដូច្នោះ?
- ហេតុអ្វីបានជាព្រះជាម្ចាស់យកអាហារពីក្មេងប្រុសតូចម្នាក់នោះ?
- តើព្រះជាម្ចាស់ពិតជាមានព្រះទ័យអាណិតអាសូរដល់ជនក្រីក្រ និងស្ត្រីមេម៉ាយដែរឬទេ?

## រឿងទី៣ «ស្ត្រីមេម៉ាយម្នាក់ និងប្រាក់ពីរសេន» ម៉ាកុស ១២ៈ៤១

នៅថ្ងៃមួយពេលព្រះយេស៊ូគង់នៅក្នុងព្រះវិហារទល់មុខហិបតង្វាយ ព្រះអង្គទតមើលរបៀបដែលអ្នកមានទាក់ទាញចំណាប់អារម្មណ៍នៅពេលដែលគេយកប្រាក់មកថ្វាយក្នុងហិបតង្វាយនោះ។ មានស្ត្រីមេម៉ាយក្រីក្រម្នាក់មកដល់ នាងមានតែប្រាក់ពីរសេនប៉ុណ្ណោះ។ ដោយសារតែនាងមានតែប៉ុណ្ណឹង នាងមានអារម្មណ៍ខ្មាសគេណាស់ ហើយមិនចង់ឲ្យគេឃើញនាងថ្វាយដង្វាយទេ ដូច្នេះនាងបានថ្វាយដង្វាយដោយស្ងាត់ៗ និងលាក់លៀម។

ព្រះយេស៊ូបានហៅពួកសាវ័កមក ហើយមានព្រះបន្ទូលទៅគេថា «ស្ត្រីម្នាក់នេះ បានថ្វាយដង្វាយច្រើនជាងអ្នកផ្សេងទៅទៀត»។

**ការពិភាក្សាៈ**

- តើព្រះយេស៊ូមានបន្ទូលនេះ មានន័យដូចម្តេច? តើស្ត្រីម្នាក់នោះបានថ្វាយដង្វាយច្រើនជាងគេដោយរបៀបណា?
- ហេតុអ្វីបានជាព្រះយេស៊ូមិនប្រាប់នាងថា «ទេ អ្នកម្តាយត្រូវការប្រាក់នេះជាងព្រះវិហារទៅទៀត»។ តាមពិតព្រះអង្គអាចហាមគាត់បាន ប៉ុន្តែហេតុអ្វីបានជាព្រះអង្គមិនហាមគាត់?

ព្រះយេស៊ូមិនបានហាមឃាត់ស្ត្រីម្នាក់នោះទេ តែផ្ទុយមកវិញព្រះអង្គបានកត់ចំណាំជាពិសេសលើការលះបង់របស់គាត់។ ចាប់តាំងពីពេលនោះមក រឿងរបស់ស្ត្រីម្នាក់នោះត្រូវបានគេសរសេរទុកសម្រាប់ឲ្យមនុស្សជាច្រើនទៀតអាន។ វាជាការពិតដែលគាត់បានថ្វាយច្រើនបំផុត ចេញពីលទ្ធភាពរបស់គាត់។ ទង្វើរបស់គាត់បានជំរុញទឹកចិត្តដល់គ្រិស្តបរិស័ទជាង២០០០ឆ្នាំមកហើយ។ ចូរគិតថា ជាលទ្ធផលនៃគំរូរបស់គាត់ តើគ្រិស្តបរិស័ទបានថ្វាយទៅកាន់ព្រះជាម្ចាស់ គិតជាទឹកប្រាក់ប៉ុន្មាន។ នេះជាការពហុគុណដ៏ច្រើន។ គាត់បានថ្វាយតង្វាយអស់ពីអ្វីដែលគាត់មាន ហើយព្រះជាម្ចាស់ជាអ្នកពហុគុណចំនួននោះ។ នេះហើយជាគណិតវិទ្យាតាមព្រះរាជ្យរបស់ព្រះជាម្ចាស់!

ចូរចែកសំបុត្រ (មេរៀនទី ៧.៤)

**ចម្លើយ៖** ស្ត្រីមេម៉ាយ + កាក់២ x ព្រះយេស៊ូ = ការជំរុញទឹកចិត្តរយៈពេល ២០០០ ឆ្នាំ

សម្រាប់ក្រុមមិនសូវចេះអក្សរ
- ស្ត្រីមេម៉ាយ
- កាក់២
- ការជំរុញទឹកចិត្តរយៈពេល ២០០០ឆ្នាំ

**ត្រូវរំឭកក្រុមនីមួយៗអំពី៖**

- ព្រះជាម្ចាស់បង្គាប់ឲ្យក្មេងប្រុសតូចនោះថ្វាយអាហារ តែមួយ ដែលវាមានដល់ទ្រង់...
- ទ្រង់បង្គាប់ឲ្យស្ត្រីមេម៉ាយផ្តល់អាហារចុងក្រោយបង្អស់ដែលគាត់មានដល់ព្យាការីអេលីយ៉ាហូបជាមុន...
- ទ្រង់អនុញ្ញាតឲ្យស្ត្រីមេម៉ាយម្នាក់ថ្វាយតង្វាយអស់ពីអ្វីដែលគាត់មាន...

**ការពិភាក្សា៖**

- តើព្រះយេស៊ូមានបន្ទូលលើកលែងអ្នកក្រីក្រមិនឲ្យថ្វាយតង្វាយឬ?
- តើអ្នកថ្វាយតង្វាយតែងទទួលបានព្រះពរបែបផ្ទាល់ខ្លួន នៅក្នុងជីវិតនេះជានិច្ចឬ?
- ដើម្បីស្តាប់បង្គាប់តាមបទបញ្ជារបស់ព្រះយេស៊ូដែលឲ្យយើងស្រលាញ់អ្នកជិតខាងរបស់យើង តើយើងត្រូវការអ្វី? តើទាល់តែមានអ្វីមួយពិសេសជាមុនសិនឬ? (យើងត្រូវការតែអ្វីដែលយើងមានស្រាប់តែប៉ុណ្ណោះ)
- តើយើងគួរមានចិត្តគំនិតបែបណា? (ចិត្តគំនិតនៃជំនឿ ការស្តាប់បង្គាប់ និងការបន្ទាបខ្លួន)
- តើមានអ្វីមួយដែល «តិចតួចពេក» ឬ «គ្មានប្រយោជន៍» ទាល់តែសោះ សម្រាប់ថ្វាយជាតង្វាយដល់ព្រះជាម្ចាស់ដែរឬទេ?

- តើព្រះជាម្ចាស់ប្រទានពរដល់ការថ្វាយរបស់ជនក្រីក្រដែរឬទេ?
- នៅដែលព្រះជាម្ចាស់ប្រទានពរដល់ការថ្វាយរបស់ជនក្រីក្រ តើវាគ្រាន់តែជាការប្រទានពរបែប «បូកបន្ថែម» ឬ «គុណបន្ថែម?»

រឿងចុងក្រោយបង្អស់ តែរឿងនេះមិនសូវជារីករាយប៉ុន្មាននោះទេ...

## រឿងទី៤ «ប្រស្នាអំពីប្រាក់ណែន» ម៉ាថាយ ២៥:១៤

មានបុរសជាសេដ្ឋីម្នាក់ហៀបចេញដំណើរទៅស្រុកឆ្ងាយ។ មុនពេលគាត់ចាក់ចេញទៅ គាត់បានហៅពួកអ្នកបម្រើ៣នាក់មកប្រគល់ទ្រព្យសម្បត្តិឲ្យ។ គាត់ប្រគល់ប្រាក់ឲ្យអ្នកបម្រើទីមួយនូវប្រាក់៥ណែន រួចនិយាយថា «ចូរយកវាទៅរកស៊ីចុះ ហើយចាំសងខ្ញុំពេលខ្ញុំត្រឡប់មកវិញ»។ គាត់បានឲ្យអ្នកបម្រើទីពីរនូវប្រាក់២ណែន រួចនិយាយថា«យកវាទៅរកស៊ីចុះ ហើយចាំសងពេលខ្ញុំត្រឡប់មកវិញ»។ ជាចុងក្រោយគាត់បានប្រគល់ប្រាក់១ណែនទៅឲ្យអ្នកបម្រើទី៣ ហើយនិយាយដូចគ្នាថា «ចូរយកវាទៅរកស៊ីចុះ ហើយចាំសងពេលខ្ញុំត្រឡប់មកវិញ»

លុះយូរក្រោយមកគាត់បានវិលត្រឡប់មកវិញ។ គាត់ក៏បានហៅពួកអ្នកបម្រើមកជួបម្តងទៀត ដើម្បីសាកសួរថា ពួកគេធ្វើអ្វីខ្លះពេលគាត់មិននៅ។ អ្នកបម្រើទីមួយ បាននិយាយប្រាប់ថា គាត់រកបានប្រាក់៥ណែនបន្ថែមទៀត។ លោកសេដ្ឋីក៏តបថា «ល្អហើយអ្នកបម្រើដ៏ប្រសើរ មានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ ឥឡូវអ្នកមានច្រើនបន្ថែមទៀត»។ អ្នកបម្រើទី២ បាននិយាយប្រាប់ថា គាត់រកបានប្រាក់២ណែនបន្ថែមទៀត រួចលោកសេដ្ឋីក៏តបថា«ល្អហើយអ្នកបម្រើដ៏ប្រសើរ មានចិត្តស្មោះត្រង់អើយ! អ្នកបានស្មោះត្រង់នឹងកិច្ចការមួយដ៏តូចនេះ ឥឡូវអ្នកមានច្រើនបន្ថែមទៀត»។

នៅចុងក្រោយគេ អ្នកបម្រើទី៣បានបរិយាយប្រាប់ថា «ខ្ញុំដឹងថាលោកជាមនុស្សតឹងតែងណាស់។ ខ្ញុំខ្លាចបាត់ប្រាក់ដែលលោកឲ្យខ្ញុំ ដូច្នេះខ្ញុំក៏បានយកវាទីកកប់។ ដូច្នេះវានឹងមិនបាត់ទេ»។ លោកសេដ្ឋីក៏តបទៅបុរសនោះវិញថា «នែ អ្នកបម្រើអាក្រក់ ខ្ជិលច្រអូសអើយ!» គាត់ក៏បានយកប្រាក់ពីបុរសម្នាក់នោះវិញ ហើយបានបោះគាត់ចោលទៅខាងក្រៅព្រះរាជ្យ។

សាច់រឿងនេះក៏ជាមានគណិតវិទ្យាតាមបែបព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរ។ សូមមើលទាំងអស់គ្នា...

ចែកសំបុត្រចុងក្រោយគេ (មេរៀនទី ៧.៥)

**ចម្លើយៈ** "អ្នកបម្រើ + ប្រាក់១ណែន x 0 = កំណើន 0 + អ្នកបម្រើត្រូវបណ្តេញចេញទៅទីងងឹត"

### ការពិភាក្សា

- តើអ្នកណាដែលបានទទួលប្រាក់ចុងក្រោយគេ? អ្នកក្រីក្រជាងគេឬ? ប៉ុន្តែ សូមមើលថាមានរឿងអ្វីកើតឡើង!
- តើព្រះជាម្ចាស់មិនយកព្រះហឫទ័យទុកដាក់ជាមួយអ្នកក្រីក្រទេឬ? ហេតុអ្វីបានជាគេបោះអ្នកនោះចេញពីព្រះរាជ្យរបស់ព្រះជាម្ចាស់?
- តើមានផលលំបាកអ្វីខ្លះកើតចេញពីការមិនស្តាប់បង្គាប់ព្រះយេស៊ូ?

## សេចក្តីសន្និដ្ឋាន

ចូរឲ្យក្រុមនីមួយៗគិតពីសំណួរដូចខាងក្រោម។ ហើយបើអាច ចូរឲ្យគេពិភាក្សាគ្នារកចម្លើយ៖

១. តើយើងបាននឹងកំពុងអនុវត្តគោលការណ៍ទាំងនេះក្នុងជីវិតខ្លួនឯងហើយឬនៅ?

២. តើគោលកាណ៍ទាំងនេះត្រូវបានអនុវត្តដល់កម្រិតណាដែរ នៅក្នុងក្រុមជំនុំ?

៣. តើមានការផ្លាស់ប្តូរអ្វីខ្លះ ចំពោះខ្លួនឯង និងក្រុមជំនុំដើម្បីអនុវត្តគោលការណ៍នេះ?

## មេរៀនទី៨

# ការស្វែងយល់ពីរបៀបជួយ

**គោលបំណង**

១. យល់ការអភិវឌ្ឍពិតប្រាកដ គឺជាការបង្រៀនអ្នកដទៃឲ្យធ្វើអ្វីមួយដោយខ្លួនគេ។
២. យល់ថា ពេលណាជាពេលល្អក្នុងការធ្វើអ្វីមួយសម្រាប់នរណាម្នាក់ និងពេលណាជាពេលដែលប្រសើរ ក្នុងការបង្រៀនពួកគេឲ្យអ្វីមួយដើម្បីខ្លួនគេ។

## ការដើរឆ្លងទឹកទន្លេ

ចូរយកដី-សគូសបន្ទាត់ពីរនៅលើឥដ្ឋធ្វើជាច្រាំងទន្លេ។ រួចគូសរង្វង់ពីរធ្វើជាដុំថ្មសម្រាប់ដើរជាន់ និងរង្វង់មូលធំមួយទៀតធ្វើជាកោះ។ មានបុរសពីរនាក់ចង់ឆ្លងទឹកទន្លេ ប៉ុន្តែពួកគេអត់ចេះហែលទឹក។ ខ្សែទឹកហូរខ្លាំងណាស់ ហើយពួកគេមិនហ៊ានដើរឆ្លងទេ។ បុរសទី៣ ដើរចូលមកដល់ ហើយឃើញពីបញ្ហាលំបាករបស់ពួកគេ។ គាត់ក៏ស្ម័គ្រចិត្តចិត្តជួយបុរសទាំងពីរឲ្យដើរលើដុំថ្ម ប៉ុន្តែពួកគេនៅតែខ្លាច។ ដូច្នេះ គាត់សុខចិត្តអៀវចម្លងបុរសម្នាក់ឲ្យដល់ដីកោះ ហើយទុកឲ្យគាត់រង់ចាំនៅទីនោះ។

រួចគាត់ក៏ត្រឡប់មកយកបុរសទី២។ ប៉ុន្តែ ពេលនេះគាត់អស់កម្លាំងណាស់ ហេតុនេះគាត់មិនអាចអៀវបុរសទី២ម្នាក់ទៀតបាននោះទេ តែគាត់ស្ម័គ្រចិត្តជួយបង្រៀនឲ្យគាត់ចេះដើរឆ្លងលើដុំថ្ម។ ពេលដើរឆ្លងបានត្រឹមតែពាក់កណ្តាល បុរសទី២នោះចាប់ផ្តើមមានទំនុកចិត្ត ហើយអាចដើរឆ្លងបានដោយខ្លួនឯង។ ចុងបញ្ចប់បុរសទាំងពីរអាចដើរឆ្លងទន្លេបានដូចគ្នា តែបុរសម្នាក់អាចដើរឆ្លងដោយខ្លួនឯង រីឯបុរសម្នាក់ទៀតនៅតែស្រែករកឲ្យគេជួយអៀវឆ្លង នៅពេលដែលបុរសទី១បានដើរចេញទៅ។

**ពិភាក្សានៅក្នុងក្រុមធំ៖**

១. តើអ្នកបានឃើញអ្វីកើតឡើងខ្លះនៅក្នុងការសម្តែងនេះ?
២. តើវិធីសាស្ត្រជួយឲ្យបុរសទាំងពីរនាក់នោះដើរឆ្លងទន្លេ មានលក្ខណៈខុសគ្នាដូចម្តេចខ្លះ?

- ខុសគ្នាត្រង់ម្នាក់ឲ្យគេអៀវ តែម្នាក់ទៀតឲ្យគេបង្រៀនពីរបៀបដើរឆ្លងទឹកទន្លេ។

ត្រូវពន្យល់សិស្សឲ្យដឹងថា នេះជាដំណើររឿងដែលជួយយើងឲ្យយល់ពីរបៀបជួយអ្នកដទៃ។ ត្រើយម្ខាងនៃទន្លេតំណាងឲ្យសហគមន៍ ឬមនុស្សដែលក្រីក្រ ហើយត្រើយម្ខាងទៀតតំណាងឲ្យការដែលពួកគេចង់អភិវឌ្ឍខ្លួន និងសហគមន៍។ បុរសពីរនាក់ដែលចង់ដើរឆ្លង តំណាងឲ្យជនក្រីក្រដែលត្រូវការជំនួយ ហើយបុរសទី៣គឺតំណាងឲ្យយើងដែលជាអ្នកចង់ជួយ។

៣. តើមានរឿងអ្វីកើតឡើងចំពោះបុរសទី១? ក្រោយពីគាត់ឆ្លងរួច តើគាត់បានល្អប្រសើរជាងមុន ឬយ៉ាប់យ៉ឺនជាងមុន?

- គាត់ត្រូវបានគេទុកចោលនៅកណ្ដាលទន្លេ។
- ឥឡូវនេះគាត់យ៉ាប់យ៉ឺនជាងមុនទៅទៀត ព្រោះគាត់ជាប់គាំងនៅលើកោះនោះ ពុំមានលទ្ធភាពឆ្លងទៅណាទៀតឡើយ។

៤. តើបុរសណារៀនឆាប់ចេះជាង? តើអ្នកដែលឈរចាំតែមើលគេ ឬក៏អ្នកដែលត្រូវគេបង្រៀនឲ្យធ្វើ?

- គឺបុរសដែលត្រូវបានបង្រៀនឲ្យធ្វើ។ ដើម្បីឲ្យគេរៀន គឺមនុស្សត្រូវការឧទាហរណ៍ជាគំរូ និងការលើកទឹកចិត្ត។

៥. តើមានរឿងអ្វីកើតឡើង ប្រសិនបើយើងគិតតែពីជួយគេ តែមិនបង្រៀនគេឲ្យចេះធ្វើការងារជួយខ្លួនឯង?

- គឺពួកគេនឹងមិនចេះធ្វើការងារជួយខ្លួនឯងទេ ហើយតែងតែត្រូវការយើងជួយពួកគេ។

៦. តើយើងត្រូវធ្វើដូចម្ដេច ដើម្បីឲ្យអ្នកដែលយើងជួយចេះពឹងលើខ្លួនឯង?

- ត្រូវបង្រៀនមនុស្សឲ្យគេចេះធ្វើការងារដោយខ្លួនឯង។
- ត្រូវមានចិត្តជួយគេជាសន្សឹមៗរហូតដល់គេអាចចេះដើរបានដោយខ្លួនឯង។

<u>ចូរសម្ដែងរឿងនេះម្ដងទៀត</u> នៅកន្លែងដែលបុរសម្នាក់បានជួយឆ្លងផុតទន្លេ ហើយជួយបង្រៀនបុរសដែលគេទុកចោលនៅលើកោះ ឲ្យចេះដើរឆ្លងដូចគាត់ដែរ។ ធ្វើដូច្នេះ គឺដើម្បីឲ្យបុរសនោះអាចចេះបង្រៀនអ្នកដទៃទៀតបានដែរ។

តើយើងសង្កេតឃើញមានអ្វីខ្លះកើតឡើង តាមរយៈការសម្ដែងជាលើកទីពីរនេះ?

- ប្រសិនបើយើងបង្រៀនមនុស្ស ហើយពួកគេអាចបង្រៀនអ្នកផ្សេងទៀតបាន នោះយើងអាចជួយមនុស្សដែលត្រូវការជំនួយបានកាន់តែច្រើនឡើងៗ។

## ដំណើររឿងពិតនៃការផ្លាស់ប្ដូររបស់អ្នកស្រី លី (Lee)

ពាក្យស្លោកមួយពោលថា «ស៊ូបង្រៀនមនុស្សឲ្យចេះស្ទូចត្រី ប្រសើរជាងឲ្យត្រីគេហូប។ ប្រសិនបើអ្នកបង្រៀនមនុស្សឲ្យចេះស្ទូចត្រី នោះអ្នកនឹងអាចចិញ្ចឹមគេអស់មួយជីវិត។»

- តើពាក្យស្លោកនេះមានន័យដូចម្ដេច?
- តើយើងអាចយកវាមកអនុវត្តដូចម្ដេច ដើម្បីជួយមនុស្សក្នុងសហគមន៍?
- តើមានឧទាហរណ៍ណាខ្លះដែលយើងអាច «បង្រៀនមនុស្សឲ្យចេះស្ទូចត្រី» ប្រសើរជាង ឲ្យត្រីគេហូប?

ចូរអានដំណើររឿងទាំងអស់នេះ

អ្នកស្រីលី ជាមនុស្សពិតម្នាក់ ប៉ុន្តែឈ្មោះរបស់គាត់ត្រូវបានដូរ។ គាត់មានចិត្តចង់ជួយគ្រួសារក្រីក្រក្នុងសហគមន៍របស់គាត់យ៉ាងខ្លាំង ជាពិសេសអ្នកដែលគ្មានការងារធ្វើ។ ជារៀងរាល់ខែ គាត់តែងតែចុះទៅសួរសុខទុក្ខគ្រួសារមួយចំនួន ដើម្បីជួយគេឲ្យបង្កើតរបរចិញ្ចឹមជីវិត។ ខាងក្រោមនេះជាដំណើររឿង ៣ ក្នុងចំណោមរឿងផ្សេងៗទៀតដែលគាត់បានជួយដល់ក្រុមគ្រួសារមួយចំនួន។ ដំណើររឿងទាំង អស់នេះសុទ្ធតែជារឿងពិតៈ

### សាច់រឿងទី១ៈ អ្នកស្រី និងសួនផ្កា

នៅក្នុងតំបន់របស់នាង មានក្រុមគ្រួសារក្រីក្រមួយដែលមានកូនពីរនាក់។ ទាំងឪពុក និងម្ដាយរបស់ពួកគេ គ្មានការងារធ្វើនោះទេ។ អ្នកស្រីលី បានមកសួរសុខទុក្ខពួកគេ ហើយបានសម្គាល់ថាមានដីមួយដុំដែលនៅមុខផ្ទះរបស់ពួកគេ។ «ហេតុអ្វីបានជាអ្នកមិនដាំផ្កា» គាត់បានសួរ។ «អ្នកអាចធ្វើឲ្យផ្ទះរបស់អ្នកមានសោភ័ណភាពស្អាត និងអាចលក់ផ្កានៅផ្សារជិតនោះបាន។»



ស្ត្រីជាម្ដាយក៏បានធ្វើតាមនាង ហើយចាប់ផ្ដើមយកផ្កាដែលគាត់បានដាំ ទៅលក់នៅផ្សារ។ ប៉ុន្តែ មិនយូរប៉ុន្មាន អ្នកទិញក៏បានសួររកផ្កាប្រភេទផ្សេងផងដែរ ប៉ុន្តែ ដោយសារតែនាងមានដីតូចតែមួយកន្លែង មិនអាចដាំប្រភេទផ្កាផ្សេងបាននោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ត្រីជាម្ដាយបានទិញផ្កាពីអ្នកដាំផ្សេង ហើយយកមកលក់ជាមួយផ្ការបស់នាង ដើម្បីទទួលបានចំណូល។ ឥឡូវនេះ នាងមានកន្លែងតូចមួយនៅក្នុងផ្សារដើម្បីលក់ផ្កា ហើយនាងគិតថា «ខ្ញុំអាចលក់របស់ផ្សេងទៀតបានតើ!» នាងបានក្រោកពីព្រលឹមដើម្បីទៅទិញចេក និងដូងយកមកលក់នៅផ្សារក្នុងតូបលក់ផ្ការបស់នាង។

### រឿងទី២ៈ អ្នកស្រីលី និងដំឡូងជ្វា

មានគ្រួសារមួយទៀតដែលត្រូវការជំនួយ ចង់បានការងារធ្វើប៉ុន្តែមិនដឹងថាធ្វើអ្វី ហើយក៏មិនមានជំនាញអ្វីដែរ។ ពួកគេធ្វើការជាកម្មករ ប៉ុន្តែពួកគេមិនអាចរកការងារធ្វើបាននោះទេ។ អ្នកស្រីលី មើលឃើញថាគ្រួសារមួយនេះ ខិតខំប្រឹងប្រែងធ្វើការ និងពិតជាចង់ធ្វើការ ដូចនេះនាងបានទៅលេងគ្រួសារមួយទៀតនៅក្នុងក្រុមជំនុំ ដែលជាកសិករដាំដំឡូងជ្វា។ នាងបានសួរពួកគេថា ការធ្វើការដាំដំឡូងជ្វាចំណេញដែរឬទេ តើវាមានទីផ្សារល្អដែរឬទេ ហើយអ្នកត្រូវការអ្វីខ្លះដើម្បីដាំដំឡូងជ្វា។

នៅពេលដែលនាងបានរៀនថាវាជាការងារដ៏ល្អមួយ នាងបានពន្យល់ទៅកាន់គ្រួសារនោះថា ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យស្រលាញ់អ្នកជិតខាង និងមើលថែជនក្រីក្រ និងហើយនាងបានសួរពួកគេថា តើពួកគេមានបំណងចង់បង្រៀនគ្រួសារក្រីក្រមួយពីរបៀបដាំដំឡូងជ្វាដែរឬទេ។ ពួកគេក៏យល់ព្រម។ អ្នកស្រីលីបានណែនាំគ្រួសារទាំងពីរឲ្យស្គាល់គ្នា។ គ្រួសារក្រីក្រនោះពិតជារំភើប ដែលឥឡូវនេះពួកគេអាចធ្វើអ្វីបាន ហើយបានជួលដីមួយកន្លែងតូច និងអ្វីៗដែលត្រូវការដើម្បីចាប់ផ្តើម។ នៅចុងឆ្នាំ ពួកគេប្រមូលបានផលល្អ ហើយអាចមានលទ្ធភាពដើម្បីបង់ថ្លៃជួលដីបាន និងលុយសម្រាប់ទិញគ្រាប់ពូជ ហើយនៅតែអាចមានប្រាក់ចំណេញដល់គ្រួសាររបស់ពួកគេ។



**រឿងទី៣៖ អ្នកស្រីលី និង ការផ្សះផ្សានៅក្នុងគ្រួសារ**



នៅក្នុងគ្រួសារទី៣នេះ អ្នកស្រីលី ចង់ជួយកូនដែលបានបែកចេញពីឪពុកម្តាយរបស់គេ។ ឪពុកម្តាយនៅក្នុងគ្រួសារនេះ ថាក្រុមគ្រួសារពួកគេគ្មានបានការ និងគ្មានប្រយោជន៍អ្វីឡើយ។ អ្នកស្រីបានជួបជាមួយគ្រួសារនោះ ហើយបានព្យាយាមសម្របសម្រួលគ្រួសារទាំងសងខាង។ អ្នកលី ធានាថា នាងនឹងជួបជាមួយគ្រួសារនោះឲ្យបានទៀងទាត់ ព្រមទាំងជួយឲ្យជីវិតរបស់ពួកគេប្រសើរឡើង ប្រសិនបើឪពុកម្តាយចង់ទទួលយកគ្រួសាររបស់ពួកគេវិញ និងជួយពួកគេបន្តិចបន្តួច។ ជាលទ្ធផល ឪពុកម្តាយបានសម្រេចចិត្តទុកចិត្តកូនប្រុស និងឲ្យកូនប្រុសខ្ចីលុយមួយចំនួន ដើម្បីអាចចាប់ផ្តើមអាជីវកម្មសំណល់ដែក។ ឥឡូវនេះ កូនប្រុសរបស់គាត់ដើរទិញរបស់របរដែលប្រើហើយចាស់ៗដែលធ្វើមកពីដែក និងលក់វាឲ្យហាងកែឆ្នៃ។ សព្វថ្ងៃនេះ គាត់អាចផ្គត់ផ្គង់គ្រួសាររបស់គាត់ និងមានសេចក្តីអំណរនូវអ្វីដែលគាត់រកបានប្រចាំថ្ងៃ ហើយគាត់មានអារម្មណ៍ថាគាត់មានសេចក្តីថ្លៃថ្នូរ។

**នៅក្នុងក្រុមតូច**

ចូរគិតពីសាច់រឿងទាំងអស់នេះ រួចពិភាក្សានូវសំណួរដូចខាងក្រោម៖

- តើអ្នកស្រីលីបានធ្វើអ្វីខ្លះចំពោះគ្រួសារនីមួយៗ?
    - ផ្តល់ដំបូន្មាន និងលើកទឹកចិត្ត
    - ចុះសួរសុខទុក្ខអ្នកផ្សេងទៀត ដូចជាគ្រួសារដែលបានដាំដំឡូងជ្វា ហើយរៀនថា តើវាអាចផ្តល់ប្រាក់ចំណេញដែរឬទេ និងថាតើពួកគេមានចិត្តចង់ជួយដែរឬទេ។

- តើសកម្មភាពរបស់អ្នកស្រីលី ទទួលបានលទ្ធផលអ្វីខ្លះ?
    - មនុស្សមានការងារធ្វើ ហើយអាចមានលទ្ធភាពផ្គត់ផ្គង់ដល់គ្រួសាររបស់ពួកគេបាន
    - ធ្វើឲ្យគេមានមោទនភាពលើខ្លួនឯង ព្រោះគេអាចធ្វើអ្វីម្យ៉ាងដើម្បីជួយដល់ខ្លួនឯង។
- តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកស្រីលី គ្រាន់តែផ្តល់លុយមួយចំនួន ឬអាហារមួយចំនួន ទៅកាន់មនុស្សទាំងនេះ?
    - ពួកគេនឹងពុំមានការផ្លាស់ប្តូរឡើយ។
- ប្រសិនបើអ្នកស្រីលី បានផ្គត់ផ្គង់លុយឲ្យពួកគេជារៀងរាល់សប្តាហ៍រយៈពីរឆ្នាំ រួចឈប់ តើអ្នកគិតថា ជីវិតរបស់ពួកគេនឹងមានការរីកចម្រើនដូចដែលគេចេះជួយខ្លួនឯងនេះដែរឬទេ?
    - ទេ គឺគេនឹងអង្គុយចាំតែទទួលយកលុយពីអ្នកស្រីលី ហើយពឹងផ្អែកលើលុយប៉ុណ្ណឹង ហើយលែងចង់ធ្វើការជាមិនខាន។
- តើការជួយគេដោយឲ្យលុយ និងការជួយគេដូចអ្នកស្រីលីបានធ្វើ ខុសគ្នាដូចម្តេចខ្លះ?
    - គាត់ផ្តល់ជាជំនាញ និងវិធីសាស្ត្រអនុវត្តដល់មនុស្ស ដើម្បីឲ្យគេចេះជួយខ្លួនឯងបាន។
- ចូរគិតមើលថា  ប្រសិនបើយើងគ្រប់ៗគ្នាសុទ្ធតែធ្វើដូចអ្នកស្រីលី ដូចជាការចុះសួរសុខទុក្ខក្រុមគ្រួសារ ចូលរួមស្តាប់ និងព្យាយាមស្វែងយល់ពីបញ្ហារបស់គេ ក៏ដូចជាជួយរកដំណោះស្រាយឲ្យគេ តើវានឹងជះឥទ្ធិពលយ៉ាងណាដល់សហគមន៍ទាំងមូល?

## ករណីសិក្សា

ចូរចែកសិស្សជាក្រុម។ សូមអានពីករណីសិក្សា និងឲ្យពួកគេឆ្លើយសំណួរពីរខាងក្រោម។ ត្រូវឲ្យសិស្សយល់ច្បាស់ពីបញ្ហាទាក់ទងនឹងការរស់សង្ឃឹម ហើយឲ្យគេដឹងថាមធ្យោបាយដ៏ល្អបំផុតដើម្បីយកឈ្នះលើបញ្ហានេះ គឺមិនគ្រាន់តែជាការជូនរបស់របរមួយចំនួន ប៉ុន្តែគឺការជួយមនុស្សឲ្យធ្វើអ្វីមួយដោយខ្លួនគេ។

មានគ្រួសារមួយរស់នៅក្បែរក្រុមជំនុំរបស់អ្នក។ ប្តីតែងតែទៅរកស៊ីឆ្ងាយបាត់ៗ តែរកលុយបានតិចតួចណាស់ ហើយមួយខែឬពីរខែទើបវិលមកផ្ទះម្តង។ ប្រពន្ធនៅផ្ទះមើលថែទាំកូនបីនាក់ ហើយកូនទាំងបីនាក់នោះសុទ្ធតែមិនបានទៅរៀន។ ជាទម្លាប់ ពួកវាតែងរត់លេងជើងទទេ ហើយស្លៀកសំលៀកបំពាក់ចាស់ៗ។ រីឯផ្ទះរបស់គេវិញទ្រុឌទ្រោម និងស្រក់ទឹកជាច្រើនកន្លែង ពេលមានភ្លៀងធ្លាក់ម្តងៗ។ ស្រាប់តែមានពេលមួយអ្នកបានដើរកាត់ផ្ទះរបស់ពួកគេ ហើយឮសម្រែកក្មេងៗយំឃ្លានបាយ។

**ពិភាក្សានៅក្នុងក្រុមតូច**

តើគ្រួសារនេះមានតម្រូវការអ្វីខ្លះ?



លើសពីនេះទៅទៀតនោះ ស្រ្តីម្នាក់នេះប្រហែលជាមានអារម្មណ៍អស់សង្ឃឹម។ តាមពិតទៅ អ្នកដែលគ្មានការងារធ្វើ មិនមែនសុទ្ធតែខ្ជិលគ្រប់គ្នានោះទេ។ ភាគច្រើនដោយសារតែពួកគេឆ្លងកាត់ការលំបាកក្នុងជីវិតខ្លាំងពេក បាត់បង់ជំនឿចិត្តលើខ្លួនឯងថា គេអាចកែប្រែជីវិតរបស់គេបាន។ ដូច្នេះ ភារៈកិច្ចដ៏សំខាន់របស់យើងគឺជួយឲ្យគេយល់ថា ទោះបីយើងស្ថិតក្នុងស្ថានភាពណាបែបណា ក៏យើងអាចកែប្រែបានដែរ តាមយៈការជួយពួកគេឲ្យចាប់ផ្តើមផ្លាស់ប្រែ។ ការផ្តល់ជាអង្គរបន្តិចបន្តួចដល់គ្រួសារនេះគឺមិនថ្មីនោះទេ តែបើយើងផ្តល់ឲ្យញឹកញាប់ពេក គឺយើងកំពុងតែជំរុញឲ្យគេគិតថាខ្លួនគេពិតជាអស់សង្ឃឹមមែន។ អ្វីដែលគេត្រូវការពិតប្រាកដនោះគឺក្តីសង្ឃឹម ដែលអាចកែប្រែជីវិតរបស់គេបាន។

**ការពិភាក្សានៅក្នុងក្រុមតូច**

បើប្រដូចទៅនឹងអ្នកស្រី លី តើយើងអាចជួយគ្រួសារនេះដោយមធ្យោបាយអ្វីខ្លះ?

មធ្យោបាយដែលយើងអាចជួយរួមមាន

- ជួយឲ្យប្រពន្ធនិងកូនអាចរកចំណូលខ្លះៗ។ តើពួកគេមានដី ឬជំនាញពិសេសណាមួយដែរឬទេ?
- ជួយឲ្យកូនៗបានទៅរៀន។ ជួយនាំម្តាយទៅសុំសាលាឲ្យកូនបានចូលរៀនដោយឥតគិតថ្លៃ ឬពិនិត្យមើលក្រែងមានកម្មវិធីអក្ខរកម្មនៅក្បែរៗតំបន់របស់អ្នក។ ត្រូវស្វែងរកគ្រប់មធ្យោបាយដែលអាចជួយពួកគេបាន។
- ប្រមូលខោអាវដែលប្រើប្រាស់រួចពីសមាជិកក្នុងក្រុមជំនុំ និងព្យាយាមផ្គត់ផ្គង់ខោអាវចាំបាច់មួយចំនួនដល់កូនម្នាក់ៗ។
- ចាប់ផ្តើមចុះទៅសួរសុខទុក្ខស្រ្តីជាម្តាយជាប្រចាំ ហើយលើកទឹកចិត្តឲ្យគាត់ដឹងថាជីវិតគាត់នឹងមានការផ្លាស់ប្តូរ។
- ជួយសង់ផ្ទះដល់គ្រួសារនោះឡើងវិញ។ សុំឲ្យមនុស្សពីរបីនាក់ពីក្រុមជំនុំមកជួយសង់ផ្ទះឡើងវិញ ប៉ុន្តែត្រូវប្រើតែសម្ភារៈដែលមានក្នុងផ្ទះស្រាប់ ហើយឲ្យកូនៗចូលរួមជួយធ្វើការផងដែរ។ ពីព្រោះក្មេងអាយុ ៨ឆ្នាំអញ្ចឹងគឺមានកម្លាំងច្រើន។
- លើកទឹកចិត្តឲ្យគ្រួសារនេះធ្វើសួនតូចមួយដាំបន្លែ ដើម្បីអាចមានអាហារហូបប្រសើរជាងមុន។

- ផ្តល់កូនមាន់ខ្លះឲ្យគ្រួសារនេះចិញ្ចឹម ហើយសុំឲ្យនរណាម្នាក់ពីក្រុមជំនុំបង្រៀនពួកគេពីរបៀបចិញ្ចឹមមាន់។ បើចាំបាច់ ត្រូវទុកមាន់នៅផ្ទះរបស់អ្នក ខ្លាចក្រែងគេឃ្លានពេក នាំគ្នាយកវាធ្វើម្ហូប ហើយសឹមឲ្យកូនម្នាក់របស់គាត់មកប្រមូលយកពងមាន់ និងមើលថែមាន់ជាប្រចាំថ្ងៃ។ អ្នកក៏ត្រូវបង្រៀនពួកគេឲ្យចេះមើលថែមាន់ដែរ។
- ទាក់ទងទៅគ្រួសារខាងប្តី និងខាងប្រពន្ធ។ តើគេអាចជួយអ្វីខ្លះៗបានដែរឬទេ?
- បង្រៀនគ្រួសារនេះឲ្យចេះរៀបចំផែនការចាយវាយលុយដែលប្តីរកបាន។ តើគេអាចយកលុយនោះទៅរកស៊ីអ្វីផ្សេងដែលអាចទទួលបានលុយកាន់តែច្រើន នៅពេលខាងមុខដែរឬទេ? តើគេអាចចាយលុយដោយត្បិតត្បៀត ដើម្បីចាយវាឲ្យបានគ្រប់គ្រាន់គ្រប់ពេលដោយរបៀបណាដែរ?

## អនុវត្តន៍

ចូរធ្វើការជាគូ ដោយនាំគ្នាអធិស្ឋានដើម្បីឲ្យព្រះជាម្ចាស់បង្ហាញអ្នកពីគ្រួសារមួយដែលអ្នកអាចជួយដូចអ្នកស្រីលីដែរ។ ប្រសិនបើគ្រួសារនោះ គឺជាគ្រួសារដែលអ្នកមិនសូវស្គាល់ ចូររៀបចំផែនការទៅសួរសុខទុក្ខពួកគេ។ គ្រប់ពេលមុននឹងអ្នកចេញទៅសួរសុខទុក្ខពួកគេ ត្រូវអធិស្ឋានសុំឲ្យព្រះជាម្ចាស់បើកភ្នែក និងត្រចៀករបស់អ្នក ដើម្បីឲ្យយល់ច្បាស់ពីបញ្ហាជាក់ស្តែង និងដើម្បីឲ្យព្រះអង្គប្រទានគំនិតដល់អ្នកក្នុងការរកវិធីជួយពួកគេ។ ត្រូវបន្តអធិស្ឋានឲ្យគេជាប្រចាំ មិនថាពេលជួយគេ ឬជួយបង្កើតមុខរបរឲ្យគេនោះទេ។ ត្រូវមានចិត្តចង់ទៅសួរសុខទុក្ខគេមួយខែម្តង និងជួយផ្តល់ដំបូន្មានពេញមួយឆ្នាំ។

## មេរៀនទី៩

# សកម្មភាពនៃសេចក្ដីស្រលាញ់

**គោលបំណង**

១. ស្វែងយល់ពីលក្ខណៈសកម្មភាពនៃសេចក្ដីស្រលាញ់។
២. ស្វែងយល់ពីរបៀបដែលសកម្មភាពនៃសេចក្ដីស្រលាញ់អាចនាំការផ្លាស់ប្រែដល់សហគមន៍។
៣. មានគំនិតមួយចំនួនពីអ្វីដែលពួកគេអាចធ្វើបាន ជាសកម្មភាពនៃសេចក្ដីស្រលាញ់។

## សេចក្ដីផ្ដើម

ចែកសិស្សឲ្យធ្វើការជាគូពីរ ពីរនាក់។ នៅក្នុងមួយគូ ពួកគេត្រូវគិតរកមធ្យោបាយមួយចំនួនតាមដែលអាចធ្វើទៅបាន ដែលពួកគេអាចធ្វើនៅក្នុងក្រុមជំនុំ ដោយមិនចំណាយលុយ។ ពួកគេមានពេល៧នាទី ហើយក្រុមណាដែលមានចម្លើយច្រើនជាងគេនឹងទទួលបានរង្វាន់។ ក្រោយពីពេល៣នាទីត្រូវរំឭកឲ្យគេគិតពីរាល់ជំនាញទាំងអស់ដែលមនុស្សនៅក្នុងក្រុមជំនុំមាន ហើយដែលគេអាចបរិច្ចាគបាន។

## សកម្មភាពនៃសេចក្ដីស្រលាញ់

សកម្មភាពនៃសេចក្ដីស្រលាញ់គឺជាគម្រោងតូចៗ ដែលយើងអាចធ្វើបានតាមរយៈក្រុមជំនុំ ដើម្បីបង្ហាញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ ទៅកាន់សហគមន៍របស់ពួកគេ។ ជាធម្មតា វាសាមញ្ញ និងអាចបង្កើយត្រឹមតែមួយថ្ងៃ។

ចែករំលែកសាច់រឿងមួយចំនួនដែលទាក់ទងនឹងសកម្មភាពនៃសេចក្ដីស្រលាញ់។ ឧទាហរណ៍គំរូមួយចំនួន អ្នកអាចរកឃើញនៅក្នុងគេហទំព័ររបស់យើងតាម www.TCTprogram.org/stories

តើអ្វីខ្លះដែលជាលទ្ធផលនៃគម្រោងទាំងអស់នេះ?

- ក្រុមជំនុំត្រូវបានពង្រឹងខ្លាំងឡើង
- សហគមន៍កាន់តែជិតស្និទ្ធជាមួយក្រុមជំនុំ
- មនុស្សមកទទួលជឿលើព្រះគ្រិស្ត
- មនុស្សត្រូវបានជួយ
- ទង្វើនៃសេចក្ដីស្រលាញ់អាចជួយបង្កើតឲ្យគម្រោងកាន់តែធំឡើងៗ

# លក្ខណៈរបស់សកម្មភាពនៃសេចក្ដីស្រលាញ់

## ១. ត្រូវបានធ្វើឡើងដើម្បីបង្ហាញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់

<u>ការពិភាក្សានៅក្នុងក្រុមធំ៖</u>

- តើអ្នកមិនជឿមានចំណាប់អារម្មណ៍បែបណាទៅលើគ្រិស្តបរិស័ទនៅក្នុងសហគមន៍របស់អ្នក? ហេតុអ្វី?
- តើធ្លាប់មានមនុស្សមកចូលរួមក្នុងក្រុមជំនុំ ដោយមិនបានអញ្ជើញដែរឬទេ? បើមាន តើហេតុអ្វី? បើមិនមាន តើហេតុអ្វី?
- តើអ្នកមិនជឿមានចំណាប់អារម្មណ៍បែបណាចំពោះព្រះជាម្ចាស់? តើពួកគេគិតថា ព្រះជាម្ចាស់មានបុគ្គលិកលក្ខណៈបែបណា?

ចូររំឭកនៅក្នុងថ្នាក់ពីមេរៀនដែលត្រូវបានរៀននៅក្នុងមេរៀនទី៣៖ ស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់អ្នកជិតខាង។ យើងត្រូវតែធ្វើជាមនុស្សដែលបង្ហាញសេចក្ដីស្រលាញ់របស់យើងទៅកាន់ព្រះជាម្ចាស់ ដោយស្រលាញ់អ្នកជិតខាងរបស់យើង។

- តើអ្នកគិតថាមនុស្សនៅក្នុងសហគមន៍របស់អ្នក នឹងនិយាយយ៉ាងណា ប្រសិនបើក្រុមជំនុំរបស់អ្នកចាប់ផ្ដើមធ្វើកិច្ចការមួយចំនួនដូចដែលបានរៀបរាប់ក្នុងសាច់រឿងទាក់ទងនឹងសកម្មភាពនៃសេចក្ដីស្រលាញ់?

គន្លឹះចម្បងមួយចំពោះសកម្មភាពនៃសេចក្ដីស្រលាញ់ គឺបង្ហាញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ទៅកាន់សហគមន៍របស់អ្នក។

- តើសកម្មភាពនៃសេចក្ដីស្រលាញ់គួរតែប្រព្រឹត្តចំពោះគ្រិស្តបរិស័ទ ឬអ្នកមិនមែនជាគ្រិស្តបរិស័ទ?

យើងត្រូវតែធ្វើសកម្មភាពនៃសេចក្ដីស្រលាញ់ចំពោះអ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ដោយសារតែពួកគេចាំបាច់ត្រូវតែឃើញពីសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់សម្រាប់ខ្លួនគេ។ មនុស្សជាច្រើននឹងមិនដែលទៅក្រុមជំនុំទាល់តែសោះ ដូច្នេះ វាជាវិធីមួយដែលយើងចេញទៅខាងក្រៅដើម្បីបង្ហាញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ ដែលពួកគេនឹងស្វែងយល់ពីសេចក្ដីស្រលាញ់ចំពោះពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវតែប្រាកដថា យើងក៏ជួយអ្នកនៅក្នុងក្រុមជំនុំដែរ។ យើងសូមលើកចិត្តអ្នកឲ្យចាប់ផ្ដើមជាមួយអ្វីដែលអ្នកអាចបង្ហាញសេចក្ដីស្រលាញ់ ទៅកាន់អ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ឬទៅសហគមន៍ទាំងមូល ប៉ុន្តែអ្នកអាចផ្លាស់ប្ដូរគម្រោងនេះដោយសេរី ដើម្បីជួយដល់អ្នកជឿផងដែរ។

## ២. ត្រូវបានធ្វើឡើងដោយគោរពព្រះជាម្ចាស់

យើងចង់ប្រាកដថា យើងតែងតែដើរដោយគោរពព្រះជាម្ចាស់ចំពោះអ្វីៗទាំងអស់។ ជាជាងធ្វើការស្ទង់មតិនៅក្នុងសហគមន៍ ដើម្បីស្វែងយល់ពីតម្រូវការ និងប្រើប្រាស់វា យើងចង់ចាប់ផ្តើមដំបូងជាមួយនឹងការអធិស្ឋាន និងទូលសុំព្រះជាម្ចាស់សម្រាប់អ្វីដែលទ្រង់ចង់ឲ្យយើងធ្វើ។ ភាគច្រើន ទង្វើនៃសេចក្តីស្រលាញ់ដែលជះឥទ្ធិពលជាងគេ គឺមិនមែនជាអ្វីដែលយើងអាចយល់បាននោះទេ។

នៅក្នុងប្រទេសម៉ិចស៊ិច មានភូមិមួយដែលពោរពេញទៅដោយអ្នកប្រើប្រាស់ថ្នាំញៀន។ មានបេសកជនម្នាក់បានទៅតំបន់នោះ ហើយមនុស្សក៏បានផ្លាស់ប្រែ។ បេសកជននោះនៅតែបន្តអធិស្ឋាន ទាំងតមអាហារជាមួយពួកគេ នៅពេលដែលពួកគេកំពុងតែស្វែងយល់ពីអ្វីដែលព្រះជាម្ចាស់ចង់ឲ្យពួកគេធ្វើ។ នៅក្នុងសហគមន៍របស់ពួកគេ គ្មានបង្គន់ប្រើ គ្មានទឹកស្អាត ហើយសត្វជ្រូក និងសត្វមាន់ដើរចេញចូលពេញផ្ទះ។ នៅពេលដែលពួកគេកំពុងតែអធិស្ឋានអំពី**សកម្មភាពនៃសេចក្តីស្រលាញ់** ព្រះជាម្ចាស់បានបង្ហាញពួកគេថា ពួកគេគួរតែយកចិត្តទុកដាក់ចំពោះស្ត្រីមេម៉ាយ ដោយសាងសង់ផ្ទះសម្រាប់ពួកគេ។ វាខុសប្លែកពីយោបល់របស់មនុស្សគ្រប់គ្នាដែលបានផ្តល់ឲ្យមកពួកគេ។ នៅក្នុងវប្បធម៌របស់ពួកគេ អ្នកដឹកនាំគឺពិតជាសំខាន់ខ្លាំងណាស់ ប៉ុន្តែផ្ទះរបស់ពួកគេគឺមិនសូវមានគុណភាពរឹងមាំប៉ុន្មានទេ។ មនុស្សគ្រប់គ្នាទៅក្នុងសហគមន៍ បានផ្តល់យោបល់ឲ្យពួកគេចាប់ផ្តើមសាងសង់ផ្ទះថ្មីសម្រាប់អ្នកដឹកនាំ។ ប៉ុន្តែ ព្រះជាម្ចាស់វិញ បានត្រាស់ហៅពួកគេឲ្យយកចិត្តទុកដាក់ចំពោះស្ត្រីមេម៉ាយ។ ពួកគេក៏ស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយសាងសង់ផ្ទះថ្មីដល់ស្ត្រីមេម៉ាយ។ ជាលទ្ធផល មនុស្សដែលនៅភូមិជិតនោះ បានឮពីគម្រោងដែលពុំធ្លាប់មាននេះ ហើយពួកគេក៏បានមកស្វែងយល់បន្ថែម។ បន្ទាប់មក ក៏មានការផុសផុលមួយកើតមានឡើងនៅក្នុងតំបន់របស់ពួកគេ ដែលមានមនុស្សជាច្រើនបានថ្វាយជីវិតទៅកាន់ព្រះអម្ចាស់។ ប្រសិនបើពួកគេបានធ្វើតាមអ្វីដែលមនុស្សគ្រប់គ្នារំពឹងទុកនោះ ពួកគេនឹងមិនឃើញពីការជះឥទ្ធិពលនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែពួកគេស្តាប់បង្គាប់តាមព្រះជាម្ចាស់ មិនមែនវប្បធម៌របស់ពួកគេទេ ជាលទ្ធផលគឺមិនគួរឲ្យជឿឡើយ។

នៅក្នុងប្រទេសមួយទៀត ក្រុមជំនុំបានសម្រេចចិត្តធ្វើសកម្មភាពនៃសេចក្តីស្រលាញ់មួយ។ ពួកគេមានអារម្មណ៍ថា ព្រះជាម្ចាស់កំពុងតែប្រាប់ពួកគេឲ្យជួយប្រពន្ធរបស់បងធំ ក្មេងទំនើងនៅក្នុងតំបន់នោះ។ ពួកគេបានភ័យខ្លាចជាខ្លាំង ដោយសារតែបងធំនោះ ល្បីថាឆាប់ខឹង និងវាយមនុស្សដោយសារតែរឿងតូចតាច។ ទោះបីជាយ៉ាងណាក៏ដោយ ពួកជំនុំចង់ស្តាប់បង្គាប់ព្រះជាម្ចាស់។ ពួកគេរង់ចាំទាល់តែមានពេលមួយ ដែលបងធំក្មេងទំនើងចេញក្រៅក្រុង ហើយពួកគេក៏បានជួយប្រពន្ធបងធំនោះប្រមូលផលនៅក្នុងចម្ការ ហើយរៀបចំផលដំណាំដើម្បីយកទៅលក់។ នៅពេលដែលបងធំក្មេងទំនើងនោះត្រឡប់មកផ្ទះវិញ គាត់បានឃើញផលដំណាំបានប្រមូលរួចរាល់ហើយ ក៏ស្រែកថា «អាណាធ្វើទាំងអស់នេះ?» នាងខ្លាច

មិនហ៊ានប្រាប់គាត់នោះទេ ហើយខ្លាចថាគាត់នឹងបង្ករឿង ហើយចុងក្រោយនាងក៏សារភាពថាពួកជំនុំបានជួយគាត់។ បងធំក្មេងទំនើងនោះ ក៏ស្ទុះចេញទៅក្រុមជំនុំ ហើយបុកទ្វារ។ គ្រូគង្វាលក៏បានឆ្លើយ (បន្ទាប់ពីសម្រែកហៅគ្រូគង្វាល និងអ្នកដឹកនាំ) រួចបងធំនោះក៏ដើរចូលមក។ «ហេតុអ្វីបានជាលោកធ្វើអញ្ចឹង?» គាត់សួរ។ ពួកគេឆ្លើយតបថា ពួកគេគ្រាន់តែចង់បង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។ បុរសម្នាក់នោះក៏ចាប់ផ្តើមយំ ហើយនិយាយថាគ្មាននរណាធ្លាប់ស្រលាញ់គាត់ពីមុនទេ នៅក្នុងជីវិតរបស់គាត់។ គាត់ក៏បានក្លាយជាគ្រិស្តបរិស័ទ ហើយបានផ្លាស់ប្រែជីវិតរបស់គាត់ និងបានទៅនាំក្រុមគ្រួសារបងធំផ្សេងទៀតមកទទួលជឿលើព្រះគ្រិស្តដែរ។

- តើក្រុមជំនុំបានសម្រេចចិត្តបង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ទៅកាន់អ្នកណា?
- តើអ្វីជាការជះឥទ្ធិពល ឬការផ្លាស់ប្រែនៅក្នុងសហគមន៍នោះ?

### ៣. ត្រូវបានធ្វើតាមរយៈកម្លាំងរបស់ព្រះជាម្ចាស់

សូមមើល យ៉ូហាន ១៥៖១-៨

- តើយើងអាចធ្វើបានដោយខ្លួនឯងច្រើនប៉ុណ្ណា?
- តើយើងអាចបង្កើតផលផ្លែបានច្រើនប៉ុណ្ណា?
  ការជួយដល់មនុស្ស គឺពិតជាពិបាកខ្លាំងណាស់។ មានតែព្រះជាម្ចាស់ទេ ដែលអាចនាំការផ្លាស់ប្រែដែលយើងចង់ឃើញនៅក្នុងសហគមន៍របស់យើង។ ប្រសិនបើយើងចង់ឃើញសហគមន៍របស់យើងផ្លាស់ប្រែតាមរយៈគម្រោងទាំងអស់នេះ យើងចាំចាច់ត្រូវសម្លឹងទៅព្រះជាម្ចាស់ ហើយសុំជំនួយពីទ្រង់។
- នៅក្នុងគម្ពីរយ៉ូហាន ១៥៖៥ ចែងថា៖ «ខ្ញុំនេះហើយជាដើមទំពាំងបាយជូរ អ្នករាល់គ្នាជាមែក អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នកនោះបង្កើតផលបានច្រើន»។ តើគិតថាពាក្យ *ស្ថិតនៅជាប់* នឹងព្រះជាម្ចាស់មានអត្ថន័យដូចម្តេច?
  ការអានព្រះគម្ពីរគឺដើម្បីស្វែងរកសេចក្តីពិតរបស់ព្រះជាម្ចាស់។ ការសុំទិសដៅ និងការណែនាំនឹងជួយឲ្យអ្នកយល់ពីតម្រូវការរបស់សហគមន៍របស់អ្នក។ ចូរស្វែងរកព្រះជាម្ចាស់ដោយស្មោះត្រង់នៅក្នុងការអធិស្ឋាន និងស្តាប់យ៉ាងយកចិត្តទុកដាក់នូវព្រះប្រាជ្ញាញាណរបស់ទ្រង់។ ចូរទូលសុំឲ្យព្រះជាម្ចាស់ប្រទានមកឲ្យអ្នកនូវកម្លាំង ដើម្បីបន្តប្រព្រឹត្តគម្រោងសកម្មភាពនៃសេចក្តីស្រលាញ់។
  នៅពេលដែលយើងស្វែងរកព្រះជាម្ចាស់តាមការអធិស្ឋាន សូមស្តាប់ និងស្ថិតនៅជាប់នឹងទ្រង់ ដើម្បីឲ្យយើងអាចទុកចិត្តនឹងពេលវេលាដែលគម្រោងរបស់យើងនឹងទទួលបានផលផ្លែ។
- តើយើងអាចទុកចិត្តលើកម្លាំងរបស់ព្រះជាម្ចាស់ក្នុងគម្រោងទាំងនេះបានដោយរបៀបណា?
  យើងគួរតែអធិស្ឋាននៅមុនពេល កំឡុងពេល និងពេលបន្ទាប់ពីធ្វើគម្រោងនោះហើយ។

**៤. ធ្វើបានដើម្បីឲ្យព្រះជាម្ចាស់ទទួលការសរសើរ**

សូមអាន យ៉ូហាន ១៥៖៨

- តើយើងបង្កើតផលផ្លែឲ្យបានច្រើនក្នុងគោលបំណងអ្វី?

សូមអាន ម៉ាថាយ ៥៖១៣-១៦

- ហេតុអ្វីបានជាយើងធ្វើអំពើល្អ?
- តើអ្វីគួរតែជាគោលដៅរបស់យើង នៅពេលដែលយើងធ្វើទង្វើនៃសេចក្តីស្រលាញ់?

បន្ទាប់ពីធ្វើគម្រោងនីមួយៗ យើងគួរតែចំណាយពេលវាយតម្លៃ។ តើគម្រោងនេះផ្តល់លទ្ធផលអ្វី? សូមគិតពីបីចំណុចនេះ៖

១. តើបានជួយដល់មនុស្សដែរឬទេ?

២. តើគម្រោងនេះបានបញ្ចប់ទៅក្នុងរបៀបដែលផ្តល់សេចក្តីស្រលាញ់ដែរឬទេ?

៣. តើព្រះជាម្ចាស់បានទទួលការសរសើរដែរឬទេ?

តាមការពិត មិនមែនគ្រប់ពេលដែលយើងធ្វើសកម្មភាពនៃសេចក្តីស្រលាញ់ នឹងផ្តល់ឱកាសឲ្យយើងនិយាយចែកចាយពីព្រះជាម្ចាស់ទេ ប៉ុន្តែវាគួរតែជាបំណងចិត្តរបស់យើង ដែលប្រាកដថាយើងកំពុងតែថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់គ្រប់ពេល និងធ្វើអ្វីៗនៅក្នុងរបៀបដែលថ្វាយព្រះកិត្តិយលដល់ទ្រង់។

**៥. តូច ហើយសាមញ្ញ**

នៅពេលដែលអ្នកចាប់ផ្តើមប្រព្រឹត្តសកម្មភាពនៃសេចក្តីស្រលាញ់ យើងសូមលើកទឹកចិត្តអ្នកឲ្យជ្រើសរើសអ្វីៗដែលសាមញ្ញ។ ល្អបំផុតនោះ សកម្មភាពទាំងនោះគួរតែអាចបញ្ចប់ក្នុងពេលមួយថ្ងៃបាន។

- ហេតុអ្វីបានអ្នកគិតថា វាជាការសំខាន់ក្នុងការដែលចាប់ផ្តើមសកម្មភាពនៃសេចក្តីស្រលាញ់ពីតូច ហើយសាមញ្ញ?
    - អាចសម្រេចវាបាន។ ប្រសិនបើយើងធ្វើអ្វីមួយធំ នោះយើងងាយនឹងមានអារម្មណ៍ថាវាលើសលប់ពេក និងពិបាកក្នុងការសម្រេចបាននូវគោលបំណងដែលយើងចង់បាន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើយើងធ្វើអ្វីមួយតូច ហើយសាមញ្ញ នោះយើងនឹងអាចធ្វើបានសម្រេច។
    - មានមនុស្សច្រើនអាចជួយបាន។ វាងាយស្រួលដល់មនុស្សក្នុងការចុះឈ្មោះសម្រាប់គម្រោងតូច ហើយប្តេជ្ញាធ្វើវា ប្រសិនបើពួកគេដឹងថាវាត្រឹមតែមួយថ្ងៃ និងកន្លះថ្ងៃ។ ពួកគេនឹងនិយាយថា «អូហ៎ ខ្ញុំអាចធ្វើវាបាន។ ខ្ញុំទំនេរនៅសៀលហ្នឹង។» ប៉ុន្តែប្រសិនបើវាជាគម្រោងធំវិញ វាត្រូវចំណាយជាច្រើនថ្ងៃដើម្បីសម្រេចវាបាន ហើយមនុស្សក៏នឹងរុញ

រាក្នុងការប្តេជ្ញាចិត្តប្រើប្រាស់ពេលវេលា និងធនធានរបស់ពួកគេ ជាពិសេសដោយសារតែគំនិតនៃការធ្វើអ្វីសម្រាប់នរណាម្នាក់ នៅថ្មីសម្រាប់ពួកគេនៅឡើយ។

- ឱកាសដើម្បីកសាងជំនាញរបស់យើង។ ប្រហែលជាយើងមិនមានបទពិសោធន៍ច្រើនក្នុងការធ្វើគម្រោងនេះទេ។ វានឹងផ្តល់ឱកាសឲ្យយើងដើម្បីធ្វើអ្វីដែលស្រដៀងគ្នា និងទទួលបានបទពិសោធន៍ មុននឹងយើងព្យាយាមធ្វើអ្វីដែលស្មុគស្មាញច្រើន។
- ឆាប់ទទួលបានជោគជ័យ។ នៅពេលដែលយើងទទួលបានជោគជ័យនៅក្នុងគម្រោងតូចៗ យើងអាចទាក់ទាញមនុស្សផ្សេងទៀតឲ្យចូលរួមបន្ថែមតាមរយៈជោគជ័យរបស់យើង។ ប្រហែលជានៅពេលដែលយើងទើបតែចាប់ផ្តើមដំបូង មានតែពួកជំនុំពីរបីនាក់ប៉ុណ្ណោះ ដែលចាប់អារម្មណ៍នឹងការជួយ ប៉ុន្តែនៅពេលដែលអ្នកកាន់តែបង្រៀន និងគំរូនៃគម្រោងកាន់តែទទួលបានជោគជ័យ នោះមនុស្សជាច្រើននឹងចាប់អារម្មណ៍ចូលរួម។

វាជាការប្រសើរក្នុងការដែលធ្វើសកម្មភាពនៃសេចក្តីស្រលាញ់តូចៗ ហើយញឹកញាប់ (មួយអាទិត្យម្តង ឬពីរអាទិត្យម្តង) ជាជាងការធ្វើគម្រោងធំតែមួយ ហើយឈប់។ លើសពីនេះទៅទៀត គុណសម្បត្តិនៃការការធ្វើទង្វើនៃសេចក្តីស្រលាញ់តូចៗ ដូចដែលបានរៀបរាប់ខាងលើ ហើយធ្វើគម្រោងនោះជាញឹកញាប់ វានឹងជិតនៅជាប់ក្នុងដួងចិត្តរបស់ប្រជាជនក្នុងសហគមន៍ ថាក្រុមជំនុំយកចិត្តទុកដាក់ជាមួយពួកគេ។

**៦. ធ្វើបានដោយប្រើធនធានក្នុងតំបន់**

- ហេតុអ្វីបានជាអ្នកគិតថា កិច្ចការដែលយើងត្រូវធ្វើជាមុននៅក្នុងសកម្មភាពនៃសេចក្តីស្រលាញ់ គឺធ្វើឡើងដោយប្រើធនធានក្នុងតំបន់ មិនមែនក្រៅតំបន់ ជាធនធានដែលព្រះជាម្ចាស់បានប្រទានមកឲ្យអ្នកហើយ? ហេតុអ្វីបានជាអ្នកគិតថាវាសំខាន់?
  - វាបង្ហាញសេចក្តីស្រលាញ់ច្រើនជាង។
    - សូមគិតពីរឿងរ៉ូបសារី (រ៉ូបរបស់ជនជាតិឥណ្ឌា) នៅក្នុងមេរៀនទី៥។ តើអ្នកគិតថាមានទទួលបានឥទ្ធិពលដូចគ្នាដែរឬទេ ប្រសិនបើគ្រាន់តែមានអង្គការធំមួយ ឧបត្ថម្ភសារីទៅកាន់សហគមន៍? ទេ វាមិនដូចគ្នាទេ។
    - ហេតុអ្វីបានជាមនុស្សមានអារម្មណ៍ពីសេចក្តីស្រលាញ់?
      គឺដោយសារតែពួកគេបានឃើញសេចក្តីស្រលាញ់របស់មនុស្សដែលបានលះបង់នោះ។ ប្រសិនបើសហគមន៍មិនបានឃើញពីការលះបង់ ឬការខិតខំប្រឹងប្រែងដើម្បីធ្វើវានោះទេ ពួកគេនឹងមិនឃើញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ទៅកាន់ពួកគេក្នុងរបៀបដូចគ្នាឡើយ។
  - ព្រះពរនៃការឲ្យ។ សូមអាន ២ កូរិនថូស ៩៖៦-១១។ ព្រះជាម្ចាស់បានប្រាប់យើងថាទ្រង់នឹងប្រទានពរដល់អ្នកដែលឲ្យ ក្នុងរង្វាស់ដូចដែលយើងឲ្យ។ ទោះបីជាយ៉ាងណាក៏ដោយ ចូរពិនិត្យមើលខគម្ពីរទាំងនេះម្តងទៀត។
    - ហេតុអ្វីបានជាព្រះជាម្ចាស់ប្រទានពរដល់យើង?

ដើម្បីឲ្យយើងបានបង្ហាញពីសន្តានចិត្តដ៏ល្អនៅគ្រប់ឱកាស។

ដើម្បីឲ្យព្រះជាម្ចាស់បានទទួលការសរសើរ។

នៅពេលដែលក្រុមជំនុំមានចិត្តសប្បុរស នោះយើងឃើញថាពួកគេបានទទួលព្រះពរពីព្រះជាម្ចាស់។ ពួកគេចាប់ផ្តើមចាកចេញពីភាពក្រីក្រ។ ប៉ុន្តែ អ្វីដែលសំខាន់ជាងនេះទៅទៀត នោះគឺពួកគេកាន់តែមានចិត្តសប្បុរស ដើម្បីធ្វើគម្រោងកាន់តែច្រើនទៀត។ វាជាវដ្តដ៏អស្ចារ្យមួយ ដែលនាំសហគមន៍ចេញពីភាពក្រីក្រ។

- តើអ្នកគិតថា យើងនឹងទទួលបានលទ្ធផលដូចគ្នាដែរឬទេ ប្រសិនបើយើងបានប្រើប្រាស់ធនធានខាងក្រៅ?

  វាមិនដូចគ្នាទេ។ ព្រះជាម្ចាស់បានសន្យាថានឹងប្រទានពរដល់អស់អ្នកដែលឲ្យ មិនមែនអ្នកដែលទទួលនោះទេ។ ប្រសិនបើយើងគ្រាន់តែទទួល នឹងយើងនឹងមិនបានឃើញការពហុគុណរបស់ព្រះជាម្ចាស់ លើការខិតខំប្រឹងប្រែងរបស់យើង ហើយនឹងបាត់បង់ព្រះពរមួយចំនួនដែលទ្រង់បានសន្យា។

ការប្រើប្រាស់ធនធានខាងក្រៅអាចធ្វើឲ្យជួបបញ្ហាប្រឈមធំៗមួយចំនួន។ ឧទាហរណ៍ នៅក្នុងតំបន់របស់យើងមនុស្សកំពុងតែមានមន្ទិលសង្ស័យជាមួយក្រុមជំនុំច្រើន។ វាមិនជារឿងចម្លែកសម្រាប់មនុស្សដែលលសង្ស័យថា ក្រុមជំនុំបាននាំយកធនធានខាងក្រៅមួយចំនួនសម្រាប់ខ្លួនគេ ហើយគេផ្តល់តែមួយផ្នែកប៉ុណ្ណោះដល់សហគមន៍។ មូលនិធិខាងក្រៅអាចបង្កបញ្ហាដល់ក្រុមជំនុំ។ ទោះបីជានៅក្នុងក្រុមជំនុំក៏ដោយ សាតាំងក៏ប្រើប្រាស់ធនធានខាងក្រៅដើម្បីបង្កើតឲ្យមានការសង្ស័យ និងបែកបាក់សាមគ្គីនៅក្រុមជំនុំដែរ។

- ចុះប្រសិនបើយើងគ្មានធនធានអ្វីនោះ?
  - យើងមាន។ យើងត្រូវតែបើកភ្នែករបស់យើងឲ្យឃើញនូវអ្វីដែលបានព្រះជាម្ចាស់បានប្រទានមកឲ្យយើង។ តើនៅក្នុងសហគមន៍របស់យើងមានជំនាញអ្វីខ្លះ? (កសិករ គ្រូបង្រៀន គ្រូពេទ្យ វិស្វករ ជាងសំណង់ ជាងដេរ...)។ យើងត្រូវតែអនុវត្ត ដើម្បីមើលឲ្យឃើញអ្វីដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើង។
  - ២ ពេត្រុស ១៖៣-៥ ចែងពីសេចក្តីពិតដែលថា ព្រះជាម្ចាស់បានប្រទានឲ្យយើងនូវអ្វីៗទាំងអស់ទាំងអស់ សម្រាប់ជីវិតរស់នៅ និងសម្រាប់គោរពប្រណិបតន៍ទ្រង់។ យើងត្រូវតែបើកភ្នែករបស់យើងឲ្យមើលឃើញ និងប្រើប្រាស់អ្វីដែលយើងទទួលបានដើម្បីថ្វាយសិរីរុងរឿងដល់ទ្រង់។

## អនុវត្តន៍

សូមសញ្ជឹងគិតលើគំនិតទាំងប៉ុន្មាន ដែលបានរៀបរាប់នៅក្នុងលំហាត់ដំបូងនៃមេរៀននេះ។ ចូរចាប់ដៃគូពីរៗនាក់ម្តងទៀត ហើយរើសសកម្មភាពបីដើម្បីវាយតម្លៃ។ បន្ទាប់មក សូមពិចារណាលើសំណួរដូចខាងក្រោមៈ

១. តើសកម្មភាពនេះ ជួយអ្នកឲ្យបង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ទៅកាន់សហគមន៍ដោយរបៀបណា? តើយើងគួរតែបន្ថែមអ្វី ហើយផ្លាស់ប្តូរអ្វីនៅក្នុងសកម្មភាពនេះ ដើម្បីបង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ឲ្យបានកាន់តែប្រសើរឡើង?

២. តើវាជាគម្រោងតូច ហើយសាមញ្ញដែលអាចសម្រេចបានត្រឹមមួយថ្ងៃឬ?

៣. តើធនធានដែលត្រូវការដើម្បីសម្រេចគម្រោងនេះ អាចរកបាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ?

៤. តើសកម្មភាពនេះ អាចផ្លាស់ប្រែសហគមន៍ដូចម្តេចខ្លះ? តើប្រភេទនៃការផ្លាស់ប្រែនេះ ជាអ្វីដែលអ្នកចង់ឃើញនៅក្នុងសហគមន៍របស់អ្នកដែរឬទេ? ប្រសិនបើមិនមែន តើសកម្មភាពនេះនឹងនាំឲ្យមានឥទ្ធិពលប្រសើរនៅក្នុងសហគមន៍របស់អ្នកដែរឬទេ?

៥. តើអ្នកគិតថា ព្រះជាម្ចាស់នឹងត្រូវបានថ្វាយសិរីរុងរឿងដែរឬទេ នៅពេលដែលសកម្មភាពមួយនេះបានសម្រេច?

## មេរៀនទី១០

# ការរៀបចំផែនការ សកម្មភាពនៃសេចក្ដីស្រលាញ់

**គោលបំណង**

១. យល់ពីរបៀបរៀបចំផែនការកម្មភាពនៃសេចក្ដីស្រលាញ់។
២. ជ្រើសរើសសកម្មភាពនៃសេចក្ដីស្រលាញ់ ដើម្បីធ្វើនៅក្នុងតំបន់របស់ពួកគេ។
៣. បង្កើតផែនការ។

ចូរចែកសិស្សជាក្រុមមានគ្នា ៥ ទៅ ៧ នាក់ដើម្បីរៀបចំផែនការ។

ត្រូវចាប់ផ្ដើមដោយឲ្យសិស្សអានកំណត់ចំណាំនៅក្នុងសៀវភៅរបស់គេ។ បន្ទាប់មក សូមមើលក្រែងគេមានសំណួរណាមួយ។ ក្រោយមក ចូរឲ្យពួកគេចាប់ផ្ដើមគិតធ្វើផែនការពីអ្វីដែលគេត្រូវធ្វើនៅក្នុងសកម្មភាពនៃសេចក្ដីស្រលាញ់។ ក្រោយរយៈពេល ៥នាទី ត្រូវឲ្យសិស្សឈប់ រួចសួរពួកគេពីផែនការដែលគេចង់ធ្វើ។ ត្រូវធ្វើឲ្យប្រាកដថាផែនការនីមួយៗស្របតាមលក្ខណៈសកម្មភាពនៃសេចក្ដីស្រលាញ់។ ជារឿយៗ សិស្សមានមហិច្ឆតាធំ ហើយគេធ្វើផែនការចេញជាគម្រោងធំជ្រុល។ ដូច្នេះ ត្រូវលើកទឹកចិត្តឲ្យគេជ្រើសយកគម្រោងណាដែលតូចល្មម ព្រោះថាគម្រោងកាន់តែតូច គឺគេអាចអនុវត្តបានជាក់ស្ដែង និងឆាប់ទទួលបានជោគជ័យ។ ផ្ទុយមកវិញ អ្នកដែលចាប់ផ្ដើមដោយគម្រោងធំ គឺអាចឆាប់នឹងទទួលបរាជ័យ ហើយបាក់ទឹកចិត្ត។

ចូរចែកក្រដាសមួយផ្ទាំងធំឲ្យក្រុមនីមួយៗ ដើម្បីឲ្យគេសរសេរគម្រោងរបស់គេនៅលើនោះ រួចឲ្យគេចែកចាយគំនិតទាំងនោះជាមួយសិស្សផ្សេងទៀត។ ពេលគេធ្វើបទបង្ហាញ ចូរឲ្យសិស្សផ្សេងទៀតចូលរួមស្ដាប់ និងរកបញ្ហាដែលអាចកើតមាន ដើម្បីឲ្យក្រុមទាំងនោះមានឱកាសកែប្រែផែនការរបស់គេឲ្យកាន់តែប្រសើរឡើង។ សូមជួយឲ្យពួកគេឃើញចំណុចមួយចំនួន ដែលគេគិតមិនទាន់បានគិតដល់នៅឡើយ។

# ជំហាននៃការរៀបចំផែនការ

**ជំហានទី១៖ អធិស្ឋាន**

រឿងដំបូងដែលត្រូវធ្វើមុនគេគឺអធិស្ឋាន។ ឥឡូវត្រូវចំណាយពេលអធិស្ឋាន។ ចូរទូលសុំឲ្យព្រះជាម្ចាស់បង្ហាញ ពីអ្វីដែលអ្នកគួរធ្វើ សម្រាប់សកម្មភាពនៃសេចក្ដីស្រលាញ់។

**ជំហានទី២៖ ជ្រើសយកសកម្មភាពមួយ**

ចូរសម្រេចចិត្តជាក្រុមជ្រើសរើសយកសកម្មភាពមួយដែលយើងអាចធ្វើ ជាសកម្មភាពនៃសេចក្ដីស្រលាញ់។ សូមស្រង់យកគំនិតខ្លះៗពីមេរៀន «ព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំជួយដល់សហគមន៍» និងមេរៀន «តើអ្វីខ្លះជាតម្រូវការនៅក្នុងសហគមន៍?»។ រួចសម្រេចយកមតិរួមគ្នាធ្វើនូវអ្វីដែលអ្នកមានអារម្មណ៍ ថាព្រះជាម្ចាស់កំពុងដឹកនាំឲ្យអ្នកធ្វើ។

នៅពេលអ្នកសម្រេចយកប្រធានបទណាមួយហើយ ត្រូវឲ្យប្រាកដថា វាជាប្រធានបទដែលអ្នកអាចធ្វើបានជោគជ័យក្នុងរយៈពេលមួយ ឬពីរថ្ងៃ។ ប្រសិនបើមិនដូច្នោះទេ តើអ្នកអាចធ្វើវាមួយជំហាន ឬពីរជំហានសិនបានដែរឬទេ?

**ជំហានទី៣៖  សម្រេចចិត្តពីអ្វីដែលត្រូវការ**

ជំហានបន្ទាប់មកទៀតគឺត្រូវចាប់ផ្ដើមរៀបចំផែនការតែម្ដង។ ជាដំបូងយើងត្រូវសម្រេចចិត្តមើលថា យើងចាំបាច់ត្រូវការអ្វីខ្លះដើម្បីអនុវត្តន៍គម្រោង ដែលក្នុងនោះរួមមានដូចជា តើត្រូវការមនុស្សប៉ុន្មាននាក់ សម្ភារៈអ្វីខ្លះ និងត្រូវសុំការអនុញ្ញាត្តិពីនរណាខ្លះជាដើម។ ដើម្បីជួយឲ្យអ្នកគិតបានច្បាស់លាស់ អ្នកអាចប្រើក្រដាសលំហាត់នៅក្នុងសៀវភៅសិស្ស។ ពេលអ្នកសរសេរបំពេញពីអ្វីដែលអ្នកត្រូវការនៅក្នុងតារាងរួចហើយ អ្នកអាចសម្រេចចិត្តថា តើនរណាគួរតែជាអ្នកទទួលខុសត្រូវ និងត្រូវចាប់ផ្ដើមអនុវត្តន៍គម្រោងនោះនៅពេលណា។

**ជំហានទី៤៖ សរសេរពីផែនការ**

ត្រូវប្រាកដថា ផែនការរបស់អ្នកឆ្លើយសំណួរខាងក្រោមនេះ។ (ប្រសិនបើក្រុមនោះ មិនសូវចេះអក្សរ គឺមិនចាំបាច់ត្រូវសរសេរផែនការនោះឡើងទេ ប៉ុន្តែត្រូវប្រាកដថា ពួកគេបានពិភាក្សាសំណួរទាំងអស់នេះដូចគ្នា)។

- តើអ្នកនឹងធ្វើអ្វី?
- តើអ្នកត្រូវការអ្វីខ្លះ ដើម្បីធ្វើវា? តើយើងនឹងអាចយកសម្ភារៈទាំងអស់នោះមកពីណា?
- តើអ្នកនឹងទៅជួយនរណា? តើអ្នកបានសុំពួកគេជាមុនដែរឬទេ?
- តើនរណាខ្លះនឹងចូលរួមជួយ?
- តើអ្នកនឹងធ្វើវានៅថ្ងៃណា?

**ជំហានទី៥៖ អធិស្ឋាន**

នៅពេលសរសេរផែនការចប់សព្វគ្រប់ហើយ អ្នកត្រូវចំណាយពេលអធិស្ឋានម្តងទៀត។ ចូរទូលសុំឲ្យព្រះជាម្ចាស់ជួយអ្នកឲ្យសម្រេចបានលើគម្រោងនោះ និងបង្កើនផលផ្លែឲ្យបានច្រើន។ អធិស្ឋានថាព្រះនាមទ្រង់នឹងត្រូវបានទទួលសិរីរុងរឿង។ ក្នុងអំឡុងពេល ១ ឬ ២ សប្តាហ៍ក្រោយមកទៀត នៅពេលកំពុងរៀបចំគម្រោង អ្នកគួរតែបន្តអធិស្ឋានដើម្បីឲ្យព្រះជាម្ចាស់ជួយអ្នកជាមួយគម្រោងនោះ។

**ជំហានទី៦៖ អនុវត្តន៍គម្រោង**

ជំហានបន្ទាប់ គឺត្រូវអនុវត្តនូវគម្រោងដែលអ្នកបានធ្វើផែនការរួច។ ត្រូវចាប់ផ្តើមអនុវត្តន៍ដោយការអធិស្ឋាន និងថ្វាយរាល់ការខិតខំប្រឹងប្រែងទៅកាន់ព្រះជាម្ចាស់។ ត្រូវចងចាំថា មូលហេតុដែលអ្នកធ្វើគម្រោងនេះ គឺដើម្បីបង្ហាញពីក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់សហគមន៍របស់អ្នក។ ហើយត្រូវរក្សាចិត្តគំនិតដែលស្របនឹងគោលបំណងនេះ។

**ជំហានទី៧៖ ត្រូវវាយតម្លៃ និងរាយការណ៍ពីគម្រោង**

ជំហានចុងក្រោយបង្អស់គឺត្រូវវាយតម្លៃ និងរាយការណ៍ពីគម្រោង។ ហេតុអ្វីបានជាយើងត្រូវវាយតម្លៃ? ដោយសារវាជួយឲ្យយើងរៀនបានបន្ថែមទៀត។ យើងអាចគិតអំពីអ្វីដែលយើងធ្វើបានល្អប្រសើរ និងអ្វីដែលយើងអាចកែប្រែសម្រាប់គម្រោងក្រោយៗទៀត។ អ្នកមិនចាំបាច់ត្រូវចំណាយពេលវេលាច្រើន ដើម្បីវាយតម្លៃនោះទេ គឺអ្នកអាចចំណាយពេលត្រឹមតែ ២ ទៅ ៣នាទីដើម្បីពិភាក្សាសំណួរខាងក្រោមជាការស្រេច៖

- តើអ្វីខ្លះដែលដំណើរការបានល្អ?
- តើអ្វីខ្លះដែលដំណើរការមិនបានល្អ?
- តើគម្រោងនេះត្រូវការការកែប្រែអ្វីខ្លះ?
- តើលទ្ធផលដូចតាមបំណងដែលបានគិតទុកដែរឬទេ? បើមិនដូច មកពីមូលហេតុអ្វី?
- តើព្រះជាម្ចាស់ទទួលបានសិរីរុងរឿងដែរឬទេ?

គ្រូបណ្តុះបណ្តាលមានទម្រង់របាយការណ៍គម្រូសម្រាប់សិស្ស។ ហេតុអ្វីបានជាយើងត្រូវធ្វើរបាយការណ៍? នៅក្នុងគម្ពីរ ម៉ាកុស ៦៖៣០ បានចែងថា ពួកសាវ័ករបស់ព្រះយេស៊ូបានរាយការណ៍ប្រាប់ព្រះអង្គគ្រប់សកម្មភាពទាំងអស់ដែលគេបានធ្វើ។ យើងធ្វើរបាយការណ៍ដើម្បីបង្ហាញពីភាពស្មោះត្រង់និងការដឹងគុណដល់អ្នកដែលបានបង្រៀន និងរៀបចំសម្ភារៈ និងផ្តល់គ្រូបណ្តុះបណ្តាលដល់យើង។ ការរាយការណ៍ផ្តល់ឱកាសឲ្យអ្នកចែកចាយពីអ្វីដែលអ្នកបានធ្វើ ក៏ដូចជាចែកចាយពីទីបន្ទាល់នូវអ្វីដែលព្រះជាម្ចាស់បានប្រើប្រាស់អ្នកក្នុងគម្រោងនោះ។ ម្យ៉ាងវិញទៀត វាក៏ផ្តល់ឱកាសដល់គ្រូបណ្តុះបណ្តាលឲ្យឃើញពីបញ្ហា និងស្វែងរកមធ្យោបាយដើម្បីកែតម្រូវឲ្យកាន់តែប្រសើរឡើងពេលអនាគត។

## ឧបសម្ព័ន្ធទី១៖ ដំណើររឿងរបស់លោកគ្រូគង្វាល វ៉ង់ ( Wong)

មានលោកគ្រូគង្វាលម្នាក់ ស្ថិតនៅក្នុងក្រុមជំនុំក្រីក្រតូចមួយ ស្ថិតនៅក្នុងតំបន់ក្រីក្រនៃទីក្រុងដ៏ធំមួយ។ គាត់មានឈ្មោះថារ៉ង់។ លោកគ្រូ រ៉ង់ ទើបតែផ្លាស់ទីលំនៅមកសហគមន៍នោះ ដោយសារតែគាត់មានអារម្មណ៍ថាព្រះជាម្ចាស់បានចាត់គាត់ឲ្យមកទីនោះ។ ក្រុមជំនុំនោះតូច មានសមាជិកតែ៤០នាក់ប៉ុណ្ណោះ ហើយភាគច្រើនសុទ្ធតែស្ត្រី និងក្មេងៗ។ លោកគ្រូរ៉ង់ មានការងារពីរ។ គាត់ធ្វើការបន្ថែមដោយសារតែការងារនោះអាចផ្គត់ផ្គង់ដល់ប្រពន្ធ និងកូនតូចៗពីរនាក់របស់គាត់ ហើយគាត់ក៏បានធ្វើជាគ្រូគង្វាលម្នាក់ដ៏ល្អ ចំពោះកូនចៀមរបស់គាត់។

នៅថ្ងៃមួយ ជាទម្លាប់របស់គាត់ គឺគាត់បានសម្រាកពីការងារ នាពេលថ្ងៃនឹងមានពេលវេលាផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់។ គាត់បានក្រោកឡើង និងតុបតែងខ្លួន ដើរលបៗកាត់វាំងនន នៅឆ្ងាយពីកន្លែងដែលប្រពន្ធរបស់គាត់ និងកូនៗរបស់គាត់កំពុងតែសម្រាន្ត។ គាត់បានយកកំប៉ុងតូចមួយ ដាក់ប្រេងកាតដុតប្រឆេះបំភ្លឺឡើង។ គាត់ក៏ចាប់ផ្តើមអានព្រះគម្ពីរ។ នៅព្រឹកនោះ គាត់កំពុងតែអាននៅក្នុងកណ្ឌគម្ពីរអេសាយ ជំពូកទី៥៨ ហើយបានឮពីសម្រេករបស់ព្រះជាម្ចាស់សម្រាប់ការថ្វាយបង្គំដែលទ្រង់សព្វព្រះហឫទ័យៈ

*ការតមអាហារដែលគាប់ចិត្តយើង គឺត្រូវដោះលែងអ្នកទោសដែលអ្នកយកមកដាក់ច្រវាក់ដោយអយុត្តិធម៌ ត្រូវដោះនឹមដែលអ្នកដាក់លើគេនោះចេញ ត្រូវដោះលែងអ្នកដែលត្រូវគេសង្កត់សង្កិន ឲ្យមានសេរីភាពឡើងវិញ ពោលគឺត្រូវបំបាក់នឹមគ្រប់យ៉ាង។ ត្រូវចែកអាហារឲ្យអ្នកស្រេកឃ្លាន ត្រូវទទួលជនក្រីក្រ ដែលគ្មានទីជម្រក ឲ្យស្នាក់នៅជាមួយ។ បើឃើញនរណាម្នាក់គ្មានសម្លៀកបំពាក់ ត្រូវចែកឲ្យគ្នាស្លៀកពាក់ផង ហើយមិនត្រូវគេចខ្លួនពីបងប្អូនណាដែលមកពឹងពាក់អ្នកឡើយ។*

លោកគ្រូ រ៉ង់ ក៏ឈប់ត្រឹមនេះ។ ដួងចិត្តរបស់គាត់កំពុងតែប្រឈមគ្នាជាមួយគំនិតរបស់គាត់។ ហេតុអ្វីបានជាព្រះជាម្ចាស់យកចិត្តទុកដាក់ជាមួយអ្នកក្រខ្សត់យ៉ាងដូច្នោះ នៅពេលដែលលោកគ្រូ រ៉ង់ ខ្លួនគាត់ផ្ទាល់កំពុងតែស្ថិតនៅក្នុងភាពទាល់ក្រ និងរងទុក្ខ ហើយសេចក្តីនេះក៏បានប៉ះពាល់ដួងចិត្តគាត់ជាខ្លាំង? គាត់ដឹងថា ប្រជាជននៅក្នុងសហគមន៍របស់គាត់ គឺខិតខំតស៊ូយ៉ាងលំបាកដើម្បីរស់។ ពួកគេពិតជាលំបាកលំបិនខ្លាំងណាស់។ ពេលខ្លះគាត់មិនមានអាហារបរិភោគគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់គាត់ និងមិនមានលទ្ធភាពដើម្បីទិញថ្នាំសង្កូវដែលពួកគេត្រូវការនោះទេ។ គាត់គិតថា «តើព្រះជាម្ចាស់ នៅឯណា? តើឲ្យខគម្ពីរនេះ បំពេញតម្រូវការនៅស្រុក ឡាស់ ប៉ាវ៉ាស់ (Las Pavas) បានយ៉ាងដូចម្តេចទៅ?»

នៅពេលដែលគាត់កំពុងតែតយុទ្ធជាមួយគំនិតទាំងអស់នេះ ស្រាប់តែបានឮសម្លេងគោះទ្វារ។ «តើនរណាគេទៅ គោះទ្វារទាំងព្រលឹមដូច្នោះ?» លោកគ្រូ រ៉ង់ គិត។ គាត់បានដើរទៅមាត់ទ្វារ។ «តើនរណាគេហ្នឹង?» សម្លេងនៅមួយចំហៀងទៀតបាននិយាយថា «រ៉ង់ ខ្ញុំជាព្រះយេស៊ូ។» «នរណាគេ?» គាត់សួរ។ «ខ្ញុំជាព្រះយេស៊ូ! រ៉ង់» សម្លេងនោះឆ្លើយ។ «តើអ្នកជាអ្នកណាឲ្យពិតប្រាកដ?» លោកគ្រូ រ៉ង់សួរ។ សម្លេង

នោះឆ្លើយ «វ៉ង់ ខ្ញុំជាព្រះយេស៊ូ។ ខ្ញុំមកនេះ ដោយសារតែខ្ញុំបានឮសម្រែកចេញពីដួងចិត្តរបស់អ្នក។ ខ្ញុំចង់ឲ្យអ្នកប្រាប់ខ្ញុំ ពីបញ្ហារបស់អ្នក។»

សម្លេងនោះឮច្បាស់ខ្លាំងណាស់។ លោកគ្រូ វ៉ង់ បានចាក់សោរទ្វារ បើកទ្វារ។ ពេលនោះមេឃនៅងងឹតនៅឡើយ ហើយលោកគ្រូ វ៉ង់ មើលឃើញតែស្រមោលប៉ុណ្ណោះ ប៉ុន្តែគាត់មើលឃើញតាមការស្រមៃរបស់គាត់ថាពិតជាព្រះយេស៊ូមែន។ «សូមព្រះអម្ចាស់ យាងចូលមក» លោកគ្រូ វ៉ង់ និយាយ។ «អត់ទេ វ៉ង់ ខ្ញុំចង់ឲ្យអ្នកនាំខ្ញុំទៅសហគមន៍របស់អ្នក ហើយបង្ហាញខ្ញុំពីអ្វីដែលធ្វើឲ្យប៉ះពាល់ដល់ដួងចិត្តរបស់អ្នក។» លោកគ្រូ វ៉ង់ យល់ព្រមទាំងភ្ញាក់ផ្អើល ហើយរំឭកថា «យើងត្រូវតែដើរដោយប្រុងប្រយ័ត្ន មេឃភ្លៀងខ្លាំងណាស់ ហើយនៅទីនេះមានសំរាមច្រើន ហើយយើងគ្មានបង្គន់ប្រើប្រាស់នោះទេ។»

នៅពេលដែលយើងដើរតាមផ្លូវក្នុងតំបន់ក្រីក្រនោះ លោកគ្រូ វ៉ង់ បានប្រាប់ព្រះយេស៊ូពីរឿងទាក់ទងនឹងផ្ទះនីមួយៗដែលគាត់បានដើរឆ្លងកាត់។ នៅក្នុងផ្ទះមួយនោះ មានស្ត្រីម្នាក់លក់ខ្លួនដើម្បីចិញ្ចឹមកូនៗរបស់នាង។ នៅក្នុងខ្ទមជិតនោះមានប្ដីប្រមឹកម្នាក់ ដែលតែងតែវាយប្រពន្ធ និងកូនៗរបស់គេគ្រប់ពេលដែលគាត់ស្រវឹង។ ហើយនៅទីនោះ ជាផ្ទះរបស់ប្រធានមូលនិធិ ជាបុរសម្នាក់ដែលពុករលួយគេងបន្លំយកលុយ ដោយសន្យាថានឹងតភ្ជាប់អគ្គិសនីដល់សហគមន៍ ប៉ុន្តែគាត់បានយកលុយនោះទៅផឹកស៊ី ហើយលេងល្បែងស៊ីសងអស់ទៅ។

ពួកគាត់បានដើរកាត់ទីកន្លែងសាធារណៈមួយនៅចំកណ្ដាលសហគមន៍នោះ។ វាគួរតែជាកន្លែងដែលជួបប្រជុំប្រជាជននៅក្នុងសហគមន៍ទាំងមូល ប៉ុន្តែនៅទីនោះពោរពេញទៅដោយសំរាមដែលស្អុយរលួយ និងកណ្ដុររត់ចុះឡើងពេញទីនោះ។ «មានឃើញផ្ទះនោះទេ? លោកគ្រូ វ៉ង់ សួរ ហើយចង្អុលទៅខ្ទមនៅជើងភ្នំ។ «មានស្ត្រីម្នាក់ និងកូន៤នាក់រស់នៅទីនោះ។ ហើយដំបូលលិចទឹកជាច្រើនកន្លែង។ ពួកគេក្រីក្រខ្លាំងណាស់។ ពួកគេមិនមានអាហារហូបចុក និងសំលៀកបំពាក់គ្រប់គ្រាន់នោះទេ ពួកគេតែងតែឈឺនេះឈឺនោះរហូត។» ហើយពីរនាក់ដែលនៅជើងភ្នំ ជាកន្លែងដែលសហគមន៍ ឡាស់ ប៉ាវ៉ាស់ ត្រូវបានកសាងឡើង។ លោកគ្រូ វ៉ង់ ចង្អុលពីចម្ងាយ «នៅត្រង់កន្លែងនោះវិញ ដែលមានស្រ្តី និងកូនរបស់គេដើរទៅដងទឹក។ ហើយនៅ ឡាស់ ប៉ាវ៉ាស់ នេះគ្មានទឹកទេ»។

លោកគ្រូ វ៉ង់ បានដើរទៅកាច់ជ្រុង ប៉ុន្តែបានឮសំឡេងយំ។ គាត់បានសម្លឹងតាមរកសំឡេងនោះ។ វាជាសំឡេងដែលព្រះយេស៊ូកំពុងតែយំ» លោកគ្រូ វ៉ង់ ឃើញថាព្រះយេស៊ូ ហើយនឹងរូបគាត់មានការប៉ះពាល់ដួងចិត្តដូចគ្នា។ លោកគ្រូ វ៉ង់ រៀបនឹងនិយាយ ប៉ុន្តែព្រះយេស៊ូបានដាក់ព្រះហស្តរបស់ទ្រង់ជុំវិញលោកគ្រូ វ៉ង់ ហើយមានបន្ទូលថា «វ៉ង់ ខ្ញុំចង់បង្ហាញអ្នកពីអ្វីដែលជាផែនការដែលខ្ញុំមានសម្រាប់សហគមន៍ ឡាស់ ប៉ាវ៉ាស់ នេះ»។

ភ្លាមៗនោះ លោកគ្រូវ៉ង់ កំពុងតែសម្លឹងមើលទៅឡាស់ ប៉ាវ៉ាស់។ ព្រះយេស៊ូចាប់ផ្តើមមានបន្ទូល ហើយ លោកគ្រូ វ៉ង់ ចាប់ផ្តើមស្រមៃឃើញពីអ្វីៗដែលព្រះយេស៊ូកំពុងតែបរិយាយអំពីអ្វីដែលនឹងកើតមានឡើង! ព្រះយេស៊ូមានព្រះបន្ទូលពីសមាជិកនៅក្នុងក្រុមជំនុំរបស់លោកគ្រូ វ៉ង់ ពីភាពក្រីក្ររបស់ពួកគេ ព្រមទាំង ចែករំលែកអ្វីដែលពួកគេមានជាមួយប្រជាជនក្រីក្រដែលនៅជិតខាងនោះ។ ជារៀងរាល់ថ្ងៃ ពួកគេសន្សំ អង្ករបន្តិចបន្តួច ហើយដាក់វានៅក្នុងកំប៉ុង។ នៅចុងសប្តាហ៍ ពួកគេមានកំប៉ុងដែលពេញទៅដោយអង្ករ ហើយពួកគេយកវាមកចែករំលែកនៅក្នុងព្រះនាមព្រះយេស៊ូ ជាមួយប្រជាជននៅក្នុងសហគមន៍ និង «ជួយចិញ្ចឹម» ពួកគេ ជួយពួកគេឲ្យចេះសម្អាត ចម្អិនម្ហូប និងចេះមើលថែរក្សាកូនៗរបស់ពួកគេ នៅពេល ដែលពួកគេឈឺ។

ព្រះយេស៊ូមានព្រះបន្ទូលអំពីការងារ ហើយលោកគ្រូ វ៉ង់ ឃើញថាមនុស្សមានការងារធ្វើ។ វាមិនមែនជា ការងារដែលផ្តល់ប្រាក់ខែខ្ពស់នោះទេ តែជាការងារដែលផ្តល់នូវភាពថ្លៃថ្នូរ ផ្តល់កម្រៃគ្រប់គ្រាន់សម្រាប់ តម្រូវការចាំបាច់ផ្សេងៗរបស់ពួកគេ។ ព្រះយេស៊ូមានព្រះបន្ទូលអំពីផ្ទះ ដែលលោកគ្រូ វ៉ង់ បានឃើញពី ខ្ទមបាក់បែកដែលនៅហាលខ្យល់ ហាលភ្លៀង បានផ្លាស់ប្តូរទៅជាផ្ទះជាច្រើន។ មិនមែនជាផ្ទះដែលល្អ ឆើតឆាយនោះទេ ប៉ុន្តែជាផ្ទះដែលផ្តល់សុវត្ថិភាព និងអនាម័យ។ ព្រះយេស៊ូមានបន្ទូលអំពីទឹកអាងស្តុក ទឹក នៅក្នុងទីកន្លែងដែលស្ត្រី និងក្មេងៗអាចយកទឹកស្អាតប្រើប្រាស់បាន។ ព្រះយេស៊ូមានបន្ទូលអំពី អនាម័យ ហើយលោកគ្រូ វ៉ង់ ឃើញមានបង្គន់ជាច្រើន មិននៅគ្រប់ផ្ទះនោះទេ ប៉ុន្តែមានគ្រប់គ្រាន់ដើម្បី ឲ្យមនុស្សគ្រប់គ្នាអាចប្រើប្រាស់បាន។ ហើយគំនរសំរាមដែលនៅទីប្រជុំជននោះ ត្រូវបានគេយកចេញ អស់គ្មានសល់។ ផ្ទុយទៅវិញ មានដើមឈើតូចៗ ហើយនៅទីនោះមានក្មេងៗសើចលេងក្អាកក្អាយ លេងជាមួយគ្នា និងលេងទាត់បាល់។ ព្រះយេស៊ូក៏មានបន្ទូលអំពីការផ្លាស់ប្រែនៅក្នុងជីវិតផងដែរ ហើយ លោកគ្រូ វ៉ង់ បានស្រមៃឃើញស្ត្រីដែលលក់ខ្លួន អាចចិញ្ចឹមកូនៗរបស់នាងដោយមានការងារសមរម្យ មួយ។ ប្តីដែលប្រមឹកនោះ ឥឡូវនេះជាប្តី និងជាឪពុកដែលពោរពេញទៅដោយសេចក្តីស្រលាញ់។ ចំណែកឯប្រធានមូលនិធិវិញ លែងប្រើប្រាស់លុយមិនស្មោះត្រង់ទៀតហើយ ប៉ុន្តែបែជាជួយទៅដល់ សហគមន៍វិញ។

បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលថា «វ៉ង់ ចូរសម្លឹងមើលទៅក្រុមជំនុំវិញ!» លោកគ្រូ វ៉ង់ ក៏មើលឃើញ មានមនុស្សពេញតែម្តង។ ហើយនៅទីនោះមានមនុស្សប្រុសៗជាច្រើន! សមាជិកនៅទីនោះសប្បាយ រីករាយ។ ពួកគេបានសរសើរតម្កើងព្រះជាម្ចាស់សម្រាប់កិច្ចការដ៏ល្អដែលទ្រង់បានធ្វើ។ ហើយនៅទីនោះ មានលោកគ្រូ វ៉ង់ កំពុងតែអធិប្បាយ បង្រៀន និងដឹកនាំសមាជិកចូលទៅក្នុងព្រះវិញ្ញាណ ហើយធ្វើ សកម្មភាពនៃសេចក្តីស្រលាញ់។ ព្រះយេស៊ូពន្យល់ថា «វ៉ង់ និមិត្តនេះមិនទាន់បានសម្រេចនៅឡើយទេ ទាល់តែខ្ញុំត្រឡប់មកវិញ ប៉ុន្តែជាផែនការរបស់ខ្ញុំសម្រាប់សហគមន៍ ឡាស់ ប៉ាវ៉ាស់នេះ។ ខ្ញុំចង់ឲ្យអ្នក ចែករំលែកនូវនិមិត្តនេះ ហើយចាប់ផ្តើមដឹកនាំមនុស្សទៅកាន់និមិត្តនេះ។»

លោកគ្រូវ៉ង់ បានប្រកែកថា «ប៉ុន្តែ ព្រះអម្ចាស់ យើងក្រខ្លាំងណាស់!» «វ៉ង់» ព្រះយេស៊ូសួរស្ងាត់ៗថា «តើនរណាដែលដឹកនាំប្រជាជនអ៊ីស្រាអែលឆ្លងកាត់សមុទ្រក្រហម? តើនរណាជាអ្នកដែលពហុគុណនំបុ័ង និងត្រី ហើយអាចផ្តល់អាហារដល់មនុស្សប្រាំពាន់អ្នក បូករួមទាំងស្ត្រី និងក្មេងៗផង? តើនរណាជាអ្នកដែលបំពេញប្រេង និងម្សៅរបស់ស្ត្រីមេម៉ាយនៅក្រុងសារិបតា ដើម្បីឲ្យនាងចិញ្ចឹមគ្រួសាររបស់នាងដល់ទៅ៣ឆ្នាំនោះ? តើនរណាជាអ្នកដែលធ្វើឲ្យសមុទ្រនៅស្រុកកាលីឡេស្ងប់?» «គឺទ្រង់ ព្រះអម្ចាស់» លោកគ្រូ វ៉ង់ និយាយ។ «ដូច្នេះ វ៉ង់ ត្រូវតែធ្វើតាមអ្វីដែលយើងបានសុំឲ្យលោកធ្វើ។ ចូរចែករំលែកនូវអ្វីដែលលោកមាន ទោះបីជាតិចតួចក៏ដោយ។ ចូរប្រកាសពីផែនការដ៏ល្អរបស់យើងនេះ ទៅប្រជាជនរបស់លោកទៅ ទាំងខាងព្រលឹងវិញ្ញាណ និងរូបកាយ។ ហើយយើងនឹងប្រោសដីរបស់លោកឲ្យបានជា!»

លោកគ្រូ វ៉ង់ ក៏បានឮសម្លេងមាន់រងាវ។ ប្រពន្ធរបស់គាត់ក្អក រើ នៅម្ខាងនៃវាំងនន។ គាត់កំពុងតែអង្គុយនៅជិតតុ ប៉ុន្តែចង្កៀងរបស់គាត់បានរលត់ទៅហើយ។ ថ្ងៃក៏រះឡើង។ លោកគ្រូ វ៉ង់ បានសម្លឹងរកមើលព្រះយេស៊ូ ប៉ុន្តែមិនឃើញទ្រង់នោះទេ។ គាតឆ្ងល់ថា «តើខ្ញុំយល់សប្តិទេដឹង? តើវាជានិមិត្តឬ?» គាត់មិនប្រាកដនោះទេ ប៉ុន្តែគាត់ដឹងច្បាស់ថា គាត់បានជួបព្រះយេស៊ូ ហើយគាត់បានយល់ច្បាស់ពីការយកចិត្តទុកដាក់របស់ទ្រង់ទៅលើអ្នកក្រីក្រ និងនិមិត្តថ្មីមួយ ពីរបៀបដែលគាត់នឹងដឹកនាំប្រជាជនរបស់គាត់ឲ្យឃើញពីស្រលាញ់របស់ព្រះជាម្ចាស់នៅក្នុងសហគមន៍ឡាស់ ប៉ាវ៉ាស់នេះ។